**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royal de droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# កំណើនសេដ្ឋកិច្ចនៅកម្ពុជាតាមរយៈ វិស័យឧស្សាហកម្ម

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០២២


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **គួច មួយអ៊ីម**

**ខុទ្ធ ដានេ**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ខ៉ាន់ ស៊ុនដេត**


ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី ៦

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **គួច មួយអ៊ីម** និង **ខុទ្ធ ដារ៉េ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ ក្រុមរបស់ខ្ញុំបានជ្រើសរើសយកប្រធានបទ " **កំណើនសេដ្ឋកិច្ចនៅកម្ពុជាតាមរយៈវិស័យឧស្សាហកម្ម** " មកចងក្រងជារបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ យើងខ្ញុំសូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដូចតទៅ ៖

ជាដំបូងយើងខ្ញុំសូមសំដែងនូវការដឹងគុណដ៏ជ្រាវជ្រៅចំពោះលោកឪពុក អ្នកម្តាយដែលបានចិញ្ចឹមបីបាច់ថែរក្សា និងផ្តល់នូវដំបូន្មានល្អៗចំពោះរូបកូន ជាពិសេសបានជួយទំនុកបម្រុងគាំទ្រដល់ការសិក្សាតាំងពីថ្នាក់បឋមសិក្សារហូតបញ្ចប់ថ្នាក់បរិញ្ញាបត្រ។ លើសពីនេះទៅទៀតលោកបានបញ្ចេញកម្លាំងកាយ ចិត្ត ប្រាជ្ញាស្មារតី ដើម្បីរកថវិការមកផ្គត់ផ្គង់ដល់ការសិក្សារបស់កូន។ គុណដ៏ធំធេងនេះកូននឹងចងចាំទុកដោយខិតខំប្រឹងប្រែងរៀនសូត្រឲ្យសមជាកូនល្អសម្រាប់គ្រួសារ និងសង្គមជាតិនាពេលអនាគត។

ឯកឧត្តមនៃសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹតបុរស នាយកថ្នាក់ក្រោយបរិញ្ញាបត្រ ប្រធានការិយាល័យ និងបុគ្គលិកសិក្សា ព្រមទាំងសាស្ត្រាចារ្យគ្រប់មុខវិជ្ជានៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានផ្តល់ការអប់រំ និងចំណេះដឹងជាច្រើនដល់យើងខ្ញុំដើម្បីជាស្ពានឈានទៅរកភាពជោគជ័យនាពេលអនាគត។

លោកសាស្ត្រាចារ្យបណ្ឌិត **ខ៉ាន់ ស៊ុនដេត** ដែលបានខិតខំបង្ហាត់បង្រៀន ជួយជ្រោមជ្រែង ដឹកនាំជ្រើសរើសនូវឯកសារល្អៗយកមកបង្ហាញ និងផ្តល់នូវគំនិតល្អៗក្នុងការរៀបចំសរសេរសារណាមួយនេះ និងកែសម្រួលនូវចំណុចខ្វះខាតចាប់តាំងពីចំណុចផ្តើមរហូតទទួលបានជោគជ័យ។

ជាទីបញ្ចប់ យើងខ្ញុំសូមជូនពរដល់មិត្តអ្នកអាន អ្នកស្រាវជ្រាវ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ទទួលបាននូវពរទាំងឡាយបួន សម្បត្តិបី អរិយទ្រព្យប្រាំពីរ និងមានសេចក្តីសុខ សំណាងល្អគ្រប់ពេលវេលា ជោគជ័យលើការសិក្សា និងជោគជ័យនូវគោលបំណងដែលប៉ងគ្រប់ៗគ្នាកុំបីខានឡើយ។

# អារម្ភកថា

សូមស្វាគមន៍មិត្តៗនិស្សិត ប្រិយមិត្តអ្នកអាន និងអ្នកសិក្សាស្រាវជ្រាវជាទីគោរព។ សៀវភៅសារណាដែលលោកអ្នកកំពុងតែកាន់អាននេះ ជាសមិទ្ធិផលកើតឡើងដោយយើងខ្ញុំផ្ទាល់ដែលបានខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់គ្រប់សកម្មភាពទាំងអស់រហូតប្រមូលផ្តុំចងក្រងបានជាសៀវភៅនេះឡើងដែលក្នុងនោះមានទាក់ទងទៅនឹងកំណើនសេដ្ឋកិច្ចនៅកម្ពុជាតាមរយៈវិស័យឧស្សាហកម្ម។

ខ្លឹមសារនៃការស្រាវជ្រាវក្នុងសៀវភៅនេះនឹងផ្តល់នូវចំណេះ ក៏ដូចជាជួយអ្នកឲ្យស្គាល់ពីវិស័យឧស្សាហកម្មនៅកម្ពុជា មូលហេតុដែលនាំឲ្យមានកំណើនសេដ្ឋកិច្ច និងបញ្ហា យុទ្ធសាស្ត្រមួយចំនួនតូចទៅតាមលទ្ធភាពដែលខ្ញុំធ្លាប់បានសិក្សាស្រាវជ្រាវកន្លងមក និងតាមឯកសារយោងខ្លះៗនៅក្នុងបណ្ណាល័យ អ៊ីនធឺណេត និងកន្លែងផ្សេងៗ។ ក្រុមយើងខ្ញុំធ្វើកិច្ចការស្រាវជ្រាវនេះឡើងសង្ឃឹមថាកិច្ចការស្រាវជ្រាវនេះនឹងក្លាយជាសៀវភៅដ៏ល្អ និងជាមូលដ្ឋានមួយសម្រាប់ឈានទៅរកភាពលំអិតសម្រាប់មិត្តទាំងអស់គ្នា និងនិស្សិតជាក់ជាពុំខានឡើយ។

ជាចុងក្រោយយើងខ្ញុំរង់ចាំទទួលការរិះគន់ និងគំនិតថ្មីៗពីសំណាក់អ្នកអាន លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មិត្តរួមជំនាន់ និងប្អូនៗជំនាន់ក្រោយ រាល់កំហុសខុសឆ្គងពាក្យពេចន៍ ឃ្លា វេយ្យាករណ៍ អក្ខរាវិរុទ្ធ ដើម្បីជួយកែលំអរសៀវភៅនេះឲ្យមានភាពសុក្រឹត។

# មាតិកា

ទំព័រ

បញ្ជីអក្សរកាត់.....................................................................iv

បញ្ជីតារាង.....................................................................v

បញ្ជីក្រាហ្វិក.....................................................................vi

## សេចក្តីផ្តើម

១. លំនាំបញ្ហា.....................................................................1

២. កម្មវត្ថុនៃការស្រាវជ្រាវ.....................................................................1

៣. ចំណោទបញ្ហា.....................................................................2

៤. សារៈសំខាន់នៃការស្រាវជ្រាវ.....................................................................2

៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ.....................................................................2

៦. វិធីសាស្រ្តនៃការស្រាវជ្រាវ.....................................................................2

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.....................................................................3

## ជំពូកទី១

## រំលឹកទ្រឹស្តីកំណើនសេដ្ឋកិច្ច

**១.១ កំណើនសេដ្ឋកិច្ច**.....................................................................5

១.១.១ និយមន័យនៃកំណើនសេដ្ឋកិច្ច.....................................................................5

១.១.២ ទ្រឹស្តីនៃកំណើនសេដ្ឋកិច្ច.....................................................................5

១.១.២.១ ទ្រឹស្តីបុរាណ.....................................................................6

១.១.២.២ ទ្រឹស្តីសម័យថ្មី.....................................................................6

១.១.២.៣ ទ្រឹស្តីកំណើនសេដ្ឋកិច្ចថ្មី.....................................................................7

១.១.២.៤ ទ្រឹស្តីកំណើនបង្រួបបង្រួម.....................................................................7

១.១.៣ ការវាស់កំណើនសេដ្ឋកិច្ច.....................................................................8

**១.២ ឧស្សាហៈធានអំពីវិស័យឧស្សាហកម្មលើកំណើនសេដ្ឋកិច្ច** ........ 10
**១.៣ វិស័យឧស្សាហកម្ម** ........ 13
១.៣.១ និយមន័យឧស្សាហកម្ម ........ 13
១.៣.២ ទម្រង់នៃឧស្សាហកម្ម ........ 14
១.៣.២.១ ឧស្សាហកម្មផ្អែកលើវត្ថុធាតុដើម ........ 14
១.៣.២.២ ទម្រង់ឧស្សាហកម្មតាមទំហំ ........ 14
១.៣.២.៣ ទម្រង់ឧស្សាហកម្មកម្មសិទ្ធិ ........ 16
**១.៤ ករណីសិក្សាវិស័យឧស្សាហកម្មជម្រុញកំណើនសេដ្ឋកិច្ចបរទេស** ........ 17
១.៤.១ ការសិក្សាលើវិស័យឧស្សាហកម្មនៅប្រទេសសិង្ហបុរី ........ 17
១.៤.២ ការសិក្សាលើវិស័យឧស្សាហកម្មនៅប្រទេសឥណ្ឌូនេស៊ី ........ 19
១.៤.៣ ការសិក្សាលើវិស័យឧស្សាហកម្មនៅប្រទេសថៃ ........ 20
**១.៥ វិស័យឧស្សាហកម្មជម្រុញកំណើនសេដ្ឋកិច្ចនៅកម្ពុជា** ........ 22
១.៥.១ វិស័យកាត់ដេរ ........ 23
១.៥.២ វិស័យទេសចរណ៍ ........ 23
១.៥.៣ វិស័យសំណង់ និងអចលនទ្រព្យ ........ 25
១.៥.៤ វិស័យកសិ-ឧស្សាហកម្ម ........ 26

**ជំពូកទី២**

**ទិដ្ឋភាពទូទៅនៃវិស័យឧស្សាកម្មនៅកម្ពុជា**

**២.១ សង្ខេបស្ថានភាពសេដ្ឋកិច្ចកម្ពុជា** ........ 28
**២.២ ស្ថានភាពវិស័យឧស្សាហកម្មកម្ពុជា** ........ 28
២.២.១ ប្រវត្តិសង្ខេបនៃវិស័យឧស្សាហកម្ម ........ 29
២.២.២ រចនាសម្ព័ន្ធឧស្សាហកម្ម ........ 30
**២.៣ ស្ថានភាពវិស័យឧស្សាហកម្មក្រោយពេលមានគោលនយោបាយ** ........ 31
២.៣.១ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មរបស់រាជរដ្ឋាភិបាល ........ 31
២.៣.២ ភាពចាំបាច់នៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ........ 31

២.៣.២ បញ្ហាប្រឈម នៃការអភិវឌ្ឍន៍ឧស្សាហកម្មនៅកម្ពុជា ........ 33
២.៣.៣ យុទ្ធសាស្រ្តគន្លឹះនៃការអភិវឌ្ឍវិស័យឧស្សាហកម្ម ........ 34
២.៣.៤ ការអនុគ្រោះចំពោះសហគ្រាសដែលមានអនុលោមភាពសារពើពន្ធខ្ពស់ ........ 35
**២.៤ អត្ថប្រយោជន៍របស់ឧស្សាហកម្មក្នុងការរួមចំណែកដល់សេដ្ឋកិច្ចកម្ពុជា** ........ 35
២.៤.១ បង្កើតការងារដល់ប្រជាពលរដ្ឋ និងលើកកម្ពស់គុណភាពរស់នៅ ........ 36
២.៤.២ បង្កើនការនាំចេញ និងពង្រឹងពាណិជ្ជកម្មអន្តរជាតិ ........ 37
២.៤.៣ ជួយសម្រួលដល់សេដ្ឋកិច្ចជាតិ ........ 37
២.៤.៤ កាត់បន្ថយភាពក្រីក្រ និងការធ្វើចំណាកស្រុក ........ 38
២.៤.៥ ទាក់ទាញវិនិយោគគិនបរទេស ........ 38

## ជំពូកទី៣

## ការវិភាគលើទិន្នន័យ

៣.១ ការកំណត់អថេរ និងគំរូវិភាគ ........ 41
៣.២ ទំនាក់ទំនងរវាងវិស័យឧស្សាហកម្ម និងផលិតផលក្នុងស្រុកសរុប ........ 41
៣.៣ ការវិភាគទិន្នន័យ ........ 43
**សេចក្តីសន្និដ្ឋាន** ........ 46
**ការផ្តល់អនុសាសន៍** ........ 47
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| ល.រ | អក្សរកាត់ | ពាក្យពេញជាភាសាអង់គ្លេស | ពាក្យពេញជាភាសាខ្មែរ |
|---|---|---|---|
| ១ | GDP | Gross Domestic Product | ផលិតផលជាតិសរុប |
| ២ | OPEC | Organization Of The Petroleum Exporting Country | អង្គការនាំចេញប្រេង |
| ៣ | EU | European Union | សហជីពអឺរ៉ុប |
| ៤ | FDI | Foreign Direct Investment | ការវិនិយោគផ្ទាល់ពីបរទេស |
| ៥ | CVEA | Cambodian Valuers And Estate Agents Association | សមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា |
| ៦ | MFN | Most Favoured Nation | សិទ្ធិអនុគ្រោះពន្ធ |
| ៧ | GSP | Generalized System Of Preferences | ប្រព័ន្ធអនុគ្រោះពន្ធទូទៅ |
| ៨ | AEC | Asean Economic Community | សហគមន៍សេដ្ឋកិច្ចអាស៊ាន |
| ៩ | RCEP | Regional Comprehensive Economic Partnership | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី |
| ១០ | TNI | Total Net Income | ប្រាក់ចំណូលជាតិសរុប |
| ១១ | Ex-IM | Export-Import | ការនាំចេញ- ការនាំចូល |
| ១២ | LDC | Least developed countries | ប្រទេសអភិវឌ្ឍន៍តិចតួច |
| ១២ | WTO | World Trade Organization | អង្គការពាណិជ្ជកម្មពិភពលោក |
| ១៣ | TIFA | Trade Investment Framework Agreement | កិច្ចព្រមព្រៀងក្របខ័ណ្ឌវិនិយោគពាណិជ្ជកម្ម |
| ១៤ | AFTA | ASEAN Free Trade Area | តំបន់ពាណិជ្ជកម្មសេរីអាស៊ាន |
| ១៥ | SOE | state-owned enterprise | សហគ្រាសរដ្ឋ |

# បញ្ជីតារាង


- តារាងនិយមន័យនៃសហគ្រាសធុន មីក្រូ តូច មធ្យម និងធុនរបស់រាជរដ្ឋាភិបាល ........................ 15
- តារាចំណែកសហគ្រាសដែលបានចុះបញ្ជីអាជីវកម្មស្របច្បាប់គិតជា(%) .................................... 16
- តារាងទិន្នន័យវិស័យឧស្សាហកម្មនៅប្រទេសឥណ្ឌូនេស៊ី ........................................................ 20
- តារាងទិន្នន័យវិស័យឧស្សាហកម្មនៅប្រទេសថៃ ..................................................................... 22
- តារាងរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា(ជាពាន់រៀល) ................................................................ 30
- តារាងទិន្នន័យការនាំចេញ(%GDP) នៅកម្ពុជា(២០០៩-២០២០) ............................................... 37
- តារាងទិន្នន័យកំណើនប្រាក់ចំណូលនៃមនុស្សម្នាក់នៅកម្ពុជា .................................................... 38
- តារាងទិន្នន័យនៃការវិនិយោគផ្ទាល់ពីបរទេសនៅប្រទេសកម្ពុជា(២០០៩-២០១៩) ......................... 39
- តារាងដែលបង្ហាញទំនាក់ទំនងរវាងវិស័យឧស្សាហកម្ម និងផលិតផលក្នុងស្រុកសរុប .................... 42

# បញ្ជីក្រាហ្វិក


- ក្រាហ្វិកទិន្នន័យនៃការនាំចេញសម្លៀកបំពាក់ និងស្បែកជើងនៅកម្ពុជា(២០០០-២០១៨) ........... 23
- ក្រាហ្វិកទិន្នន័យចំនួនភ្ញៀវទេសចរណ៏នៃកម្ពុជា(២០១៤-២០១៩) .......................................... 25
- ក្រាហ្វិកនៃទិន្នន័យកំណើនប្រទេសកម្ពុជា (២០១៦-២០២០) ................................................ 26
- ក្រាហ្វិកទិន្នន័យការចែកចាយការងារតាមវិស័យសេដ្ឋកិច្ច(២០០៩-២០១៩) .............................. 36
- ក្រាហ្វិកទិន្នន័យរវាង%GDP និង%Industry Sector ........................................................... 47

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ចាប់តាំងពីសង្គ្រាមស៊ីវិលត្រូវបានបញ្ចប់ក្នុងរយៈពេលជាច្រើនទសវត្សកន្លងមក ប្រទេសកម្ពុជារក្សាបានកំណើនសេដ្ឋកិច្ចខ្ពស់គួរឲ្យកត់សម្គាល់ ពោលគឺការឈានឆ្ពោះទៅសម្រេចឋានៈប្រទេសមានចំណូលមធ្យមដែលតម្រូវឲ្យមានការកែទម្រង់រចនាសម្ព័ន្ធស៊ីជម្រៅ សំដៅពង្រឹងពិពិធកម្មសេដ្ឋកិច្ច និងភាពប្រកួតប្រជែងដែលធានាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងមានការបែងចែកផ្លែផ្កាប្រកបដោយសមធម៌។ ទន្ទឹមនឹងការសម្រេចបាននូវបង្គោលចរជាប្រវត្តិសាស្ត្រនេះបានលើកទឹកចិត្តរដ្ឋាភិបាលឲ្យសម្លឹងឆ្ពោះទៅមុខតាមរយៈការបន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ និងដាក់ចេញគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មជាបន្តបន្ទាប់ដើម្បីជម្រុញឲ្យមានកំណើនសេដ្ឋកិច្ចជាតិ និងប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់។

ជាក់ស្តែង វិស័យឧស្សាហកម្មក៏ជាប្រភពចំណូលមួយដ៏សំខាន់ និងជាស្នូលរបស់ប្រទេសកម្ពុជាផងដែរ បន្ទាប់ពីវិស័យកសិកម្មដែលបានរួមចំណែកដល់ការរីកចម្រើនឥតឈប់ឈរនៃសេដ្ឋកិច្ចជាតិ។ ជាហេតុ ក្នុងឆ្នាំ ២០១៥រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម សំដៅផ្តល់នូវក្របខណ្ឌគោលនយោបាយ និងយន្តការជាក់លាក់សម្រាប់ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា និងបង្កើតការងារផ្តោតលើការអភិវឌ្ឍន៍វិស័យកម្មន្តសាល កសិឧស្សាហកម្ម និងសហគ្រាសធុនតូច និងមធ្យម។ តាមរយៈគោលនយោបាយនេះ កម្ពុជានឹងសម្រេចបាននូវការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចមួយយ៉ាងជ្រាលជ្រៅដោយឈានពីរចនាសម្ព័ន្ធដែលពឹងផ្អែកលើវិស័យកសិកម្មទៅបង្កើតសេដ្ឋកិច្ចដែលពឹងផ្អែកសំខាន់លើកម្មន្តសាល និងកសិឧស្សាហកម្ម ហើយឈានទៅដល់ការលើកកម្ពស់ និងពិពិធកម្មឧស្សាហកម្មក្នុងវិស័យផ្សេងៗទៀត ជាពិសេសឧស្សាហកម្មដែលប្រើប្រាស់បច្ចេកវិទ្យា និងនវានុវត្តន៍ក្នុងដំណាក់កាលចុងក្រោយ។

## ២. កម្មវត្ថុនៃការស្រាវជ្រាវ

តាមរយៈការសិក្សាមុខវិជ្ជា សេដ្ឋកិច្ចអភិវឌ្ឍន៍កន្លងមក សង្កេតឃើញថាវិស័យឧស្សាហកម្មពិតជាមានឥទ្ធិពលទៅលើសេដ្ឋកិច្ចប្រទេសនីមួយៗ ជាពិសេសចំពោះសេដ្ឋកិច្ចប្រទេសកម្ពុជាគឺមានកំណើនជាលំដាប់ នេះជាហេតុដែលពួកខ្ញុំសម្រេចចិត្តជ្រើសប្រធានបទ ក្នុងគោលបំណងចង់ស្រាវជ្រាវបន្ថែមតាមចំនុចខាងក្រោមនេះ៖

- ការវាស់កំណើនសេដ្ឋកិច្ច
- ប្រភេទនានានៃវិស័យឧស្សាហកម្មនៅកម្ពុជា
- កំណើនសេដ្ឋកិច្ចតាមរយៈវិស័យឧស្សាហកម្ម
- តួនាទីនៃវិស័យឧស្សាហកម្មក្នុងសេដ្ឋកិច្ចជាតិ។

## ៣. ចំណោទបញ្ហា

ក្នុងបរិបទនៃការអភិវឌ្ឍប្រទេស ក៏ដូចជាជំរុញកំណើនសេដ្ឋកិច្ចជាតិមួយរយៈកាលកន្លងមក កម្ពុជាតែងតែពឹងផ្អែកលើវិស័យកសិកម្មជាស្នូលដ៏សំខាន់ ប៉ុន្តែបច្ចុប្បន្នកម្ពុជាបានឈានផុតពីប្រទេសពឹងផ្អែកទាំងស្រុងទៅលើវិស័យកសិកម្ម មកពឹងផ្អែកលើឧស្សាហកម្មវិញ ព្រោះវិស័យនេះចាប់ផ្តើមមានកំណើនខ្ពស់ និងផ្តល់ចំណូលដល់ប្រទេសជាតិយ៉ាងច្រើន។ ដោយយោងតាមការរៀបរាប់ខាងលើយើងខ្ញុំសូមលើកជាសំនួរថា

តើវិស័យឧស្សាហកម្មបានផ្តល់ កំណើនសេដ្ឋកិច្ចដូចម្តេចខ្លះ?

## ៤. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃអត្ថបទនៃការស្រាវជ្រាវនេះ គឺចង់បង្ហាញដល់មិត្តអ្នកអាន និងមិត្តនិស្សិតជាច្រើនដូចជា៖

- សារៈសំខាន់នៃវិស័យឧស្សាហកម្មនៃកំណើនសេដ្ឋកិច្ច
- ស្វែងយល់ពីផលវិបាក និងដំណោះស្រាយទៅលើបញ្ហាប្រឈមនានានៃវិស័យនេះ
- យល់ដឹងពីគោលនយោបាយ ឬយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ទៅលើវិស័យនេះ

## ៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

វិស័យឧស្សាហកម្មនៅកម្ពុជា គឺមានទាក់ទងវិស័យជាច្រើន ជាក់ស្តែងអត្ថបទនេះពួកខ្ញុំបកស្រាយតែវិស័យសំខាន់ៗទាំង៤ ដែលជាសរសៃឈាមដ៏សំខាន់នៃសេដ្ឋកិច្ចកម្ពុជា មានដូចជា វិស័យកាត់ដេរ វិស័យទេសចរណ៍ វិស័យសំណង់និងអចលទ្រព្យ និងកសិ-ឧស្សាហកម្ម។ ចំពោះទិន្នន័យនានាដែលមាននៅក្នុងអត្ថបទនេះ យើងយកត្រឹមទិន្នន័យដុលដែលមានស្រាប់របស់ប្រទេសកម្ពុជា ដែលទិន្នន័យទាំងនោះបានដាក់បង្ហាញនៅតាមគេហទំព័ររបស់ក្រសួងនានាដែលជាប់ពាក់ព័ន្ធ ទិន្នន័យទាំងអស់នេះយើងខ្ញុំយកតែទិន្នន័យពីឆ្នាំ២០១០-២០១៩។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីចងក្រងចេញជាសៀវភៅ កំណើនសេដ្ឋកិច្ចនៅកម្ពុជាតាមរយៈវិស័យឧស្សាហកម្ម នេះពួកខ្ញុំបានជ្រើសរើសវិធីសាស្ត្របរិមាណ (Quantitative Method) ក្នុងការស្វែងរកទិន្នន័យ និងប្រមូលទិន្នន័យទាំងនោះដើម្បីផ្ទៀងផ្ទាត់អំពីទំនាក់ទំនងរវាងវិស័យឧស្សាហកម្ម និងកំណើនសេដ្ឋកិច្ច។

- តម្រូវការទិន្នន័យស្រាប់ធ្វើការវិភាគ គឺប្រើប្រាស់ទិន្នន័យទី២ (Secondary Data)។
- ទិន្នន័យបានដកស្រង់ចេញពី ក្រសួងជាប់ពាក់ព័ន្ធមាន៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកពន្ធដារ ក្រសួងរៀបចំដែនដីនគររូបនីយកម្ម និងសំណង់ ក្រសួងទេសចរណ៍ ក្រសួងពាណិជ្ជកម្ម។
- ធានាគារពិភពលោក(World Bank) វេបសាយដែលមានទិន្នន័យពាក់ព័ន្ធនានា។

- ទិន្នន័យដែលប្រមូលបាននឹងយកមកចងក្រង រៀបចំឲ្យក្លាយទៅជាអត្ថបទស្រាវជ្រាវមួយដែលមានលក្ខណៈបច្ចេកទេសសមស្របទៅតាមហេតុផលដែលបានកើតមាននៅក្នុងការវិភាគកំណើនសេដ្ឋកិច្ច និងបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវផងដែរ។ ទិន្នន័យដែលត្រូវយកមកសិក្សាគឺវាស់ជាភាគរយទាំងនៅក្នុងវិស័យឧស្សាកម្ម នៅក្នុងផលិតផលក្នុងស្រុកសរុប(GDP)។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃកម្រងស្នាដៃសារណា នៃប្រធានបទនេះមានបីជំពូកសំខាន់ៗ មានដូចជា៖

- ជំពូកទីមួយ បកស្រាយរលឹកអំពីនិយមន័យ និងទ្រឹស្តីបទនៃពាក្យគន្លឹះនៃប្រធានបទ និងបកស្រាយពីទស្សនៈដែលជាប់ពាក់ព័ន្ធផ្សេងៗរបស់ប្រធានបទ ក៏ដូចជារួមបញ្ចូលទាំងការសិក្សាវិស័យឧស្សាហកម្មរបស់ប្រទេសជិតខាងផងដែរ។
- ជំពូកទីពីរ ធ្វើការបង្ហាញពីស្ថានភាពសេដ្ឋកិច្ច និងស្ថានភាពនៃឧស្សាហកម្មនៅកម្ពុជា ក៏ដូចជាបកស្រាយអំពីសារៈសំខាន់នៃឧស្សាហកម្មក្នុងសេដ្ឋកិច្ចជាតិ។
- ជំពូកទីបី គឺជាការធ្វើការវិភាគទិន្នន័យ និងបកស្រាយទិន្នន័យពីទំនាក់ទំនងរវាងឧស្សាហកម្ម និងកំណើនសេដ្ឋកិច្ចកម្ពុជា។

# ជំពូកទី១
# រំលឹកទ្រឹស្តីនៃកំណើនសេដ្ឋកិច្ច

# ជំពូកទី១

# រំលឹកទ្រឹស្តីនៃកំណើនសេដ្ឋកិច្ច

## ១.១ កំណើនសេដ្ឋកិច្ច

សេដ្ឋកិច្ចគឺជាការសិក្សាអំពីភាពខ្វះខាត និងផលប៉ះពាល់របស់វាចំពោះការប្រើប្រាស់ធនធាន ការផលិតទំនិញ និងសេវាកម្ម កំណើននៃផលិតកម្ម និងសុខុមាលភាពតាមពេលវេលា និងបញ្ហាស្មុគស្មាញជាច្រើនផ្សេងទៀត ដែលជាកង្វល់ដ៏សំខាន់ចំពោះសង្គម។ កំណើនសេដ្ឋកិច្ចត្រូវបានកំណត់យ៉ាងល្អបំផុតថាជាការកើនឡើងប្រកបដោយនិរន្តរភាពនៃសក្តានុពលផលិតភាពយូរអង្វែង ឬសមត្ថភាពរបស់ប្រទេសមួយ។ កំណើនកើតចេញពីការពង្រីកទាំងបរិមាណ និងគុណភាពនៃកត្តាធាតុចូលដែលឆ្លុះបញ្ចាំងនៅក្នុងផលិតភាពខ្ពស់ និងឥទ្ធិពលកំណើននៃការច្នៃប្រឌិត។ ជាពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព គឺជាកត្តាសំខាន់សម្រាប់ការកាត់បន្ថយភាពក្រីក្រខ្លាំង និងការលើកកម្ពស់កម្រិតជីវភាពជាមូលដ្ឋាន។ អត្ថប្រយោជន៍ដ៏មានសក្តានុពលមួយទៀតនៃកំណើនសេដ្ឋកិច្ចសម្រាប់ប្រទេសដែលមានចំណូលទាប និងមធ្យម គឺថាវានឹងទាក់ទាញលំហូរចូលកាន់តែច្រើននៃការវិនិយោគផ្ទាល់ពីបរទេស (FDI)។ ការបន្ថែមដើមទុនទៅក្នុងសេដ្ឋកិច្ចមាននិន្នាការបង្កើនផលិតភាពការងារ។ ឧបករណ៍ថ្មី ល្អជាង និងច្រើនទៀត មានន័យថា កម្មករអាចផលិតទិន្នផលបានច្រើនតាមពេលវេលា។ ជាឧទាហរណ៍សាមញ្ញ អ្នកនេសាទដែលមានសំណាញ់នឹងចាប់ត្រីច្រើនជាងក្នុងមួយម៉ោងជាងអ្នកនេសាទដែលមិនមានសំណាញ់ ។

### ១. ១.១ និយមន័យនៃកំណើនសេដ្ឋកិច្ច

កំណើនសេដ្ឋកិច្ច ទោះបីត្រូវបានចាប់យកក្នុងរង្វាស់ផ្សេងទៀតជាច្រើនក៏ដោយ ត្រូវបានកំណត់ជាចម្បងថាជាការកើនឡើងនៃផលិតកម្មទំនិញ និងសេវាកម្មនៅក្នុងសេដ្ឋកិច្ចមួយ (Ackermann, 2012)។ កំណើនសេដ្ឋកិច្ចអាចវាស់វែងបាន នៅពេលដែលការពិតពីស្ថិតិនៃសេដ្ឋកិច្ចនៅក្នុងចំណុចពីរផ្សេងគ្នាក្នុងពេលវេលាត្រូវបានប្រៀបធៀប ហើយពេលវេលាចុងក្រោយបង្ហាញពីទំនិញ និងសេវាកម្មកាន់តែច្រើន សេដ្ឋកិច្ចជាទូទៅត្រូវបានចាត់ទុកថាកំពុងរីកចម្រើន។ កំណើនសេដ្ឋកិច្ចជាធម្មតាត្រូវបានបង្ហាញនៅក្នុងផលិតផលក្នុងស្រុកសរុប (GDP) នៃប្រទេសមួយ។ កត្តាសំខាន់ៗដែលពាក់ព័ន្ធក្នុងកំណើនសេដ្ឋកិច្ចគឺ បច្ចេកវិទ្យា កម្លាំងពលកម្ម និងដើមទុន។

### ១.១.២ ទ្រឹស្តីនៃកំណើនសេដ្ឋកិច្ច

ការកើនឡើងនៃទំនិញ និងសេវាកម្មដែលផលិតដោយសេដ្ឋកិច្ច ជាទូទៅប្រទេសមួយ គឺជាកំណើនសេដ្ឋកិច្ច ។ វាត្រូវបានវាស់វែងជាភាគរយ នៃការកើនឡើង នៃផលិតផលក្នុង ស្រុកសរុបពិតប្រាកដ (GDP) ដែលជាផលិតផលក្នុងស្រុកសរុប (GDP) ដែលត្រូវបានកែសម្រួល សម្រាប់អតិផរណា។ GDP គឺជាតម្លៃទីផ្សារនៃទំនិញ និងសេវាកម្មចុងក្រោយទាំងអស់ ដែលផលិតនៅក្នុងសេដ្ឋកិច្ច ឬប្រទេសមួយ។ ដូច្នេះតើប្រទេសមួយ

ឬសេដ្ឋកិច្ចបន្តបង្កើន GDP ដូចដែលនិន្នាការកំណើនសេដ្ឋកិច្ចកើនឡើង ដោយរបៀបណា? មានទ្រឹស្តីកំណើនសេដ្ឋកិច្ចសំខាន់ៗចំនួន4តាមពេលវេលា ដែលព្យាយាម ឆ្លើយសំណួរពិតប្រាកដនោះ។ដូចនេះ ទ្រឹស្តីបុរាណ ទ្រឹស្តីសម័យថ្មី ទ្រឹស្តីកំណើនថ្មី និងទ្រឹស្តីកំណើនបង្រួបបង្រួមនឹងត្រូវបានពិពណ៌នា។

**១.១.២.១ ទ្រឹស្តីបុរាណ**

ទ្រឹស្តីកំណើនបុរាណដ៏លេចធ្លោត្រូវបានបង្កើតឡើងដោយ Adam Smith និង Thomas Malthus ។ ទ្រឹស្តីទាំងនេះបានស្វែងយល់ពីផលប៉ះពាល់នៃការកើនឡើងចំនួនប្រជាជនលើកំណើនសេដ្ឋកិច្ច។ ទ្រឹស្តីកំណើនបែបបុរាណ គឺជាទ្រឹស្តីសេដ្ឋកិច្ចដែលរក្សាថាការកើនឡើងនៃកំណើនប្រជាជននាំទៅរកការថយចុះនៃកំណើនសេដ្ឋកិច្ច (Gardon, 2022)។ យោងតាមទ្រឹស្តីនេះ កំណើនសេដ្ឋកិច្ចនឹងឈប់នៅពេលដែលមានការកើនឡើងនៃចំនួនប្រជាជន នេះគឺដោយសារតែនៅពេលដែលចំនួនប្រជាជនកើនឡើង ធនធានមានកម្រិត ដែលបណ្តាលឱ្យមានការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ច។ អ្នកគាំទ្រទ្រឹស្តីនេះជឿថាការផ្ទុះ ឬការកើនឡើងចំនួនប្រជាជនគឺបណ្តាលមកពីការកើនឡើងបណ្តោះអាសន្ននៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសមួយ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលមានការផ្ទុះឡើងនៃចំនួនប្រជាជន វាមានតម្រូវការខ្ពស់ និងធនធានមានកម្រិត ដែលនាំឱ្យចុងបញ្ចប់នៃកំណើនសេដ្ឋកិច្ច។ តួយ៉ាង នៅសម័យដើម មានដីគ្រប់គ្រាន់សម្រាប់គ្រួសារ ជាកន្លែងដែលពួកគេធ្វើការ និងទទួលបានជីវភាព។ នៅចំណុចខ្លះ ដីល្អ និងផលិតភាពទាំងអស់ត្រូវបានកាន់កាប់ ហើយនៅពេលដែលចំនួនប្រជាជនកើនឡើង ដីដែលមានតម្រូវឱ្យមានការខិតខំប្រឹងប្រែងបន្ថែមទៀត និងបង្កើតផលបានតិចតួច។ ដីបានក្លាយជាដែនកំណត់សម្រាប់ចំនួនប្រជាជន ហើយផលិតភាពធ្លាក់ចុះ។

**១.១.២.២ ទ្រឹស្តីសម័យថ្មី**

Robert Solow និង Trevor Swan បានបង្កើតទ្រឹស្តីកំណើន neoclassical ទ្រឹស្តីនេះជួនកាលត្រូវបានគេហៅថា Solow-Swan model ។ ចាប់ពីឆ្នាំ 1956 ទ្រឹស្តីកំណើននេះ គឺជាគំរូសម្រាប់កំណើនសេដ្ឋកិច្ចរយៈពេលវែង។ ទ្រឹស្តីកំណើន neoclassical គឺជាទ្រឹស្តីមួយដែលរក្សាបាននូវដើមទុន កម្លាំងពលកម្ម និងបច្ចេកវិជ្ជាដែលបានកែសម្រួលយ៉ាងល្អមានសារៈសំខាន់សម្រាប់កំណើនសេដ្ឋកិច្ចដែលមានស្ថិរភាព។ ដើម្បីឱ្យវាកើតឡើង លំនឹងបណ្តោះអាសន្នគឺត្រូវបានទាមទារ ពោលគឺដើម្បីឱ្យសេដ្ឋកិច្ចដំណើរការបានគ្រប់គ្រាន់ ទំហំដើមទុនសមាមាត្រ និងកម្លាំងពលកម្មសមស្រប គួបផ្សំនឹងបច្ចេកវិទ្យាត្រូវតែមាន (Gordan, 2022)។ ទ្រឹស្តីនេះក៏បានដាក់សារៈសំខាន់ជាច្រើនលើតួនាទីនៃបច្ចេកវិទ្យាក្នុងការរីកចម្រើននៃសេដ្ឋកិច្ចមួយ។កំណើនសេដ្ឋកិច្ចដែលប្រទេសមួយទទួលបាន និងលំនឹងនៃសេដ្ឋកិច្ចត្រូវបានកំណត់ដោយប្រើទ្រឹស្តីកំណើន neoclassical ។ រូបមន្តសម្រាប់ការប៉ាន់ប្រមាណទ្រឹស្តីកំណើនេះគឺៈ

$$Y = AF(K, L)$$

Y តំណាងឱ្យ GDP របស់ប្រទេសមួយ។ K តំណាងឱ្យចំណែកនៃដើមទុន L គឺជាកម្រិតនៃកម្លាំងពលកម្មគ្មានជំនាញនៅក្នុងសេដ្ឋកិច្ច A តំណាងឱ្យកម្រិតនៃបច្ចេកវិទ្យា។ យោងតាមទ្រឹស្តីនេះ ថ្វីត្បិតតែដើមទុនដែល

ទទួលបានដោយប្រទេសមួយមានសារៈសំខាន់ចំពោះកំណើនសេដ្ឋកិច្ចក៏ដោយ ការរួមបញ្ចូលបច្ចេកវិទ្យា ក៏ដូចជាផលិតភាពការងារក៏មានសារៈសំខាន់ផងដែរក្នុងការសម្រេចបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយស្ថិរភាព។

### ១.១.២.៣ ទ្រឹស្តីកំណើនសេដ្ឋកិច្ចថ្មី

ទ្រឹស្តី endogenous គឺជាទ្រឹស្តីហិរញ្ញវត្ថុដែលអះអាងថា កំណើនហិរញ្ញវត្ថុ ឬសេដ្ឋកិច្ចត្រូវបានបង្កើតចេញពីដំណើរការផ្ទៃក្នុង (ជាជាងខាងក្រៅ) និងធាតុចូល។ ទ្រឹស្តីកត់សំគាល់ថាផលិតភាពអាចត្រូវបានកែលម្អដោយប្រសិទ្ធភាពនៃកម្លាំងពលកម្មជំនាញ និងដោយប្រើបច្ចេកវិទ្យាត្រឹមត្រូវ។ ទ្រឹស្តីកំណើន Endogenous ផ្ទុយទៅនឹងទ្រឹស្តីសេដ្ឋកិច្ច neoclassical ដែលអះអាងថា ការអភិវឌ្ឍន៍បច្ចេកវិទ្យា និងធាតុខាងក្រៅផ្សេងទៀតគឺជាប្រភពចម្បងនៃកំណើនរូបិយវត្ថុ និងសេដ្ឋកិច្ច។ គួរកត់សំគាល់បំផុត សេដ្ឋវិទូដែលមានការលូតលាស់មិនច្បាស់លាស់ជឿថាការកែលម្អផលិតភាពអាចភ្ជាប់ដោយផ្ទាល់ទៅនឹងការច្នៃប្រឌិតលឿនជាងមុន និងការវិនិយោគកាន់តែច្រើននៅក្នុងធនធានមនុស្ស។ ពួកគេផ្តោតលើផលប៉ះពាល់នៃការផ្តល់នូវវិធីសាស្ត្របណ្តុះបណ្តាលកាន់តែប្រសើរឡើង ការស្រាវជ្រាវ និងការអភិវឌ្ឍន៍ និងវិធីផលិតភាពច្នៃប្រឌិតបន្ថែមទៀត។ ដូច្នេះ ប្រសិនបើក្រុមហ៊ុនចង់សម្រេចបាននូវកំណើនប្រកបដោយនិរន្តរភាពនោះ ចាំបាច់ត្រូវវិនិយោគលើធាតុចូលដែលមិនមានប្រភពច្បាស់លាស់ ដូចជា ធនធានមនុស្ស ការស្រាវជ្រាវ បច្ចេកវិទ្យាច្នៃប្រឌិត និងកត្តា endogenous ផ្សេងទៀត។សូមរំលឹកថា វាគឺជាឥទ្ធិពលនៃការថយចុះនៃប្រាក់ចំណូលនៅក្នុងគំរូកំណើន neoclassical ដែលកំណត់ការពង្រីកទិន្នផល និងកំណើនសេដ្ឋកិច្ច។

ដើម្បីជម្នះការរឹតត្បិតនេះចំពោះកំណើនសេដ្ឋកិច្ច EGM ជំរុញឱ្យមានការបង្កើនប្រាក់ចំណូលឡើងវិញ។ មុខងារផលិតកម្ម Cobb Douglas បុរាណបង្ហាញការវិលត្រឡប់មកវិញថេរដើម្បីមាត្រដ្ឋានទៅធាតុបញ្ចូលកត្តា។ នេះមិនទុករង្វាន់ឬការលើកទឹកចិត្តសម្រាប់ភ្នាក់ងារសេដ្ឋកិច្ចឱ្យចូលរួមក្នុងសកម្មភាពដែលជំរុញឱ្យមានការរីកចម្រើនផ្នែកបច្ចេកវិទ្យា។ ដូច្នេះទ្រឹស្តីណាមួយដែលធ្វើអោយវឌ្ឍនភាពបច្ចេកវិទ្យាមិនអាចផ្អែកលើលំនឹងប្រកួតប្រជែងដែលកត្តាត្រូវបានផ្តល់រង្វាន់ដោយយោងទៅតាមផលិតផលរឹមរបស់ពួកគេ។ សម្រាប់ភាពសាមញ្ញ និងការយល់ដឹងកាន់តែច្បាស់ ក្រដាសនេះនឹងរៀបរាប់លម្អិតលើ 3 (បី) នៃគំរូការលូតលាស់របស់ endogenous ទូទៅបំផុត (Onyimadu, 2015):

- គំរូ AK
- គំរូផលិតផលចម្រុះ
- គំរូកំណើន Schumpeterian។

### ១.១.២.៤ ទ្រឹស្តីកំណើនបង្រួបបង្រួម

បង្កើតឡើងដោយ Oded Galor និងសហអ្នកនិពន្ធរបស់គាត់ដើម្បីដោះស្រាយ ដើម្បីពន្យល់ពីភាពទៀងទាត់ជាក់ស្តែងសំខាន់ៗនៅក្នុងដំណើរការរីកចម្រើននៃសេដ្ឋកិច្ចបុគ្គល និងសេដ្ឋកិច្ចពិភពលោកទាំងមូល។ ទ្រឹស្តីកំណើនបង្រួបបង្រួម ស្វែងយល់ពីអន្តរកម្មរវាងការវិវត្តន៍នៃសមាសភាពនៃចរិតមនុស្ស និងដំណើរការលូត

លាស់។ ជាពិសេស វាជំរុញឱ្យមានសម្មតិកម្មដែលថា កម្លាំងវិវត្តន៍មានតួនាទីយ៉ាងសំខាន់ក្នុងការវិវត្តន៍នៃសេដ្ឋកិច្ចពិភពលោកពីការជាប់គាំងរហូតដល់កំណើន។ (Galor, 2005)ទ្រឹស្តីកំណើនបង្រួបបង្រួម ព្យាយាមបញ្ចូលគ្នានូវធាតុផ្សំផ្សេងៗគ្នាជាច្រើននៃកំណើនសេដ្ឋកិច្ច៖

- ភាពជាប់គាំងផ្នែកសេដ្ឋកិច្ច ដែលកំណត់លក្ខណៈភាគច្រើននៃប្រវត្តិសាស្ត្រ របស់មនុស្សជាតិរហូតដល់សតវត្សទីដប់ប្រាំបី។
- បដិវត្តន៍ឧស្សាហកម្មដំបូង និងការចាប់ផ្តើមនៃកំណើនសេដ្ឋកិច្ច។
- តួនាទីនៃការបង្កើតមូលធនមនុស្សក្នុងកំណើនសេដ្ឋកិច្ច។
- ពន្យល់ពីភាពខុសគ្នានៃកំណើនសេដ្ឋកិច្ចនៅទូទាំងប្រទេស។

### ១.១.៣ ការវាស់កំណើនសេដ្ឋកិច្ច

កំណើនសេដ្ឋកិច្ចត្រូវបានវាស់វែង ជាភាគរយនៃការកើនឡើងនៃផលិតផលក្នុងស្រុកសរុប (GDP) ដែលជាផលិតផលក្នុងស្រុកសរុប (GDP) ដែលត្រូវបានកែសម្រួលសម្រាប់អតិផរណា។ តម្លៃទីផ្សារនៃទំនិញ និងសេវាកម្មចុងក្រោយទាំងអស់ ដែលផលិតនៅក្នុងប្រទេស ឬសេដ្ឋកិច្ចត្រូវបានគេហៅថា GDP ។ អ្នកប្រវត្តិសាស្ត្រសេដ្ឋកិច្ចបានព្យាយាមបង្កើតទ្រឹស្តីនៃដំណាក់កាល ដែលសេដ្ឋកិច្ចនីមួយៗត្រូវឆ្លងកាត់នៅពេលវាអភិវឌ្ឍ។ ដើម្បីពន្យល់ពីវឌ្ឍនភាព ពីដំណាក់កាលមួយទៅ ដំណាក់កាលបន្ទាប់ទ្រឹស្តីផ្សេងៗត្រូវបានស្នើឡើង។

អ្នកសេដ្ឋកិច្ចប្រើវិធីសាស្ត្រជាច្រើន ដើម្បីកំណត់ថាតើសេដ្ឋកិច្ចរីកចម្រើនលឿនប៉ុណ្ណា។ ផលិតផលក្នុងស្រុកសរុបពិតប្រាកដ ឬ GDP ពិតប្រាកដ គឺជាមធ្យោបាយសាមញ្ញបំផុតក្នុងការវាស់វែងសេដ្ឋកិច្ច។ GDP គឺជាតម្លៃសរុបនៃអ្វីគ្រប់យ៉ាងដែលផលិតនៅក្នុងសេដ្ឋកិច្ចរបស់យើង រួមទាំងទំនិញ និងសេវាកម្មផងដែរ។ ពាក្យ "ពិតប្រាកដ" បង្ហាញថាចំនួនសរុបត្រូវបានកែតម្រូវក្នុងគណនីឥទ្ធិពលអតិផរណា។

កំណើន GDP ពិតប្រាកដអាចត្រូវបានវាស់វែងយ៉ាងតិចបីវិធីផ្សេងគ្នា។ វាមានសារៈសំខាន់ណាស់ក្នុងការដឹងថាមួយណាត្រូវបានប្រើប្រាស់ និងភាពខុសគ្នារវាងពួកវា។ (Gandhi, 2022) វិធីសាស្ត្រសាមញ្ញបំផុតចំនួនបីសម្រាប់គណនា GDP ពិតប្រាកដគឺ៖

- **វិធីសាស្ត្រចំណូល**៖ ប្រាក់ចំណូលដែលទទួលបានពីការផលិតទំនិញ និងសេវាកម្ម គឺជាចំណុចចាប់ផ្តើមសម្រាប់រូបមន្តវិធីសាស្ត្រចំណូល GDP ។ យើងគណនាប្រាក់ចំណូលដែលរកបានដោយកត្តាទាំងអស់នៃផលិតកម្មនៅក្នុងសេដ្ឋកិច្ចមួយដោយប្រើវិធីសាស្ត្រចំណូល។ ធាតុចូលដែលចូលទៅក្នុងការផលិតផលិតផល ឬសេវាកម្មចុងក្រោយត្រូវបានគេហៅថាជាកត្តានៃផលិតកម្ម។ នៅក្នុងព្រំដែនក្នុងស្រុករបស់ប្រទេសមួយ កត្តាផលិតកម្មសម្រាប់អាជីវកម្មគឺដីធ្លី កម្លាំងពលកម្ម ដើមទុន និងការគ្រប់គ្រង។

GDP (តាមការវាស់តាមចំណូល) = TNI + Sales Taxes, Depreciation + NF (factor income)

- TNI (Total Net Income): ប្រាក់ចំណូលជាតិសរុប គឺជាផលបូកនៃប្រាក់ឈ្នួល ការជួល ការប្រាក់ និងប្រាក់ចំណេញទាំងអស់នៅក្នុងប្រទេស។
- Sales Taxes: ពន្ធលើការលក់ត្រូវបានបង់ដោយរដ្ឋាភិបាលលើការទិញទំនិញ និងសេវាកម្ម។
- Depreciation ការរំលោះគឺជាចំនួនទឹកប្រាក់ដែលត្រូវបានសន្មតថាជាទ្រព្យសកម្មដោយផ្អែកលើរយៈពេលដែលវានឹងត្រូវបានប្រើប្រាស់។
- NF (Net Foreign factor income): ប្រាក់ចំណូលកត្តាបរទេសសុទ្ធ គឺជាភាពខុសគ្នារវាងប្រាក់ចំណូលសរុបដែលបង្កើតដោយពលរដ្ឋ និងក្រុមហ៊ុននៅក្រៅប្រទេសដើមរបស់ពួកគេ និងប្រាក់ចំណូលសរុបដែលបង្កើតដោយពលរដ្ឋបរទេស និងក្រុមហ៊ុននៅក្នុងប្រទេសនោះ។

- **វិធីសាស្ត្រចំណាយ៖** វិធីសាស្ត្រទីពីរ ដែលគេស្គាល់ថាជាវិធីសាស្ត្រចំណាយ គឺផ្ទុយពីវិធីសាស្ត្រនៃប្រាក់ចំណូល ព្រោះវាចាប់ផ្តើមដោយប្រាក់ចំណាយលើទំនិញ និងសេវាកម្ម ជាជាងចំណូល។ ម៉ែត្រនេះវាស់ចំនួនសរុបដែលបានចំណាយលើទំនិញ និងសេវាកម្មដោយអង្គភាពទាំងអស់នៅក្នុងព្រំដែនក្នុងស្រុករបស់ប្រទេសមួយ។

តោះមើលរបៀបគណនា GDP ដោយប្រើវិធីសាស្ត្រចំណាយ៖

GDP (Expenditure approach) = C + I + G + (EX-IM)

- C: Consumer Expenditure ដែលសំដៅទៅលើពេលដែលមនុស្សចំណាយលើទំនិញ និងសេវាកម្មផ្សេងៗ។ ឧទាហរណ៍ អាហារ ហ្គាស និងឡាន។
- I: Investment Expenditure ដែលសំដៅលើពេលដែលអាជីវកម្មចំណាយលុយដើម្បីវិនិយោគក្នុងប្រតិបត្តិការរបស់ពួកគេ។ ឧទាហរណ៍ ការទិញដី គ្រឿងចក្រ និងរបស់របរផ្សេងៗទៀត។
- G: Government Expenditure ដែលសំដៅលើចំនួនថវិកាដែលរដ្ឋាភិបាលចំណាយលើគម្រោងអភិវឌ្ឍន៍ផ្សេងៗ។
- (EX-IM): ការនាំចេញដកការនាំចូល ឬការនាំចេញសុទ្ធ។ ឧ. យើងគណនា GDP ដោយរាប់បញ្ចូលការនាំចេញទៅកាន់ប្រទេសផ្សេងទៀត និងដកការនាំចូលពីប្រទេសផ្សេងទៀតមកប្រទេសរបស់យើង។

- **វិធីសាស្ត្រទិន្នផល៖** តម្លៃប្រិយវត្ថុ ឬទីផ្សារនៃទំនិញ និងសេវាកម្មទាំងអស់ដែលផលិតក្នុងព្រំដែនរបស់ប្រទេសមួយត្រូវបានគណនាដោយប្រើវិធីសាស្ត្រទិន្នផល GDP ។ GDP នៅតម្លៃថេរ ឬ Real

GDP ត្រូវបានគណនាដើម្បីជៀសវាងការបង្ខូចទ្រង់ទ្រាយនៃផលិតផលក្នុងស្រុកសរុប ដោយសារការផ្លាស់ប្តូរកម្រិតតម្លៃ។

GDP ត្រូវបានគណនាដោយប្រើវិធីសាស្ត្រទិន្នផលដោយប្រើរូបមន្តខាងក្រោម៖

GDP (as per output method) = Real GDP (GDP at constant prices) – Taxes + Subsidies

- Real GDP (GDP at constant prices): GDP ពិតប្រាកដ (GDP នៅតម្លៃថេរ)
- Taxes: ពន្ធ
- Subsidies: ប្រាក់ឧបត្ថម្ភ
- GDP (as per output method): GDP (តាមវិធីសាស្ត្រទិន្នផល) ។

## ១.២ ទស្សនៈទាននអំពីវិស័យឧស្សាហកម្មលើកំណើនសេដ្ឋកិច្ច

ទំនាក់ទំនងរវាងឧស្សាហកម្ម និងកំណើនសេដ្ឋកិច្ចជាទូទៅ មាននៅទូទាំងប្រទេស និងកម្រិតប្រាក់ចំណូល។ ទិន្នន័យអន្តរជាតិបញ្ជាក់ថា សមាមាត្រនៃការផលិតនៅក្នុងសេដ្ឋកិច្ចកើនឡើង នៅពេលដែលផលិតផលក្នុងស្រុកសរុប (GDP) កើនឡើងសម្រាប់ប្រទេសដែលមានចំណូលមធ្យមកម្រិតទាប មធ្យមទាប និងមធ្យមកម្រិតខ្ពស់។ ការជាប់ទាក់ទងគ្នានេះកើតឡើងវិញនៅពេលដែលប្រទេសមួយក្លាយជាសេដ្ឋកិច្ចដែលមានប្រាក់ចំណូលខ្ពស់ ដែលសេវាកម្មចាប់ផ្តើមទទួលបានចំណែកខ្ពស់ជាងការផលិត។ នេះគឺដោយសារតែការផលិតផ្តល់នូវអត្ថប្រយោជន៍ផលិតភាពជាច្រើន។ (Yong, 2021)ទីមួយ ការផលិតទ្រង់ទ្រាយធំរួមបញ្ចូលនូវសេដ្ឋកិច្ចនៃមាត្រដ្ឋាន៖ ការផលិតឯកតាកាន់តែច្រើន ថ្លៃដើមក្នុងមួយឯកតាកាន់តែទាប ហើយដោយហេតុនេះការបង្កើនតម្លៃនៃទិន្នផលក្នុងមួយធាតុចូល។ ទីពីរ ការផលិតមានទំនោរមានទំនាក់ទំនងយ៉ាងរឹងមាំទៅនឹងផ្នែកផ្សេងទៀតនៃសេដ្ឋកិច្ច បង្កើតតម្រូវការជំនាញ ធាតុចូល សមាសធាតុផលិតកម្ម ការដឹកជញ្ជូន និងការផ្ទុក។ នេះមានន័យថា កំណើនក្នុងវិស័យផលិតកម្មជំរុញឱ្យមានកំណើនពេញមួយសំណុំសកម្មភាពដ៏ទូលំទូលាយ រួមទាំងក្នុងវិស័យសេវាកម្មផងដែរ។ ទីបី ការច្នៃប្រឌិត និងភាពជឿនលឿនផ្នែកបច្ចេកវិទ្យាភាគច្រើនមានប្រភពចេញពីវិស័យផលិតកម្ម ដែលបន្ទាប់មកអាចបញ្ចូលទៅក្នុងវិស័យសេដ្ឋកិច្ចផ្សេងទៀត ដែលធ្វើឲ្យពួកគេមានផលិតភាពកាន់តែច្រើនផងដែរ។

នេះជាភ័ស្តុតាងច្បាស់លាស់ដែលថាវិស័យផលិតកម្មដែលរីកចម្រើនគឺជាគន្លឹះក្នុងការបង្កើនផលិតភាព ហើយដូច្នេះកំណើនសេដ្ឋកិច្ច។ ការមកដល់នៃវិស័យផលិតកម្មនៅសតវត្សទីដប់ប្រាំបី និងទីដប់ប្រាំបួនបានបដិវត្តចនាសម្ព័ន្ធផលិតភាពនៃទ្វីបអឺរ៉ុប និងសហរដ្ឋអាមេរិក ហើយឧស្សាហូបនីយកម្មគឺជាកម្លាំងជំរុញនៅពីក្រោយអព្ភូតហេតុសេដ្ឋកិច្ចថ្មីៗបន្ថែមទៀត ដូចជាការផ្លាស់ប្តូរសេដ្ឋកិច្ចអាស៊ីបូព៌ាតាំងពីទសវត្សរ៍ឆ្នាំ 1960 ជាដើម។

ចំពោះប្រទេសកម្ពុជាជាតំបន់ធ្វើកសិកម្មនៅសហវត្សទីមួយ និងទីពីរមុនគ.ស។ រដ្ឋក្នុងតំបន់នេះធ្វើពាណិជ្ជកម្មនៅមហាសមុទ្រឥណ្ឌា និងនាំចេញលើសអង្ករ។ ប្រព័ន្ធធារាសាស្ត្រស្មុគស្មាញត្រូវបានសាងសង់នៅ

សតវត្សទី ១ ។ សម័យអាណានិគមបារាំងបានបន្សល់ទុកដីសក្តិភូមិដ៏ធំនៅដដែល។ ផ្លូវថ្នល់ និងផ្លូវដែកត្រូវបានសាងសង់ ហើយកៅស៊ូ ស្រូវ និងពោតបានដាំដុះ។ ក្រោយឯករាជ្យ ព្រះសីហនុបានបន្តគោលនយោបាយឯករាជ្យសេដ្ឋកិច្ច ដោយធានាបាននូវជំនួយ និងការវិនិយោគពីប្រទេសមួយចំនួន។បន្ទាប់ពីការបរាជ័យនៃរបបខ្មែរក្រហម ផែនការប្រាំឆ្នាំត្រូវបានអនុម័តក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវវិស័យកសិកម្ម ឧស្សាហកម្ម និងការចែកចាយ ដោយមានពាក្យស្លោកថា "ការនាំចេញ និងសន្សំសំចៃ" ។ សព្វថ្ងៃនេះ ប្រទេសកម្ពុជានៅតែជាសេដ្ឋកិច្ចកសិកម្មដ៏ច្រើន ហើយការអភិវឌ្ឍន៍ឧស្សាហកម្មមានភាពយឺតយ៉ាវ។ ដូចនេះដើម្បីអោយប្រទេសរីកចម្រើន វិស័យឧស្សាហកម្មនៅកម្ពុជាក៏ត្រូវមានការវិវត្តន៍ ដើម្បីជម្រុញកំណើនសេដ្ឋកិច្ចកម្ពុជា។ ខាងក្រោមនេះនឹងធ្វើការបកស្រាយ ទំនាក់ទំនងរវាងឧស្សាហកម្ម និងកំណើនសេដ្ឋកិច្ច ដោយយោងតាមការវាស់កំណើនសេដ្ឋកិច្ចតាមវិធីសាស្ត្រចំណាយ៖

GDP = C + I + G + (EX-IM)

តាមរយៈសមីការខាងលើនេះ អាចសង្កេតបានថាកត្តាទាំង៤នេះសុទ្ធតែសំខាន់សម្រាប់សេដ្ឋកិច្ចនៃប្រទេសនីមួយ ព្រោះគេអាចបែងចែក វាយតម្លៃជាប្រទេសអភិវឌ្ឍន៍ ឬប្រទេសកំពុងអភិវឌ្ឍន៍ គឺត្រូវយកទិន្នន័យទាំង៤មកធ្វើការវិភាគដើម្បីវាស់សេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ។ ដូចនេះកត្តាទាំង៤នេះគឺមានឥទ្ធិពលមកលើសេដ្ឋកិច្ចគ្រប់ប្រទេសទាំងអស់។ ប៉ុន្តែចំពោះទំហំនៃឥទ្ធិពលគឺមានភាពខុសគ្នារវាងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ដោយសារតែស្ថានភាពសេដ្ឋកិច្ចមានភាពខុសគ្នា។

- **កត្តាការប្រើប្រាស់**(C)៖ ការប្រើប្រាស់គឺជាគំនិតធំមួយនៅក្នុងសេដ្ឋកិច្ច ហើយមានសារៈសំខាន់ខ្លាំងណាស់ព្រោះវាជួយកំណត់កំណើន និងភាពជោគជ័យនៃសេដ្ឋកិច្ច។ អាជីវកម្មអាចបើកចំហរ និងផ្តល់ជូននូវផលិតផលល្អៗគ្រប់ប្រភេទ ប៉ុន្តែប្រសិនបើយើងមិនទិញ ឬប្រើប្រាស់ផលិតផលរបស់ពួកគេទេ ពួកគេនឹងមិនអាចបន្តអាជីវកម្មបានយូរនោះទេ។ ប៉ុន្តែនៅប្រទេសកម្ពុជាជាប្រទេសនៅមានចំណូលទាបនៅឡើយ ដោយជាប្រទេសមានតម្លៃពលកម្មទាប ព្រោះមូលធននៅមានកម្រិតចំពោះចំនេះជំនាញនានា។ ដូចនេះការចំណាយរបស់ប្រជាជនក៏ទៅតាមកម្រិតននៃប្រាក់ចំណូលដែលទទួលបានផងដែរ។
- **ការចំណាយរបស់រាជរដ្ឋាភិបាល** (G)៖ ការចំណាយរបស់រដ្ឋាភិបាលតំណាងឱ្យការចំណាយលើការប្រើប្រាស់របស់រដ្ឋាភិបាល និងការវិនិយោគសរុប។ រដ្ឋាភិបាលចំណាយប្រាក់លើឧបករណ៍ ហេដ្ឋារចនាសម្ព័ន្ធ និងប្រាក់បៀវត្ស។ ការចំណាយរបស់រដ្ឋាភិបាលអាចកាន់តែមានសារៈសំខាន់ទាក់ទងទៅនឹងសមាសធាតុផ្សេងទៀតនៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសមួយ នៅពេលដែលការចំណាយរបស់អ្នកប្រើប្រាស់ និងការវិនិយោគអាជីវកម្មទាំងពីរធ្លាក់ចុះយ៉ាងខ្លាំង។ (ឧទាហរណ៍នេះអាចកើតឡើងនៅពេលមានវិបត្តិសេដ្ឋកិច្ច។ )។ ដូចដែលដឹងថាប្រទេសកម្ពុជានៅជាប្រទេសមានប្រាក់ចំណូលទាប ដូចនេះថវិការសម្រាប់ចំណាយរបស់រាជរដ្ឋាភិបាលកម្ពុជានៅមានកម្រិតនៅឡើយ ដោយ

កំឡុងពេល១០ឆ្នាំនេះ(២០១០-២០១៩) ការចំណាយរបស់រាជរដ្ឋាភិបាលមានជាមធ្យម ២០% ប៉ុណ្ណោះនៃផលិតផលសរុបក្នុងស្រុក។

- **ប្រាក់ចំណូលជាតិ** (**ការនាំចេញ-ការនាំចូល**)៖ ការនាំចេញរបស់កម្ពុជាត្រូវបានគ្របដណ្តប់ដោយទំនិញវាយនភណ្ឌដែលមានប្រហែល 70 ភាគរយនៃការនាំចេញសរុប។ ផលិតផលនាំចេញផ្សេងទៀតរួមមាន សម្លៀកបំពាក់ ស្បែកជើង កៅស៊ូធម្មជាតិ និងត្រីជាដើម។ ដៃគូនាំចេញសំខាន់ៗរបស់កម្ពុជា គឺសហរដ្ឋអាមេរិក ហុងកុង សិង្ហបុរី កាណាដា អាល្លឺម៉ង់ និងចក្រភពអង់គ្លេស។ ប៉ុន្តែទំហំនៃការនាំចេញ នៅតូចជាងការនាំចូល ដែលជាហេតុនាំអោយមានឱនភាពផលិតកម្ម។ ដោយប្រទេសកម្ពុជាភាគច្រើននាំចូលផលិតផលប្រេង ក្រណាត់ យានយន្ត អំបោះលក់ដុំ បារី ឧបករណ៍ទំនាក់ទំនងអគ្គិសនី និងថ្នាំពេទ្យ ។ល។ ដៃគូនាំចូលសំខាន់ៗរបស់កម្ពុជាគឺចិន ថៃ ហុងកុង វៀតណាម តៃវ៉ាន់ និងកូរ៉េខាងត្បូង។ នេះបង្ហាញបានការផ្គត់ផ្គង់ផលិតផលនៅតិច ដោយកង្វះបច្ចេកវិទ្យាទំនើប ធនធានជំនាញ និងដៃគូរសហការណ៍ ឬវិនិយោគជាដើម។
- **ការវិនិយោគ** ៖ សំដៅលើការវិនិយោគក្នុងស្រុកឯកជន ឬការចំណាយដើមទុន។ អាជីវកម្មចំណាយប្រាក់ដើម្បីវិនិយោគក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួន ឧទាហរណ៍ អាជីវកម្មអាចទិញគ្រឿងចក្រ។ ការវិនិយោគអាជីវកម្មគឺជាធាតុផ្សំដ៏សំខាន់នៃផលិតផលក្នុងស្រុកសរុប ចាប់តាំងពីវាបង្កើនសមត្ថភាពផលិតភាពនៃសេដ្ឋកិច្ច និងបង្កើនកម្រិតការងារ។ ដោយសារប្រទេសកម្ពុជានៅជាប្រទេសកំពុងអភិវឌ្ឍន៍ ដូចនេះចំនួនអ្នកវិនិយោគតិច និងមូលធនរបស់វិនិយោគិនក្នុងស្រុកនៅមានកម្រិត មិនអាចគាំទ្រឬទិញនៅឧបករណ៏បច្ចេកវិទ្យាទំនើបៗ និងធុនធ្ងន់បានទេ ដូចនេះហើយពួកគេត្រូវរកដៃគូវិនិយោគ ជាពិសេសវិនិយោគិនបរទេស ដើម្បីចូលរួមជាភាគហ៊ុននៃក្រុមហ៊ុនសហគ្រាសរបស់ខ្លួន។

ដោយលំហូរវិនិយោគផ្ទាល់ពីបរទេស (FDI) នៅកម្ពុជាចន្លោះពាក់កណ្តាលឆ្នាំ ១៩៩៤ ដល់ចុងឆ្នាំ ២០២១ មានចំនួន ១៦៨,៨ ពាន់ពាន់លានរៀល (៤១,០ ពាន់លានដុល្លារ) កើនឡើង ១១,២ ភាគរយធៀបនឹងដំណាច់ឆ្នាំ ២០២០ ដោយតំបន់មហាចិននៅតែជាទីផ្សារប្រភពកំពូលរបស់ព្រះរាជាណាចក្រកម្ពុជានេះបើតាមរបាយការណ៍ថ្មី (Phanet, 2022)។ ប្រទេសកម្ពុជាដើមឡើយជាប្រទេសកសិកម្ម ប៉ុន្តែដើម្បីមានការវិវត្តន៍សេដ្ឋកិច្ចមានការរីកចម្រើន ប្រទេសកម្ពុជាក៏ត្រូវវិវត្តន៏ទៅជាប្រទេសឧស្សាហកម្មទំនើបដើម្បីជម្រុញកំណើនសេដ្ឋកិច្ចជាតិ។ មួយចំណែកធំនៃការវិនិយោគិនផ្ទាល់បរទេសនេះ ភាគច្រើនវិនិយោគទៅលើវិស័យឧស្សាហកម្ម នៅកម្ពុជា មានបែងចែកតាមវិស័យ ហិរញ្ញវត្ថុបានឈរនៅលំដាប់កំពូលក្នុងបញ្ជី FDI ដែលមានទឹកប្រាក់ចំនួន 9.4 ពាន់លានដុល្លារបានបណ្តាក់ទុននៅក្នុងតំបន់ បន្ទាប់មកដោយសហគ្រាស (8.5 ពាន់លានដុល្លារ) អចលនទ្រព្យ (4.9 ពាន់លានដុល្លារ) សណ្ឋាគារ និងភោជនីយដ្ឋាន (4.4 ពាន់លានដុល្លារ) កសិកម្ម (4.2 ពាន់លានដុល្លារ) អគ្គិសនី (2.6 ពាន់លានដុល្លារ) និងសំណង់ (1.6 ពាន់លានដុល្លារ) ជាមួយនឹង 5.3 ពាន់លានដុល្លារនឹងចូលទៅក្នុងវិស័យផ្សេងទៀត។

នេះជាភស្តុតាងមួយដែលអាចបញ្ជាក់បានថា វិនិយោគិនផ្ទាល់បរទេស ពិតជាមានសារៈសំខាន់ចំពោះវិស័យឧស្សាហកម្ម ដោយសារតែលំហូរមូលធនបរទេសមួយភាគធំ គឺវិនិយោគទៅលើឧស្សាហកម្មស្ទើរទាំងអស់ ហើយឧស្សាហកម្មជាមួយផ្នែកធំនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ ដោយមានតួនាទីជួយ បង្កើនឱកាសការងារ បង្កើនដើមទុន លំហូរចូលបច្ចេកវិទ្យាទំនើប ទំនើបកម្មនៃកសិកម្មបង្កើនផលិតផលក្នុងស្រុក និងជាវិស័យមួយដែលគាំទ្រវិស័យកសិកម្ម វិស័យការពារជាតិ និងវិស័យសេដ្ឋកិច្ចផ្សេងៗទៀត។

## ១.៣ វិស័យឧស្សាហកម្ម

ឧស្សាហកម្មគឺជា សកម្មភាពជាមូលដ្ឋាននៅក្នុងសេដ្ឋកិច្ច នៃប្រទេសណាមួយ ហើយវាទទួលខុសត្រូវចំពោះការកែច្នៃ និងការផ្លាស់ប្តូរផលិតផលធម្មជាតិ (វត្ថុធាតុដើម) ទៅជាផលិតផលសម្រេច និងពាក់កណ្តាលសម្រេចផ្សេងទៀត។ ឧស្សាហកម្មទំនើបបានចាប់ផ្តើម ជាមួយនឹងបដិវត្តន៍ឧស្សាហកម្មដែលបានកើតឡើងនៅក្នុងប្រទេសអង់គ្លេសក្នុងសតវត្សទី៨;វាគឺជាការអរគុណចំពោះការបង្កើតម៉ាស៊ីនថ្មី ដែលបំពេញភារកិច្ចដែលបានអនុវត្តពីមុន ដោយមនុស្សប្រកបដោយប្រសិទ្ធភាពជាងមុន។ សារៈសំខាន់នៃឧស្សាហកម្មមិនអាចបដិសេធបានទេ វាគឺជាការរីកចម្រើនបន្តិចម្តងៗ និងការពង្រីកឧស្សាហកម្ម ដែលនាំទៅដល់ការបង្កើត និងពង្រីកវិស័យផ្សេងទៀត ដែលឥឡូវនេះជាផ្នែកនៃសង្គមទំនើប ដូចជាធនាគារ ផលិតកម្មឧស្សាហកម្មក្នុងទ្រង់ទ្រាយធំ ការប្រមូលផ្តុំដើមទុន ការបែងចែកកម្លាំងពលកម្ម ការបង្កើនផលិតភាព ការច្នៃប្រឌិតថ្មី បច្ចេកវិទ្យា។ល។

ជាក់ស្តែង វិស័យឧស្សាហកម្មនៅកម្ពុជា (លើកលែង ឧស្សាហកម្មនិស្សារណកម្ម និងការរុករករ៉ែ) ភាគច្រើនសំដៅលើ វិស័យកាត់ដេរ កសិ-ឧស្សាហកម្ម សំណង់ និងទេសចរណ៍។ រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ទិសដៅក្នុងការប្រែក្លាយប្រទេសកម្ពុជា ឲ្យក្លាយទៅជាប្រទេស ដែលមាន ប្រាក់ចំណូលមធ្យមក្នុងឆ្នាំ២០៣០ និងមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០ ដូចបានកំណត់ក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨។ ទិសដៅនេះ បញ្ជាក់ពីតួនាទីនៃវិស័យឧស្សាហកម្ម និងសហគ្រាសធុនតូច និងមធ្យម ដែលជាកត្តាជំរុញដ៏សំខាន់ ចំពោះកំណើននាពេលអនាគត។ កាលពីខែមីនា ឆ្នាំ២០១៥ រដ្ឋាភិបាល បានរៀបចំ និងអនុម័ត គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ដែលជាមគ្គុទេសក៍មួយ ដើម្បីផ្តល់នូវដំណោះស្រាយជាលក្ខណៈប្រព័ន្ធក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្មឱ្យមានភាពប្រកួតប្រជែង នៅក្នុងប្រទេស កម្ពុជា។ វិស័យឧស្សាហកម្មចំបងៗរួមមាន វិស័យកាត់ដេរ និងវិស័យសិប្បកម្មកែច្នៃម្ហូបអាហារ (កសិ-ឧស្សាហកម្ម) វិស័យសំណង់និងអចលនទ្រព្យ និងវិស័យទេសចរណ៍(ឧស្សាហកម្មគ្មានផ្សែង) ព្រមទាំងវិស័យរុករករ៉ែ និងការរុករកផ្សេងៗទៀត ដែលកំពុងកើតមាន។

### ១.៣.១ និយមន័យឧស្សាហកម្ម

ឧស្សាហកម្ម សំដៅលើសកម្មភាពសេដ្ឋកិច្ចដែលពាក់ព័ន្ធនឹងការផលិតទំនិញ ការទាញយករ៉ែ ឬការផ្តល់សេវាកម្ម។ឧស្សាហកម្មគឺជាក្រុមនៃក្រុមហ៊ុនដែលពាក់ព័ន្ធដោយផ្អែកលើសកម្មភាពអាជីវកម្មចម្បងរបស់ពួកគេ។ នៅក្នុងសេដ្ឋកិច្ចទំនើប មានការចាត់ថ្នាក់ឧស្សាហកម្មរាប់សិប។ ចំណាត់ថ្នាក់ឧស្សាហកម្មជាធម្មតាត្រូវ

បានដាក់ជាក្រុមទៅជាប្រភេទធំជាងដែលហៅថាវិស័យ។ ក្រុមហ៊ុនបុគ្គលជាទូទៅត្រូវបានចាត់ថ្នាក់ទៅជាឧស្សាហកម្មដោយផ្អែកលើប្រភពចំណូលធំបំផុតរបស់ពួកគេ។ ជាឧទាហរណ៍ ខណៈពេលដែលក្រុមហ៊ុនផលិតរថយន្តអាចមានផ្នែកហិរញ្ញប្បទានដែលរួមចំណែក 10% ដល់ប្រាក់ចំណូលសរុបរបស់ក្រុមហ៊ុនក្រុមហ៊ុននឹងត្រូវបានចាត់ថ្នាក់នៅក្នុងឧស្សាហកម្មផលិតរថយន្តដោយប្រព័ន្ធចាត់ថ្នាក់ភាគច្រើន។ ក្រុមហ៊ុនស្រដៀងគ្នានេះត្រូវបានដាក់ជាក្រុមរួមគ្នាជាឧស្សាហកម្ម ហើយមានឧស្សាហកម្មផ្សេងៗគ្នាជាច្រើនដូចជា ហាងលក់ទំនិញ និងក្រុមហ៊ុនផលិតស្បែកជើង។ ការដាក់ជាក្រុមឧស្សាហកម្មគឺផ្អែកលើផលិតផលចម្បងដែលក្រុមហ៊ុនបង្កើត ឬលក់។ ទន្ទឹមនឹងនេះ ឧស្សាហកម្មត្រូវបានប្រមូលផ្តុំគ្នាជាផ្នែក។

**១.៣.២ ទម្រង់នៃឧស្សាហកម្ម**

ឧស្សាហកម្មត្រូវបានចាត់ថ្នាក់លើមូលដ្ឋាននៃវត្ថុធាតុដើម ទំហំ និងកម្មសិទ្ធិ៖

**១.៣.២.១ ឧស្សាហកម្មផ្អែកលើវត្ថុធាតុដើម**

ឧស្សាហកម្មផ្អែកលើវត្ថុធាតុដើមមានន័យថា ជាប្រភេទឧស្សាហកម្មដែលប្រើប្រាស់ធនធានដែលខ្លួនមាន មកផលិតជាផលិតផលឬទំនិញផ្សេងៗ ដែលទំនិញទាំងអស់នោះមានឥទ្ធិពលសំខាន់ ជំរុញកំណើនសេដ្ឋកិច្ចជាតិ។ ឧស្សាហកម្មទាំងអស់នោះមាន៖

- ឧស្សាហកម្មដែលមានមូលដ្ឋានលើកសិកម្ម៖ ប្រើប្រាស់ផលិតផលដែលមានមូលដ្ឋានលើរុក្ខជាតិ និងសត្វជាវត្ថុធាតុដើមរបស់ពួកគេ។ ឧទាហរណ៍ដូចជា ការកែច្នៃម្ហូបអាហារ ប្រេងបន្លែ វាយនភ័ណ្ឌកប្បាស ផលិតផលទឹកដោះគោ និងឧស្សាហកម្មស្បែក។
- ឧស្សាហកម្មដែលមានមូលដ្ឋានលើរ៉ែ៖ ឧស្សាហកម្មបឋមប្រើប្រាស់រ៉ែរ៉ែជាវត្ថុធាតុដើម។ ផលិតផលនៃឧស្សាហកម្មទាំងនេះចិញ្ចឹមឧស្សាហកម្មមួយផ្សេងទៀត ផលិតផលមួយគឺដែកផលិតពីរ៉ែដែក ប្រើជាវត្ថុធាតុដើមសម្រាប់ផលិតផលិតផលមួយចំនួនទៀត ដូចជាគ្រឿងចក្រធុនធ្ងន់ សម្ភារសំណង់ និងគ្រូបង្វឹកផ្លូវដែក។
- ឧស្សាហកម្មដែលមានមូលដ្ឋានលើសមុទ្រ៖ ប្រើប្រាស់ផលិតផលពីសមុទ្រ និងមហាសមុទ្រជាវត្ថុធាតុដើម។ ឧទាហរណ៍ដែលបានផ្តល់ឱ្យគឺឧស្សាហកម្មកែច្នៃអាហារសមុទ្រ ឬផលិតប្រេងត្រី។
- ឧស្សាហកម្មដែលមានមូលដ្ឋានលើព្រៃឈើ៖ ប្រើប្រាស់ព្រៃឈើជាវត្ថុធាតុដើម។ ឧស្សាហកម្មដែលពាក់ព័ន្ធជាមួយព្រៃឈើគឺ ម្សៅ និងក្រដាស ឱសថ គ្រឿងសង្ហារឹម និងអគារ។

**១.៣.២.២ ទម្រង់ឧស្សាហកម្មតាមទំហំ**

ទំហំនៃឧស្សាហកម្មត្រូវបានវាស់ដោយចំនួនប្រាក់ដែលត្រូវបានវិនិយោគ ចំនួនបុគ្គលិក និងទំនិញដែលផលិត។ សហគ្រាសខ្នាតតូច មធ្យម និងខ្នាតធំ ក៏ជំរុញផងដែរដល់ការបង្កើតការងារនៅទូទាំងប្រទេស។ សន្ទុះកំណើនចំនួនសហគ្រាសទាំងនេះ ជាហេតុធ្វើឲ្យ ការធ្វើចំណាកស្រុករកការងារទៅកាន់ប្រទេសជិតខាង

និងអត្រាគ្មានការងារបានថយចុះគួរឲ្យកត់សម្គាល់ ដែលជាលទ្ធផលបណ្តាលឲ្យមានការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស។

ដូចគ្នាទៅនឹងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតដែរ សហគ្រាសខ្នាតតូច មធ្យមនិងធំគឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចកម្ពុជា ដែលនេះបានរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការៈ (១) បង្កើតការងារ (២) បង្កើតប្រាក់ចំណូលសម្រាប់ប្រជាជនដែលមានប្រាក់ចំណូលទាប និងប្រជាជនងាយរងគ្រោះ និង (៣) ជំរុញកំណើនសេដ្ឋកិច្ច ស្ថេរភាពសង្គម និងរួមចំណែកដល់ការរីកចម្រើននៃវិស័យឯកជនយ៉ាងខ្លាំង។ របាយការណ៍ស្ថិតិប្រចាំឆ្នាំ២០១៨ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលបច្ចុប្បន្នត្រូវបានប្តូរឈ្មោះមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានបង្ហាញថាសហគ្រាសខ្នាតតូច មធ្យម និងធំដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកដល់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ខណៈដែលវាបានបង្កើតការងារស្មើនឹងចំនួន៧០% នៃការងារសរុប៩៩,៨% នៃចំនួនក្រុមហ៊ុនសរុប និងរួមចំណែក៥៨% នៃផលិតផលក្នុងស្រុកសរុប (GDP)។

ប្រទេសកម្ពុជា ចាត់ថ្នាក់សហគ្រាសជាចំនួន៤ប្រភេទគឺ មីក្រូសហគ្រាស សហគ្រាសខ្នាតតូច ខ្នាតមធ្យម និងសហគ្រាសខ្នាតធំ។

| ចំណាត់ថ្នាក់ | និយមន័យរបស់រដ្ឋាភិបាល | |
|---|---|---|
| | ចំនួននយោជិក (នាក់) | ទ្រព្យសកម្ម (មិនរាប់បញ្ចូលដី និងគិតជាដុល្លារអាមេរិក) |
| មីក្រូសហគ្រាស | <១១ | <៥០ ០០០ |
| សហគ្រាសខ្នាតតូច | ១១ – ៥០ | ៥០ ០០០ - ២៥០ ០០០ |
| សហគ្រាសខ្នាតមធ្យម | ៥១ – ១០០ | ២៥០ ០០០ - ៥០០ ០០០ |
| សហគ្រាសខ្នាតធំ | >១០០ | >៥០០ ០០០ |

ប្រភពៈ ក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម

ផ្អែកលើរបាយការណ៍ប្រចាំឆ្នាំ២០១៧ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានបង្ហាញថាចំនួនសហគ្រាសខ្នាតតូច និងមធ្យម មានចំនួនសរុប ១៥ ៧០៧ និងសហគ្រាសខ្នាតធំមានចំនួនសរុប ១ ៥២២។ ស្របពេលគ្នានេះដែរ មីក្រូសហគ្រាសដែលមាននិយោជិកតិចជាង១០ មានចំនួន ១៣៩ ៩៣៣ នាក់។អ្វីដែលគួរកត់សម្គាល់នោះគឺ កម្លាំងពលកម្មរបស់ស្ត្រីមានចំនួនច្រើនជាងបុរសនៅគ្រប់ប្រភេទ និងទំហំនៃសហគ្រាស ខណៈអាជីវកម្មដែលកាន់កាប់ដោយស្ត្រីមានចំនួនតិចតួចនៅក្នុងវិស័យឧស្សាហកម្ម។

សហគ្រាសខ្នាតតូច និងមធ្យមភាគច្រើនជាវិនិយោគក្នុងស្រុក និងមានលក្ខណៈបម្រើឲ្យការប្រើប្រាស់ក្នុងស្រុក។ ខណៈដែលសហគ្រាសខ្នាតធំ ឬឧស្សាហកម្មធុនធ្ងន់ គឺភាគច្រើនជាប្រភេទវិនិយោគបរទេស ដែលជាទូទៅផ្តោតសំខាន់លើសកម្មភាពនាំចេញ។ ក្រុមហ៊ុនក្នុងវិស័យនាំចេញភាគច្រើនជាសហគ្រាសខ្នាតមធ្យម និងធុនធំ ហើយចូលរួមក្នុងវិស័យវាយនភ័ណ្ឌ សម្លៀកបំពាក់ និងការផលិតស្បែកជើង។ ចំណែកឯមីក្រូសហគ្រាស និងសហគ្រាសខ្នាតតូច ចូលរួមជាចំបងក្នុងវិស័យកែច្នៃអាហារ។ នៅឆ្នាំ ២០១៧ បើបូករួមបញ្ចូលគ្នារវាងមីក្រូសហគ្រាស សហគ្រាសខ្នាតតូច និងមធ្យម សហគ្រាសទាំងអស់នេះបានបង្កើតការងារជាងមួយលានកន្លែង ខណៈដែលសហគ្រាសខ្នាតធំបានបង្កើតការងារជិតមួយលានកន្លែងផងដែរ។

**ចំណែកនៃសហគ្រាសដែលបានចុះបញ្ជីអាជីវកម្មស្របច្បាប់គិតជា (%)**

| ទំហំ/ប្រភេទនៃសហគ្រាស | បានចុះបញ្ជីផ្លូវការ | | | មានតារាងតុល្យការ | | |
|---|---|---|---|---|---|---|
| | ២០១០ | ២០២០ | ២០២៥ | ២០១០ | ២០២០ | ២០២៥ |
| សហគ្រាសខ្នាតតូច | ៣៧ | ៧០ | ៨០ | ៤ | ៣០ | ៥០ |
| សហគ្រាសខ្នាតមធ្យម | ៧២ | ៨០ | ៩០ | ២៤ | ៥០ | ៧០ |
| សហគ្រាសខ្នាតធំ | ៩៣ | ១០០ | ១០០ | ៦៦ | ១០០ | ១០០ |

ប្រភពៈ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥–២០២៥

នៅឆ្នាំ២០១៤ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបានប្រគល់ការទទួលខុសត្រូវសម្រាប់ការចុះបញ្ជីសហគ្រាសខ្នាតតូច និងមធ្យម។នៅឆ្នាំ២០១៨ ចំនួនសហគ្រាសខ្នាតតូច និងមធ្យមដែលបានចុះបញ្ជីសរុបបានកើនឡើងដល់ចំនួន ១៥៥ ៧៤៥។ ក្រសួងឧស្សាហកម្ម និងសិប្បកម្មក៏ប្តេជ្ញាពង្រឹង និងអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម ទាក់ទងនឹងការចុះឈ្មោះឲ្យបានស្របច្បាប់ និងការធ្វើកំណត់ត្រាហិរញ្ញវត្ថុ។ នៅត្រឹមឆ្នាំ២០២៥ សហគ្រាសដែលមានចំនួនស្មើនឹង៨០% និង៩៥% នៃសហគ្រាសទាំងអស់ ត្រូវបានគេរំពឹងថានឹងចុះបញ្ជីផ្លូវការ ហើយខណៈ៥០% និង៧០% នៃសហគ្រាសខ្នាតតូច និងមធ្យម គួរតែមានកំណត់ត្រាប្រវត្តិហិរញ្ញវត្ថុ និងតារាងតុល្យការឲ្យបានត្រឹមត្រូវ។រូបខាងលើបង្ហាញពីចំណែកនៃសហគ្រាសដែលបានចុះបញ្ជីផ្លូវការ ហើយមានកំណត់ត្រាតារាងតុល្យការត្រឹមត្រូវក្នុងឆ្នាំ២០១០ និងការព្យាករសម្រាប់ពេលអនាគត។

**១.៣.២.៣ ឧទ្រមទ់ឧស្សាហកម្មកម្មសិទ្ធិ**

វិស័យឯកជន វិស័យរដ្ឋ ឬវិស័យសាធារណៈ វិស័យរួម និងវិស័យសហករណ៍ គឺជាការចាត់ថ្នាក់នៃឧស្សាហកម្មដោយផ្អែកលើកម្មសិទ្ធិ។

- ឧស្សាហកម្មវិស័យឯកជន គឺគ្រប់គ្រង និងដំណើរការដោយបុគ្គល ឬក្រុមបុគ្គល។
- ឧស្សាហកម្មវិស័យសាធារណៈ គឺគ្រប់គ្រង និងដំណើរការដោយរដ្ឋាភិបាល ដូចជាក្រុមហ៊ុន
- ឧស្សាហកម្មវិស័យរួម ជាកម្មសិទ្ធិ និងដំណើរការដោយរដ្ឋ និងបុគ្គល ឬក្រុមបុគ្គល។

- ឧស្សាហកម្មវិស័យសហករណ៍ គ្រប់គ្រង និងដំណើរការដោយអ្នកផលិត ឬអ្នកផ្គត់ផ្គង់វត្ថុធាតុដើម។

កម្ពុជាបច្ចុប្បន្នមានសហគ្រាសរដ្ឋចំនួន ១៥៖ អគ្គិសនីកម្ពុជា កំពង់ផែស្វយ័តក្រុងព្រះសីហនុ ទូរគមនាគមន៍កម្ពុជា ទីភ្នាក់ងារដឹកជញ្ជូនកម្ពុជា សេវាប្រៃសណីយ៍កម្ពុជា ធនាគារអភិវឌ្ឍន៍ជនបទ ក្រុមហ៊ុន Green Trade ក្រុមហ៊ុនបោះពុម្ព រដ្ឋាករទឹកស្វយ័តក្រុងសៀមរាប សំណង់ និង មន្ទីរពិសោធន៍សាធារណៈ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ កំពង់ផែស្វយ័តភ្នំពេញ ធានារ៉ាប់រងកម្ពុជារ៉េ ធានារ៉ាប់រងអាយុជីវិតកម្ពុជា និងផ្សារមូលបត្រកម្ពុជា។ យោងតាមច្បាប់ស្តីពីស្ថានភាពទូទៅនៃសហគ្រាសសាធារណៈ SOE ពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជាមានពីរប្រភេទគឺ មួយត្រូវបានគ្រប់គ្រងដោយរដ្ឋ 100 ភាគរយ មួយទៀតគឺជាក្រុមហ៊ុនបណ្តាក់ទុនរួមគ្នាដែលដើមទុនភាគច្រើនជារបស់រដ្ឋ។ ហើយមួយភាគតូចត្រូវបានគ្រប់គ្រងដោយអ្នកវិនិយោគឯកជន។

SOE នីមួយៗស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ឬស្ថាប័នរដ្ឋាភិបាល ហើយត្រូវបានត្រួតពិនិត្យដោយក្រុមប្រឹក្សាភិបាលដែលត្រូវបានដកចេញពីក្នុងចំណោមមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល។ សហគ្រាសឯកជនជាទូទៅត្រូវបានអនុញ្ញាតឱ្យប្រកួតប្រជែងជាមួយសហគ្រាសរដ្ឋក្រោមលក្ខខណ្ឌស្មើគ្នា។ SOEs ក៏ស្ថិតក្រោមការយកពន្ធដូចគ្នា និងគោលនយោបាយបញ្ចុះតម្លៃពន្ធលើតម្លៃបន្ថែមដូចសហគ្រាសវិស័យឯកជនដែរ។ SOEs ត្រូវបានគ្របដណ្តប់ក្រោមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដែលត្រូវបានប្រកាសឱ្យប្រើក្នុងខែមករា ឆ្នាំ 2012 ហើយរបាយការណ៍ហិរញ្ញវត្ថុរបស់ពួកគេត្រូវបានធ្វើសវនកម្មដោយក្រសួងសមស្រប ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិ។

## ១.៤ ករណីសិក្សា សិក្សាវិស័យឧស្សាហកម្មជម្រុញកំណើនសេដ្ឋកិច្ចបរទេស

វិស័យឧស្សាហកម្មបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងកំណើនសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ ហើយបានជួយកាត់បន្ថយអត្រាភាពក្រីក្រ និងវិសមភាពទាំងមូលក៏ដូចជាជួយបង្កើននូវប្រាក់ចំនូលដល់សេដ្ឋកិច្ចជាតិផងដែរ។ ទន្ទឹមនឹងនេះបើយើងក្រឡេកមកមើលបណ្តាប្រទេសមួយចំនួនដូចជា៖

### ១.៤.១ ការសិក្សាលើវិស័យឧស្សាហកម្មនៅប្រទេសសិង្ហបុរី

វិស័យផលិតកម្ម និងឧស្សាហកម្មគឺជាផ្នែកមួយដ៏សំខាន់នៃកំណើនសេដ្ឋកិច្ចរបស់ប្រទេសសិង្ហបុរី។ នៅពាក់កណ្តាលទស្សវត្សឆ្នាំ១៩៧០ ប្រទេសនេះមានការអភិវឌ្ឍន៍យ៉ាងច្រើនទៅលើវិស័យឧស្សាហកម្មដោយផ្អែកលើកម្លាំងពលកម្មដែលមានតម្លៃទាប បច្ចេកវិទ្យាកម្រិតទាបដល់កម្រិតមធ្យម និងមានការកើនឡើងយ៉ាងរហ័សនៃការនាំចេញ។ ក្នុងឆ្នាំ១៩៨៨ សិង្ហបុរីមានរោងចក្រផលិតចំនួន៣៦៩៤ដែលមានបុគ្គលិកចំនួន ៣៥២៦០០នាក់។

បន្ទាប់ពីឆ្លងកាត់អស់រយៈពេលជាច្រើនឆ្នាំកន្លងទៅ សិង្ហបុរីមានឧស្សាហកម្មសំខាន់ៗជាច្រើនដូចជា អេឡិចត្រូនិច ការចម្រាញ់ប្រេងកាត វិស័យគីមី វិស្វកម្មមេកានិក និងបច្ចេកទេសជីវវេជ្ជសាស្ត្រ។ សិង្ហបុរីគឺជាមជ្ឈមណ្ឌលចម្រាញ់និងចែកចាយប្រេងដ៏សំខាន់ហើយក៏ជាអ្នកផ្គត់ផ្គង់គ្រឿងបន្លាស់អេឡិចត្រូនិចដ៏សំខាន់ផង

ដែរ និងជាប្រទេសនាំមុខគេខាងគីមីជាពិសេសគីមីឥន្ទនៈ។ នៅឆ្នាំ២០០៥ ឧស្សាហកម្មមានចំនួន៣៣.៦% ដែលទិន្នផលផលិតកម្មបានកើនឡើងដល់១២.៨% និងផ្តល់ការងារដល់ប្រជាពលរដ្ឋចំនួន២០.៥% រហូតមកដល់ឆ្នាំ២០១២ ឧស្សាហកម្មជីវវេជ្ជសាស្ត្ររបស់សិង្ហបុរីមានការកើនឡើងខ្ពស់ជាងគ្រឿងអេឡិចត្រូនិចជាអ្នករួមចំណែកដ៏ធំបំផុតក្នុងការផលិតដែលបង្កើតបាន២៥.៥% ធៀបនឹង២៥%នៃផ្នែកផ្សេងទៀត។

នៅក្នុងត្រីមាសទី១ ឆ្នាំ២០២១ ប្រទេសសិង្ហបុរីសម្រេចបានកំណើនសេដ្ឋកិច្ចរបស់ខ្លួនយ៉ាងគាប់ប្រសើរ។ ពោលគឺចាប់ពីខែមករា ដល់ខែមីនាផលិតផលក្នុងស្រុកសរុបកើនបាន១.៣%ធៀបនឹងត្រីមាសឆ្នាំ២០២០ មានកំណើនតែ០.២%ប៉ុណ្ណោះ។ មូលហេតុចម្បងជាងគេដែលធ្វើឲ្យកំណើនសេដ្ឋកិច្ចសិង្ហបុរីកើនខ្លាំងនៅបីខែដំបូងគឺដោយសារមានការកើនឡើងតម្រូវការនៃការនាំចេញពីសិង្ហបុរី។ ជាក់ស្តែងផលិតផលក្នុងវិស័យឧស្សាហកម្មប្រទេសសិង្ហបុរីកើនឡើងដល់ទៅជិត១១%ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០ រីឯការនាំចេញផលិតផលទូទៅមិនមែនប្រេងកើនឡើងជិត១០%។

បើយោងទៅតាមក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មសិង្ហបុរី តាមរបាយការណ៍សេដ្ឋកិច្ចប្រចាំត្រីមាសទី១ឆ្នាំ២០២១បានឲ្យដឹងថាវិស័យផលិតកម្ម និងឧស្សាហកម្មត្រូវបានគេរំពឹងថានឹងពង្រីកខ្លួនកាន់តែខ្លាំងជាងមុនទៀតដោយសារតែមានតម្រូវការគ្រឿងបង្គុំអេឡិចត្រូនិកសម្រាប់ឧបករណ៍5G និងគ្រឿងបង្គុំរថយន្តមានការកើនឡើង។ប្រទេសសិង្ហបុរីបានបង្ហាញពីគោលដៅជម្រុញវិស័យឧស្សាហកម្មផលិតរបស់ខ្លួនឲ្យកើនឡើងដល់ទៅ៥០%នៅក្នុងរយៈពេល១០ឆ្នាំខាងមុខដើម្បីធានាឲ្យបានថាវិស័យមួយនេះនឹងនៅតែបន្តចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិប្រមាណ២០%ក្នុងរយៈពេលមធ្យម។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មសិង្ហបុរី បានគូសបញ្ជាក់ថាគោលដៅដែលបានកំណត់នេះគឺមិនមែនត្រឹមតែជាតួលេខធម្មតានោះទេ តែជាការបង្កើតគន្លងថ្មីសម្រាប់ការផ្លាស់ប្តូរប្រកបដោយគុណភាព ព្រោះវិស័យឧស្សាហកម្មទំនើបនឹងក្លាយជាចំណែកកាន់តែធំនៅក្នុងសេដ្ឋកិច្ចជាតិ។ លោកពន្យល់ថា កាលពីជំនាន់មុនវិស័យឧស្សាហកម្មផលិត ប្រកួតប្រជែងគ្នាទៅលើតម្លៃតែត្រូវបានជំនួសដោយផលិតផលដែលមានតម្លៃទាបមកពីប្រទេសដទៃ ផ្ទុយទៅវិញការកំណត់គោលដៅលូតលាស់៥០%នៅពេលនេះគឺសិង្ហបុរីចង់រុញច្រានវិស័យឧស្សាហកម្មនេះឲ្យក្លាយទៅជាវិស័យឧស្សាហកម្មទំនើបដែលការប្រកួតប្រជែងមិនមែនស្ថិតនៅលើតម្លៃទៀតនោះទេគឺផ្អែកទៅលើកម្មសិទ្ធិបញ្ញា គុណភាពផលិតផល និងភាពច្បាស់លាស់នៅក្នុងវិស័យនេះ។

យ៉ាងណាមិញ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលសិង្ហបុរីសង្ឃឹមថានឹងអាចទាក់ទាញប្រជាជនសិង្ហបុរីឲ្យចូលមកវិនិយោគក្នុងវិស័យនេះហើយក៏បន្តទាក់ទាញការវិនិយោគសក្តានុពលពីក្រៅប្រទេស និងជម្រុញក្រុមហ៊ុនក្នុងស្រុកឲ្យចូលរួមវិស័យឧស្សាហកម្មទំនើបឲ្យបានកាន់តែច្រើន។ បច្ចុប្បន្នវិស័យឧស្សាហកម្មសិង្ហបុរីមានតម្លៃប្រមាណ៨០ពាន់លានដុល្លារអាមេរិក ឬស្មើនឹង ២១% នៃGDP របស់ប្រទេសសិង្ហបុរីដោយមានបុគ្គលិកជាង៤៥មឺននាក់ និងមានប្រាក់បៀវត្សជាមធ្យមប្រមាណ៣៥០០ដុល្លារអាមេរិក។ (ច័ន្ទតារា, 2021)

## ១.៤.២ ការសិក្សាលើវិស័យឧស្សាហកម្មនៅប្រទេសឥណ្ឌូនេស៊ី

ឥណ្ឌូនេស៊ីត្រូវបានគេមើលឃើញថាជាមហាសេដ្ឋីសេដ្ឋកិច្ចនាពេលអនាគត និងជាសេដ្ឋកិច្ចធំបំផុតនៅអាស៊ីអាគ្នេយ៍។ មិនតែប៉ុណ្ណោះ ឥណ្ឌូនេស៊ីគឺជាសេដ្ឋកិច្ចទីផ្សារដែលមានធនធានធម្មជាតិសម្បូរបែប និងមានប្រជាជនរហូតដល់ទៅ ២៧៧.៧លាននាក់ និងមានកម្លាំងពលកម្ម ១៣៥ លាននាក់នៅឆ្នាំ២០២២។ ប្រទេសនេះបានផ្លាស់ប្តូរពីសេដ្ឋកិច្ចដែលពឹងផ្អែកខ្លាំងលើកសិកម្មទៅជាសេដ្ឋកិច្ចដែលមានតុល្យភាពជាងមុនដែលកាត់បន្ថយការពឹងផ្អែកបែបប្រពៃរបស់ខ្លួនលើការនាំចេញចម្បង។ វិស័យកសិកម្មបានរួមចំណែកដល់ ១៣.៧% នៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេស និងផ្តល់ការងារដល់ ២៧.៧% នៃចំនួនប្រជាជនសកម្មក្នុងឆ្នាំ២០២១។ ឥណ្ឌូនេស៊ីជាប្រទេសផលិតកៅស៊ូធំទីពីរក្នុងពិភពលោក ហើយដំណាំសំខាន់ៗផ្សេងទៀតរួមមានស្រូវ អំពៅ កាហ្វេ តែ ថ្នាំជក់ ដូងប្រេង ដូង និងគ្រឿងទេស។ ក្រៅពីនេះ ប្រទេសនេះជាប្រទេសផលិតនីកែលធំជាងគេលើពិភពលោក ហើយបានក្លាយជាប្រទេសនាំចេញដែកអីណុកដ៏ធំមួយ។ ផ្ទៃដីរបស់ឥណ្ឌូនេស៊ីប្រើសម្រាប់កសិកម្មកំពុងកើនឡើង ហើយបច្ចុប្បន្នមានប្រហែល ៣០% និងបានបង្កើតចម្ការខ្នាតធំសម្រាប់ការផលិតដូងប្រេង ( ការនាំចេញធំទីពីរ )។ ជាពិសេសឥណ្ឌូនេស៊ីជាប្រទេសតែមួយគត់ដែលបានចូលជាសមាជិក OPEC ។

បើក្រឡេកមកមើល ឧស្សាហកម្មនៅក្នុងប្រទេសនេះវិញបានរួមចំណែកប្រហែល ៣៨.៣% នៃផលិតផលក្នុងស្រុកសរុប និងបានផ្តល់ការងារ ២២.៧% នៃកម្លាំងពលកម្មក្នុងឆ្នាំ២០២១។ វិស័យឧស្សាហកម្មរួមមានការផលិតវាយនភ័ណ្ឌ ស៊ីម៉ង់ ជីគីមី ផលិតផលអេឡិចត្រូនិក សំបកកង់កៅស៊ូ សម្លៀកបំពាក់ និងស្បែកជើង ( ភាគច្រើនសម្រាប់ទីផ្សារអាមេរិក )។ ការកែច្នៃឈើក៏ជាសកម្មភាពសំខាន់មួយផងដែរ ដោយសារប្រទេសនេះជាអ្នកផលិតឈើដ៏ធំបំផុតមួយរបស់ពិភពលោក។ បើយោងតាម ការអនុវត្តច្បាប់ព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្មឥណ្ឌូនេស៊ីបានលើកឡើងថា ការប្រយុទ្ធប្រឆាំងនឹងការកាប់ឈើខុសច្បាប់កំពុងមានការរីកចម្រើន ហើយឥណ្ឌូនេស៊ីបានក្លាយជាប្រទេសដំបូងគេក្នុងពិភពលោកដែលទទួលបានការលើកលែងពីការត្រួតពិនិត្យ ដើម្បីធានាថាឈើរបស់ខ្លួនមានប្រភពស្របតាម EU បទប្បញ្ញត្តិ។ ព្រៃឈើឥណ្ឌូនេស៊ីជាង៣ លានហិកតាត្រូវបានបញ្ជាក់ទទួលស្គាល់ ហើយជាង២.២ លានហិកតាក្នុងចំណោមនោះគឺជាសម្បទានព្រៃឈើផលិតកម្មធម្មជាតិ។

ចំណែកឯ វិស័យសេវាកម្ម ( ស្ថាប័នហិរញ្ញវត្ថុ ការដឹកជញ្ជូន និងទំនាក់ទំនង ) បានរួមចំណែកដល់ទៅ ៤៤.៤% នៃផលិតផលក្នុងស្រុកសរុប និងផ្តល់ការងារដល់ ៤៩.៦% នៃចំនួនប្រជាជនសកម្មក្នុងឆ្នាំ២០២១។ ទន្ទឹមនឹងនោះ វិស័យធនាគារត្រូវបានអភិវឌ្ឍយ៉ាងល្អ ហើយវិស័យទេសចរណ៍គឺជាប្រភពចំណូលដ៏សំខាន់ បើទោះបីជាវិស័យនេះបានទទួលរងការគំរាមកំហែងពីភេរវករ និងគ្រោះមហន្តរាយធម្មជាតិក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ។ ចាប់ពីខែមករា ដល់តុលាឆ្នាំ ២០១៩ ប្រទេសនេះទទួលបានភ្ញៀវទេសចរចំនួន ១៣.៦ លាននាក់ និងកើនឡើង៤.៦% បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ ២០១៨។ រដ្ឋាភិបាលរំពឹងថា ប្រទេសនេះនឹង

ក្លាយទៅជាគោលដៅទេសចរណ៍អាស៊ី និងពិភពលោកឈានមុខគេនៅឆ្នាំ ២០៤៥ជាមួយភ្ញៀវទេសចរណ៍ ៧៣ លាននាក់។ (Stanbic, 2022)

| Breakdown of Economic Activity By Sector | Agriculture | Industry | Services |
|---|---|---|---|
| **Employment By Sector** *(in % of Total Employment)* | 28.5 | 22.4 | 49.1 |
| **Value Added** *(in % of GDP)* | 13.7 | 38.3 | 44.4 |
| **Value Added** *(Annual % Change)* | 1.8 | -2.8 | -1.4 |

*Source: World Bank, Latest Available Data. Because of rounding, the sum of the percentages may be smaller/greater than 100%.*

**១.៤.៣ ការសិក្សាលើវិស័យឧស្សាហកម្មនៅប្រទេសថៃ**

ប្រទេសថៃ គឺជាប្រទេសដែលមានសេដ្ឋកិច្ចធំជាងគេទីពីរនៅអាស៊ីអាគ្នេយ៍បន្ទាប់ពីប្រទេសឥណ្ឌូនេស៊ីជាមួយនឹងស្ថានភាពប្រាក់ចំណូលមធ្យមកម្រិតខ្ពស់។ ស្របពេលគ្នានោះដែរ ការវិនិយោគសាធារណៈត្រូវបានព្យាករណ៍ថានឹងនៅតែជាកត្តាជំរុញដ៏សំខាន់ ដោយកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះស្របតាមផែនការហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋាភិបាលក្នុងការទាក់ទាញការវិនិយោគឯកជន និងបន្តកែលម្អវិស័យទេសចរណ៍ថែមទៀត។ ប្រទេសថៃមានកម្លាំងពលកម្មចំនួន ៣៩ លាននាក់ក្នុងឆ្នាំ២០២០ ក្នុងចំណោមប្រជាជនចំនួន ៦៩.៨ លាននាក់។ សេដ្ឋកិច្ចរបស់ប្រទេសនេះពឹងផ្អែកខ្លាំងលើវិស័យកសិកម្មដែលបានរួមចំណែក ៨.៦% នៃផលិតផលក្នុងស្រុកសរុប និងផ្តល់ការងាររហូតដល់ ៣១.២% នៃចំនួនប្រជាជនសកម្មក្នុងឆ្នាំ

២០២១។ ប្រទេសនេះជាអ្នកផលិតកៅស៊ូធម្មជាតិធំជាងគេបំផុតនៅលើពិភពលោក និងជាប្រទេសផលិត និងនាំចេញអង្ករឈានមុខគេ។ ហើយក៏មានស្ករ ពោត ស្លែ កប្បាស និងថ្នាំជក់ផងដែរក្នុងចំណោមដំណាំសំខាន់ៗ។ បើក្រឡេកមកមើល ការនេសាទវិញគឺជាសកម្មភាពមួយដ៏សំខាន់ ដោយសារប្រទេសថៃជាប្រទេសនាំចេញបង្គាកសិកម្មដ៏សំខាន់មួយ។ ទោះជាយ៉ាងណាក៏ដោយ ការរួមចំណែករបស់វិស័យកសិកម្មចំពោះផលិតផលក្នុងស្រុកសរុបកំពុងធ្លាក់ចុះខណៈការនាំចេញទំនិញ និងសេវាកម្មបានកើនឡើង។ ចំណែកឯ វិស័យផលិតកម្មវិញមានចំនួន ៣៣.១% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០២១ នហើយត្រូវបានធ្វើពិពិធកម្មយ៉ាងល្អ និងបានផ្តល់ការងាររហូតដល់ ២២.៥% នៃចំនួនប្រជាជនសកម្ម។ ឧស្សាហកម្មសំខាន់ៗរបស់ថៃគឺ អេឡិចត្រូនិច ដែក និងរថយន្ត ជាពិសេសក៏មានមជ្ឈមណ្ឌលប្រមូលផ្តុំសម្រាប់ម៉ាករថយន្តអន្តរជាតិផងដែរ។ គ្រឿងបរិក្ខារអគ្គិសនី កុំព្យូទ័រ ការផលិតស៊ីម៉ង់ត៍ គ្រឿងសង្ហារិម និងផលិតផលប្លាស្ទិកក៏ជាផ្នែកសំខាន់ផងដែរ។ ស្របគ្នានោះដែរ វិស័យវាយនភ័ណ្ឌមានបុគ្គលិកតិចជាងមួយភាគបួននៃចំនួនប្រជាជនសកម្ម និងលែងមានភាពស្វាហាប់ដូចវិស័យទេសចរណ៍ដែលជាប្រភពសំខាន់នៃរូបិយប័ណ្ណបរទេស។

វិស័យទីបី រួមទាំងសេវាហិរញ្ញវត្ថុកំពុងកើនឡើងដែលបានរួមចំណែកដល់ ៥៨.៣% នៃផលិតផលក្នុងស្រុកសរុប និងផ្តល់ការងារដល់ ៤៦.៣% នៃចំនួនប្រជាជនសកម្មក្នុងឆ្នាំ២០២១។ រីឯ វិស័យទេសចរណ៍ក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចថៃផងដែរ។ (Stanbic, Main Sectors of Industry, 2022)

| Breakdown of Economic Activity By Sector | Agriculture | Industry | Services |
|---|---|---|---|
| **Employment By Sector** *(in % of Total Employment)* | 31.4 | 22.8 | 45.7 |
| **Value Added** *(in % of GDP)* | 8.6 | 33.1 | 58.3 |
| **Value Added** *(Annual % Change)* | -3.4 | n/a | n/a |

*Source: World Bank, Latest Available Data. Because of rounding, the sum of the percentages may be smaller/greater than 100%.*

### ១.៥ វិស័យឧស្សាហកម្មជម្រុញកំណើនសេដ្ឋកិច្ចនៅកម្ពុជា

ឧស្សាហកម្មជាស្នូលរបស់កម្ពុជា បានរួមចំណែកដល់ការរីកចម្រើនឥតឈប់ឈរនៃសេដ្ឋកិច្ចរបស់កម្ពុជាចាប់តាំងពីបញ្ចប់សង្គ្រាមស៊ីវិល ដែលទាំងនេះបណ្តាលមកពីការអនុវត្តគោលនយោបាយបើកទូលាយ លើកទឹកចិត្តដល់ធុរកិច្ច និងគោលនយោបាយសេរីដទៃទៀត។ កំណើនប្រកបដោយចីរភាព និងស្ថេរភាពក្នុងវិស័យឧស្សាហកម្មសម្រេចបានដោយសារការអភិវឌ្ឍន៍វិស័យកាត់ដេរ វិស័យទេសចរណ៍ វិស័យសំណង់ និងអចលនទ្រព្យ និងវិស័យកសិឧស្សាហកម្ម ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រីកទីផ្សារកម្ពុជា។ ហើយក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះសេដ្ឋកិច្ចកំពុងឈានដល់ដំណាក់កាលមួយនៃការធ្វើពិពិធកម្មដ៏សំខាន់ដោយផ្លាស់ប្តូរទៅរកការផលិតដែលមានតម្លៃខ្ពស់ គុណភាព និងផលិតកម្មដែលប្រើប្រាស់ជំនាញកាន់តែច្រើន។

**១.៥.១ វិស័យកាត់ដេរ**

វិស័យកាត់ដេរ គឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចកម្ពុជា ដែលមានការនាំចេញទំនិញប្រចាំឆ្នាំចំនួន៧៤%ក្នុងរយៈពេលជាងពីរទសវត្សកន្លងមកនេះ។ យោងតាមអគ្គនាយកដ្ឋានគយ និងរដ្ឋាករក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឲ្យដឹងថាព្រះរាជាណាចក្រកម្ពុជាបាននាំចេញនូវផលិតផលសម្លៀកបំពាក់ និងស្បែកជើងដែលមានតម្លៃជិត៨ពាន់លានដុល្លារក្នុងរយៈពេល៩ខែដំបូងនៃឆ្នាំ២០១៩ពោលគឺកើនឡើង១៣% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨។ រហូតដល់ឆ្នាំ២០២១ វិស័យនេះបានកើនឡើងរហូតដល់ ១៥.២% នៃការនាំចេញ និងមានរោងចក្រ សាខាប្រហែល ១១០០កន្លែង ដែលផ្តល់ការងារដល់កម្មករប្រមាណ ៧៥០០០០នាក់ ដែលភាគច្រើនជាស្ត្រី។ ភាគច្រើននៃការនាំចេញទាំងនេះត្រូវបានដឹកទៅទីផ្សារអឺរ៉ុប សហរដ្ឋអាមេរិច និងជប៉ុន។ ការបន្តរីកចម្រើននេះគឺដោយសារគោលនយោបាយសេដ្ឋកិច្ចបើកទូលាយរបស់កម្ពុជាដែលជាទីតាំងភូមិសាស្ត្រអំណោយផល និងកម្លាំងពលកម្មដ៏សម្បូរបែបដែលបានទាក់ទាញប្រជាពលរដ្ឋក្នុងស្រុក និងជនបរទេសឲ្យមកវិនិយោគនៅក្នុងវិស័យនេះកាន់តែច្រើន។ លើសពីនេះទៀតក៏មានការផ្តួចផ្តើមក្នុងការបណ្តុះបណ្តាលកម្មករកាត់ដេរដោយផ្តល់នូវជំនាញឯកទេសបន្ថែមទៀតដែលជាកត្តាសំខាន់ដើម្បីលើកកម្ពស់ប្រាក់ចំណូល និងប្រសិទ្ធិភាពនៃឧស្សាហកម្មទាំងមូល ហើយចំណែកឯប្រាក់ឈ្នួលអប្បបរមាសម្រាប់វិស័យនេះនឹងមានការកើនឡើងទ្វេដង។

(realestate, 2019)




*Source: Ministry of Economy and Finance of Cambodia*

១.៥.២ វិស័យទេសចរណ៍

ប្រទេសកម្ពុជាត្រូវបានគេស្គាល់ថាជាទិសដៅទេសចរណ៍ វប្បធម៌ និងធម្មជាតិដ៏ល្បីល្បាញមួយ។ វិស័យទេសចរណ៍មានការរីកចម្រើនឥតឈប់ឈរ និងបានរួមចំណែកដល់ជាង១០%នៃផលិតផលក្នុងស្រុកសរុប

ជាតិ(ផសស) ក្នុងទសវត្សឆ្នាំ២០០០ រហូតដល់ឆ្នាំ២០១៨ បានកើនឡើងដល់ ១២.៣%នៃផលិតផលក្នុងស្រុកសរុប ហើយវិស័យនេះត្រូវបានកំណត់ថាជាវិស័យអាទិភាពកំពូល ហើយថែមទាំងត្រូវបានគេដាក់ឈ្មោះថាមាសបៃតង ពីព្រោះវិស័យនេះមិនត្រឹមតែបង្កើនឱកាសការងារ លើកកម្ពស់ជីវភាពប្រជាជន និងបង្កើនប្រាក់ចំណូលជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏បានទាក់ទាញការវិនិយោគផ្ទាល់ក្នុងស្រុក និងបរទេសក៏ដូចជាលំហូររូបិយប័ណ្ណអន្តរជាតិផងដែរ ដែលទាំងអស់នេះបានរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់ប្រទេសកម្ពុជាទាំងមូល។

វិស័យទេសចរណ៍នៅតែបន្តក្លាយជា សសរស្តម្ភនៃកំណើនប្រចាំឆ្នាំនៅក្នុងប្រទេសកម្ពុជា ដែលបានជំរុញដោយអ្នកទេសចរណ៍ដ៏ច្រើនសន្ធឹកសន្ធាប់ ដែលបានចូលមកទស្សនាប្រាសាទអង្គរវត្តដែលត្រូវបានអង្គការយូនីស្កូដាក់បញ្ចូលជាបេតិកភណ្ឌពិភពលោក ដោយការផ្តល់ចំណាត់ថ្នាក់នេះបានរួមចំណែកយ៉ាងធំធេងដល់ការរីកចម្រើនផ្នែកទេសចរណ៍អន្តរជាតិនៅកម្ពុជា។ យោងតាមតួលេខភ្ញៀវទេសចរណ៍អន្តរជាតិបានបង្ហាញថា ភ្ញៀវទេសចរណ៍អន្តរជាតិចំនួន ៦,២លាននាក់បានចូលមកប្រទេសកម្ពុជាក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ ភ្ញៀវទេសចរណ៍បានថយចុះបន្តិចដែលមានចំនួន ៤,៨លាននាក់ប៉ុណ្ណោះរហូតដល់ចុងឆ្នាំ២០១៩ បានកើនឡើងវិញចំនួន ៥,៦លាននាក់។ខណៈដែលសៀមរាប និងភ្នំពេញនៅតែជាមជ្ឈមណ្ឌលដ៏សំខាន់សម្រាប់កំណើននេះ ដោយខេត្តសៀមរាបបាននាំមុខក្នុងការទាក់ទាញភ្ញៀវទេសចរណ៍ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺរាជធានីភ្នំពេញ បានទាក់ទាញភ្ញៀវទេសចរចំនួនជិត ៣០មឺននាក់នៅត្រឹមត្រីមាសទី៣ ឆ្នាំ ២០១៩។

របាយការណ៍ដដែលពីក្រសួងទេសចរណ៍ក៏បានបង្ហាញផងដែរថា ៧០% នៃភ្ញៀវទេសចរក្នុងប្រទេសបានមកដល់អាកាសចរណ៍តាមរយៈអាកាសយានដ្ឋានអន្តរជាតិចំនួន៣ ដែលមានដូចជាអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ (PNH) ដែលទទួលភ្ញៀវទេសចរណ៍ភាគច្រើនគឺ ៣២,៦%។ អាកាសយានដ្ឋានអន្តរជាតិសៀមរាប (REP) ស្ថិតនៅលេខ២ ជិត ២៦,៥%។ ហើយចុងក្រោយគឺ កុងខេងអាកាសយានដ្ឋានក្នុងក្រុងព្រះសីហនុ (KOS) មានអត្រា ១១,៤% នៃចំនួនភ្ញៀវទេសចរណ៍មកដល់ត្រីមាសទី៣ ឆ្នាំ២០១៩ និងបានកើនឡើងរហូតដល់ ៣០០% នៃចំនួនភ្ញៀវទេសចរណ៍ ១៣៤.៦៦៣នាក់នៅឆ្នាំ២០១៨ ដល់ចំនួន៥៤៩.៤៨១នាក់។ ខេត្តព្រះសីហនុមានភាពល្បីល្បាញ ដោយសារការអភិវឌ្ឍ និងភាពរីកចម្រើនយ៉ាងឆាប់រហ័ស និងជាគោលដៅទេសចរណ៍តំបន់ឆ្នេរសមុទ្រដ៏សំខាន់បំផុតមរបស់កម្ពុជា។ ការវិនិយោគក្នុងវិស័យទេសចរណ៍ ការស៊ីណូ និងហោដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធបានហូរចូលក្នុងតំបន់ឆ្នេរសមុទ្រមួយនេះ។ មូលហេតុចម្បង មួយនៃភាពរីកចម្រើននេះគឺការពង្រីកអាកាសយានដ្ឋានអន្តរជាតិក្រុងព្រះសីហនុដើម្បីបង្កើនជើងហោះហើរអន្តរជាតិបន្ថែមទៀតពីប្រទេសចិន វៀតណាម ហ្វីលីពីន និងម៉ាឡេស៊ី។ (realestate, ទេសចរណ៍, 2019)

Cambodia Investment Guide 2020




*Source: Tourism Statistics Department, MOT*

## ១.៥.៣ វិស័យសំណង់ និងអចលនទ្រព្យ

ឧស្សាហកម្មសំណង់ នៅកម្ពុជាត្រូវបានគេមើលឃើញថាមានកំណើនថេរក្នុងរយៈពេលមួយទសវត្សចុងក្រោយនេះ។ យោងតាមរបាយការណ៍របស់ធនាគារពិភពលោកនៅខែឧសភា ឆ្នាំ២០១៩ ប្រទេសកម្ពុជាបានកើនលើសតួលេខដែលបានព្យាករណ៍នៅក្នុងកំណើនប្រចាំឆ្នាំសម្រាប់ឆ្នាំ២០១៨ ជាមួយនឹងកំណើនផលិតផលក្នុងស្រុកសរុប៧.៥%។ ជាលទ្ធផលធនាគារពិភពលោក និងអាស៊ានបានរំពឹងថាកំណើនផលិតផលក្នុងស្រុកសរុប៧% នឹងបន្តសម្រាប់ប្រទេសកម្ពុជាហើយធនាគារពិភពលោកក៏រំពឹងថាវិស័យសំណង់របស់កម្ពុជានឹងចូលរួមចំណែកយ៉ាងសំខាន់ដល់កំណើននេះ។

វិស័យសំណង់បានទាក់ទាញវិនិយោគិនបរទេសជាច្រើនក្នុងនោះប្រមាណ៩០% នៃការវិនិយោគដោយផ្ទាល់ពីបរទេស(FDI) គឺវិនិយោគិនតំបន់អាស៊ី។ ប្រទេសដែលចូលរួមចំណែកក្នុងវិស័យសំណង់ភាគច្រើនគឺប្រទេសចិន ជប៉ុន កូរ៉េ តៃវ៉ាន់ សិង្ហបុរី និងហុងកុង ស្របគ្នានោះដែលប្រទេសចិនបានចូលរួមចំណែក៤០% នៃ FDI ក្នុងឆមាសទី១នៃឆ្នាំ២០១៩។ ទន្ទឹមនឹងនោះ វិនិយោគិនបរទេសបានផ្តោតជាពិសេសទៅលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដោយមានការវិនិយោគធំៗពីរដ្ឋាភិបាលចិនព្រមទាំងធនាគារពិភពលោក។ គេរំពឹងទុកថាទុនវិនិយោគពីបរទេសសរុបនៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនៅចន្លោះឆ្នាំ២០១៣ ដល់២០២២នឹងស្ថិតនៅចន្លោះពី ១៤ពាន់លានទៅ១៦ពាន់លានដុល្លារ។

លើសពីនេះក៏មានការរំពឹងថា សកម្មភាពសំណង់របស់ប្រទេសកម្ពុជាទំនងជានឹងបន្តកើនឡើងក្នុងអត្រាដូចគ្នា ហើយរដ្ឋាភិបាល និងវិនិយោគិនបរទេសកំពុងផ្តល់អាទិភាពដល់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាមួយវិស័យសំណង់ឯកជន។ បើក្រឡេកមកមើលតម្រូវការសម្រាប់ការអភិវឌ្ឍន៍អចលទ្រព្យ ជាពិសេសការអភិវឌ្ឍន៍បុរីនៅតែមានកម្រិតខ្ពស់ទូទាំងប្រទេសកម្ពុជា ដោយសារតែចំនួនប្រជាពលរដ្ឋកំពុងកើនឡើងយ៉ាង

ឆាប់រហ័សនៅតាមទៅក្រុង។ ចំណែកឯវិស័យអចលនទ្រព្យវិញ បច្ចុប្បន្នវិស័យនេះកំពុងមានសន្ទុះខ្លាំងជាពិសេសគឺវិស័យដីធ្លីហើយវិស័យនេះអាចសក្តានុពលយូរអង្វែងទៀតនៅកម្ពុជាព្រោះជាប្រទេសដែលមានស្ថិរភាពកំណើនសេដ្ឋកិច្ច និងមានប្រទេសជាច្រើនកំពុងសម្រុកមកដាក់ទុនវិនិយោគ។ បើយោងទៅតាមប្រធានសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា (CVEA) ក៏ធ្លាប់បានព្យាករណ៍ថាវិស័យអចលនទ្រព្យនៅកម្ពុជានឹងមានសន្ទុះខ្លាំងឡើងវិញនៅប៉ុន្មានឆ្នាំខាងមុខនេះ ដោយរំពឹងថាលំហូរវិនិយោគបរទេសអាចនឹងមានដល់៣០ ទៅ៤០%។ (realestate, ការសាងសង់, 2019)




Source: Asian Development Bank. *Asian Development Outlook 2019 Update*

## ១.៥.៤ វិស័យកសិ-ឧស្សាហកម្ម

វិស័យកសិឧស្សាហកម្មគឺជាវិស័យទីមួយផង និងទីពីរ២ផងដែលជាសកម្មភាពចម្បងទាក់ទងទៅនឹងការកែច្នៃកសិផល និងជលផលទៅជាផលិតផលឧស្សាហកម្ម ឬពាក់កណ្តាលឧស្សាហកម្ម។ ការអភិវឌ្ឍន៍វិស័យកសិឧស្សាហកម្មនឹងបង្កើនតម្លៃបន្ថែមលើកសិផលដែលនឹងជំរុញកសិករឲ្យចាកចេញពីការធ្វើកសិកម្មសម្រាប់ហូប និងលើកទឹកចិត្តឲ្យមានការចូលរួមក្នុងសកម្មភាពទីផ្សារកសិកម្ម។

បើយោងតាម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទថ្មីៗនេះបានបង្ហាញពីវឌ្ឍភាពនៃផលិតកម្មដំណាំកសិ-ឧស្សាហកម្មសំខាន់ៗចំនួន៦មុខដែលបាននាំចេញនៅក្នុងឆ្នាំ២០២០ដោយសម្រេចបានការនាំចេញសរុបជាង៨លាន៥សែនតោនស្មើនឹងទឹកប្រាក់ ២ពាន់លានដុល្លារ។ ទាំងនេះបានបង្ហាញឲ្យឃើញថាវិស័យកសិ-ឧស្សាហកម្មគឺជាផ្នែកសំខាន់មួយសម្រាប់អភិវឌ្ឍន៍ប្រទេសកម្ពុជាព្រោះវិស័យនេះអាចផ្តល់ប្រាក់ចំណូលដល់ប្រជាជនកាន់តែច្រើន ហើយសេដ្ឋកិច្ចក៏កាន់តែលូតលាស់។

# ជំពូកទី២

# ទិដ្ឋភាពទូទៅនៃវិស័យឧស្សាហកម្មនៅ
# កម្ពុជា

# ជំពូកទី២

# ទិដ្ឋភាពទូទៅនៃវិស័យឧស្សាហកម្មនៅកម្ពុជា

## ២.១ សង្ខេបស្ថានភាពសេដ្ឋកិច្ចកម្ពុជា

ក្រោយពីសង្គ្រាមស៊ីវិលដែលបានអូសបន្លាយអស់រយៈពេលជាងបីទសវត្សកន្លងមកនេះ ប្រទេសកម្ពុជាបានទទួលសន្តិភាពចាប់តាំងពីឆ្នាំ១៩៩៨ និងបានកំពុងស្ថាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងរចនាសម្ព័ន្ធជាមូលដ្ឋានរបស់សង្គម និងកំពុងផ្តល់លទ្ធភាពឲ្យប្រទេសអាចបង្វែរទិសនៃធនធាន និងកម្លាំងរបស់ខ្លួនឆ្ពោះទៅរកទិសដៅនៃការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងភាពស្មើគ្នា។ ជាក់ស្តែងប្រទេសកម្ពុជា បានចាប់ផ្តើមកសាងប្រទេសពីបាតដៃទទេ បន្ទាប់ពីបរាជ័យនៃរបបខ្មែរប្រហមរួចមកដោយចាប់តាំងពីដើមទសវត្សទី៩០មកសេដ្ឋកិច្ចមានកំណើនខ្លាំង ជាពិសេសជាមួយនឹងការអនុវត្តកំណែទម្រង់ម៉ាក្រូសេដ្ឋកិច្ច និងធម្មនីយកម្មសេដ្ឋកិច្ច និងទំនាក់ទំនងពាណិជ្ជកម្មជាមួយបណ្តាប្រទេសក្នុងតំបន់ ហើយក្នុងឆ្នាំ១៩៩៤ ដល់១៩៩៨កម្ពុជាសម្រេចបានអត្រាមធ្យមប្រចាំឆ្នាំ៦.៣%។ រហូតមកដល់ឆ្នាំ២០០៣ អត្រាកំណើនជាមធ្យមប្រចាំឆ្នាំកើនដល់៨.៨%ដែលកំណើននេះបានមកពីវិស័យដែលមានសន្ទុះខ្លាំងចំនួនពីរគឺ វិស័យកាត់ដេរ និងទេសចរណ៍។

ពីដើមទសវត្សទី៨០រហូតដល់១៩៩១ សេដ្ឋកិច្ចកម្ពុជាត្រូវបានរៀបចំបែបលក្ខណៈប្រមូលផ្តុំ ប៉ុន្តែអនិយតកម្មសេដ្ឋកិច្ចត្រូវបានចាប់ផ្តើមអនុវត្តចាប់តាំងពីឆ្នាំ១៩៩២មក។ ក្នុងអំឡុងទសវត្សទី៩០ប្រទេសកម្ពុជាបានឆ្លងកាត់ដំណាក់កាលផ្លាស់ប្តូរពីសេដ្ឋកិច្ចផែនការទៅសេដ្ឋកិច្ចទីផ្សារ ចំណែកឯកំណែទម្រង់ និងគោលដៅនយោបាយសម្រាប់ជំរុញការអភិវឌ្ឍវិស័យឯកជនដែលបានអនុម័តក្នុងឆ្នាំ១៩៨៩ និង១៩៩០បានបើកទូលាយសេដ្ឋកិច្ចតាមរយៈការរំលាយចោលការត្រួតពិនិត្យតម្លៃ និងជំរុញការអភិវឌ្ឍវិស័យឯកជនរួមទាំងការវិនិយោគក្រៅប្រទេសដោយក្នុងរយៈពេលនោះកំណើនបានមកពីវិស័យផលិតកម្ម និងសេវា។

ជាលទ្ធផលក្នុងឆ្នាំ២០០៩ សេដ្ឋកិច្ចកម្ពុជាក៏បានងើបរួចពីវិបត្តិនេះដោយសម្រេចបាននូវកំណើនចំនួន៦% ហើយក្នុងឆ្នាំជាបន្តបន្ទាប់កម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចជាមធ្យម៧%។ (ជួនណារ៉ុន, ២០១៥)

## ២.២ ស្ថានភាពវិស័យឧស្សាហកម្មកម្ពុជា

ក្នុងឆ្នាំ២០២១ កន្លងទៅរោងចក្រធុនធំដែលដំណើរការនៅកម្ពុជាបានបង្កើតការងារចំនួនជិត១លាននាក់ និងមានតម្លៃបរិមាណផលិតផលសរុបប្រមាណជាង៧.៤៣៣លានដុល្លារអាមេរិច ហើយក្នុងចំណោមទំនិញដែលមានតម្លៃជាង៧.៤៣៣ពាន់លានដុល្លារអាមេរិកនោះទីផ្សារក្នុងស្រុកមានចំនួនជាង១.៩៧៧លាន និងតម្លៃបរិមាណសម្រាប់នាំចេញមានចំនួនជាង៥.៤៥៦លានដុល្លារអាមេរិក។ យោងតាមរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បានឲ្យដឹងថាវិស័យឧស្សាហកម្មបានរួមចំណែកដល់ការអភិវឌ្ឍ ការទ្រទ្រង់ និងលើកកម្ពស់កំណើនសេដ្ឋកិច្ចផងដែរ។

### ២.២.១ ប្រវត្តិសង្ខេបនៃវិស័យឧស្សាហកម្ម

តាមប្រវត្តិសាស្ត្របង្ហាញថា មុនពេលទទួលបានឯករាជ្យភាពពីអាណានិគមនិយមឆ្នាំ១៩៥៤ វិស័យឧស្សាហកម្មកម្ពុជាស្ទើរតែពុំមានវត្តមាន។ នៅសម័យនោះរោងចក្រឧស្សាហកម្មដែលបានដំណើរការរួមមានរោងចក្រច្នៃជ័រកៅស៊ូ រោងចក្រម៉ាស៊ីនកិនស្រូវ រោងចក្រតម្បាញដែលធ្វើសកម្មភាពក្នុងទិសដៅបម្រើឲ្យការនាំចេញទៅកាន់ប្រទេសក្រោមដំបូលអាណានិគមតែមួយ។ ក្រៅពីនេះមានតែសិប្បកម្មមួយចំនួនតូចប៉ុណ្ណោះ។ បន្ទាប់ពីទទួលបានឯករាជ្យ ប្រទេសកម្ពុជាបានដាក់ចេញនូវទិសដៅនយោបាយអភិវឌ្ឍវិស័យឧស្សាកម្មជាតិដែលរហូតដល់សម័យមុនសង្គ្រាមបានធ្វើឲ្យវិស័យឧស្សាហកម្មមានការរីកលូតលាស់គួរឲ្យកត់សម្គាល់។ ប៉ុន្តែលទ្ធផលនៃសង្គ្រាមស៊ីវិលឆ្នាំ១៩៧០ ដល់១៩៧៥ និងក្រោមការគ្រប់គ្រងនៃរបបប៉ុលពតឆ្នាំ១៩៧៥ ដល់១៩៧៩បានធ្វើឲ្យវិស័យឧស្សាហកម្មជាតិទទួលរងវិនាសសកម្មយ៉ាងដំណំ។ បន្ទាប់ពីបានផ្តួលរលំរបបប៉ុលពតនាឆ្នាំ១៩៧៩ រដ្ឋាភិបាលកម្ពុជាបានជ្រើសរើសមាគ៌ាអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនដោយធ្វើការស្តារវិស័យឧស្សាហកម្មជាតិដែលបានខ្ទេចខ្ទាំដោយសង្គ្រាមហើយវិស័យនេះបានដើរតួនាទីយ៉ាងសំខាន់ទី២ក្នុងសេដ្ឋកិច្ចកម្ពុជា។

ដូចដែលយើងបបញ្ជាក់កន្លងមកហើយថា នៅឆ្នាំ១៩៨៩ វិស័យឧស្សាហកម្មមានទំហំ១៤.៦% នៃផ.ស.ស ហើយបានផ្គត់ផ្គង់ការងារពលកម្មជិត៣.១%នៃប្រជាជនខ្មែរយើងនាសម័យនោះ។ រចនាសម្ព័ន្ធផលិតកម្មរួមមានអគ្គិសនី សំបកកង់រថយន្ត និងទោចក្រយាន កៅស៊ូក្រែប ឧស្សាហកម្មគីមី ឧស្សាហកម្មគ្រឿងសំណង់ ឧស្សាហកម្មចំណីអាហារ ឧស្សាហកម្មវាយនភណ្ឌឧស្សាហកម្មផលិតបារី និងផ្សេងៗទៀត។ ចំពោះផលិតកម្មដែលលេចធ្លោជាងគេនាសម័យនោះរួមមានការផលិតឧបករណ៍កសិកម្ម និងគ្រឿងបន្លាស់ ការកែច្នៃលោហធាតុ ការកែច្នៃផលិតផលកសិកម្ម និងរោងចក្រសិប្បកម្ម។ តំបន់ឧស្សាហកម្មមានទីតាំងស្ថិតនៅរាយប៉ាយផ្សេងៗគ្នានៃផ្ទៃប្រទេស ប៉ុន្តែសម្រាប់រាជធានីភ្នំពេញ តំបន់ជាយក្រុង និងតំបន់ខេត្តកណ្តាលបានគ្របដណ្តប់រហូតដល់៤០%នៃរោងចក្រឧស្សាហកម្មរបស់ប្រទេស។ រីឯខេត្តកំពង់ចាម កំពង់សោម បាត់ដំបង ព្រៃវែង កំពត បានគ្របដណ្តប់៦០%នៃចំនួនរោងចក្រសរុប។ ប៉ុន្តែទំហំផលិតកម្មទំនិញឧស្សាហកម្មសម្រាប់រោងចក្រសហគ្រាសនៅតំបន់ភ្នំពេញមានលទ្ធភាពផលិតរហូតដល់៧៣%នៃចំនួនផលិតផលសរុប។ រីឯខេត្តបាត់ដំបងជាប់ចំណាត់ថ្នាក់លេខ២។

គួរបញ្ជាក់ថា នៅប្រទេសកម្ពុជាសម័យនោះវិស័យឧស្សាហកម្មរីកលូតលាស់តែឧស្សាហកម្មធុនស្រាលនិងមធ្យមតែប៉ុណ្ណោះហើយស្ថានភាពរោងចក្រឧស្សាហកម្ម និងគ្រឿងសម្ភារផលិតកម្មផ្សេងទៀតសុទ្ធជារោងចក្រសេសសល់ពីសម័យសង្គ្រាម ហើយជាគ្រឿងចក្រផលិតនៅបណ្តាប្រទេសអតីតប្រទេសសង្គមនិយម និងមូលធននិយម។ ដោយសារតែស្ថានភាពរោងចក្រមានភាពទ្រុឌទ្រោមធ្វើឲ្យសមត្ថភាពផលិតកម្មទទួលបានបរិមាណក្នុងកម្រិតទាប ហើយទាមទារចាំបាច់នូវការកែលម្អឡើងវិញ និងធ្វើឲ្យមានទំនើបកម្មឧស្សាហកម្ម។ (ណារ៉ុន, ២០១៧)

### ២.២.២ រចនាសម្ព័ន្ធឧស្សាហកម្ម

ដំណើរការសេដ្ឋកិច្ចរបស់កម្ពុជាមានលក្ខណៈគួរឲ្យចាប់អារម្មណ៍ណាស់ នៅចន្លោះឆ្នាំ១៩៩៨ដល់ ២០០២។ វិស័យឧស្សាហកម្មគឺជាក្បាលម៉ាស៊ីនយ៉ាងសំខាន់នៃកំណើន។ ផលិតផលក្នុងស្រុកសរុបឧស្សាហកម្មបានកើនឡើងជាមធ្យម១៦%ក្នុងមួយឆ្នាំ។ វិស័យនេះរួមមានជាសំខាន់អនុវិស័យឧស្សាហកម្ម(៧៨.៥%) និងអនុវិស័យសំណង់(១៨.៨%)។

*តារាង១០.២. រចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា (ជាពាន់លានរៀល)*

| | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | % |
|---|---|---|---|---|---|---|---|
| រ៉ែ | ៥៨ | ៧៤ | ៩៧ | ១១៥ | ១៣៥ | ១៦៥ | ២% |
| ឧស្សាហកម្មផលិត | ៣.៣៧៤ | ៤.០២៧ | ៤.៥៨៥ | ៥.៥៤១ | ៦.០៧៤ | ៦.៤៤១ | ៦៩% |
| ម្ហូប ភេសជ្ជៈ ថ្នាំជក់ | ៤៨៨ | ៥០៥ | ៦០៨ | ៦៦៤ | ៧៥៧ | ៩២៤ | ១០% |
| វាយនភណ្ឌ | ២.២៩៤ | ២.៨៤៧ | ៣.១៥៨ | ៣.៨៦៩ | ៤.២៣៤ | ៤.៣១៥ | ៤៦% |
| ឈើ ក្រដាស និងការបោះពុម្ព | ១០៥ | ១១៩ | ១៤៨ | ១៧១ | ២០៣ | ២៣៩ | ៣% |
| ឧស្សាហកម្មផលិតកៅស៊ូ | ១១១ | ១២២ | ១២៦ | ១៨១ | ១៤៨ | ១៥៣ | ២% |
| ឧស្សាហកម្មផលិតដទៃទៀត | ៣៧៧ | ៤៣៣ | ៥៤៥ | ៦៥៧ | ៧៣២ | ៨១១ | ៩% |
| អគ្គិសនី ឧស្ម័ន ទឹក | ៩៣ | ១១០ | ១២៤ | ១៦៤ | ១៩៥ | ២១២ | ២% |
| សំណង់ | ១.១០៦ | ១.២៨៨ | ១.៦៣១ | ១.៩៩៥ | ២.៣៣៨ | ២.៥៧២ | ២៧% |
| ឧស្សាហកម្ម | ៤៦.៣៣១ | ៥.៤៩៨ | ៦.៤៣៦ | ៧.៨១៦ | ៨.៧៤១ | ៩.៣៨៩ | ១០០% |

*ប្រភពៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

អនុវិស័យសម្លៀកបំពាក់ និងវាយនភ័ណ្ឌបាននាំឲ្យមានសន្ទុះនេះដែលបានបង្ហាញឲ្យឃើញថាមានភាពគួរឲ្យកត់សម្គាល់។ ឧស្សាហកម្មសម្លៀកបំពាក់កម្ពុជាបានបង្ហាញឲ្យឃើញនូវកំណើនយ៉ាងខ្លាំងបន្ទាប់ពីសហរដ្ឋអាមេរិកបានផ្តល់ឲ្យស្ថានភាពនោះឲ្យទទួលបានសិទ្ធិអនុគ្រោះខ្ពស់បំផុត។ នៅក្នុងឆ្នាំ១៩៩៦ និងប្រព័ន្ធទូទៅស្តីពីការបន្ធូរពន្ធ (GSP)នៅក្នុងឆ្នាំ១៩៩៧។ ភាពមានការងារធ្វើនៅក្នុងវិស័យសម្លៀកបំពាក់ និងវាយនភ័ណ្ឌគឺជាកម្លាំងធ្វើឲ្យមានស្ថេរភាពយ៉ាងខ្លាំងសម្រាប់ប្រជាជន និងសេដ្ឋកិច្ចនៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដោយសារតែវិស័យនេះបានស្រូបយកកម្លាំងពលកម្មដែលមានជំនាញ និងពាក់កណ្តាលជំនាញយ៉ាងច្រើនជាពិសេសកម្មករស្ត្រីក្រីក្រដែលបើមិនធ្វើការនៅក្នុងវិស័យនេះទេនឹងគ្មានការងារធ្វើតែម្តង។

ចំណែកឯឧស្សាហកម្មនៅតែបន្តបង្ហាញនូវសន្ទុះងើបឡើងគួរឲ្យកត់សម្គាល់ដែលនេះគឺជាលទ្ធផលយ៉ាងសំខាន់ដែលបានមកពីនយោបាយសេរីភាវូបនីយកម្មសេដ្ឋកិច្ចដែលកំពុងតែអនុវត្តឡើងដោយរាជរដ្ឋាភិបា

ល។ អត្រាកំណើនជាមធ្យមគឺ១២.៥% នៅក្នុងឆ្នាំ១៩៩៤-១៩៩៨ បន្តហូតមកដល់ឆ្នាំ១៩៩៧ដែលធ្លាក់បន្តិច នៅក្នុងឆ្នាំ១៩៩៨ (-២.៥%) ដោយសារតែព្រឹត្តិការណ៍ផ្ទៃក្នុងរបស់កម្ពុជា និងដោយសារតែវិបត្តិហិរញ្ញវត្ថុក្នុងតំបន់។ កំណើនឧស្សាហកម្មមានសន្ទុះខ្លាំងនៅចន្លោះឆ្នាំ១៩៩៩-២០០២ (២០.២%)។ ការចូលរួមចំណែករបស់វិស័យនេះនៅក្នុងផលិតផលសរុបជាតិកើនឡើងពី១១.៦% នៅក្នុងឆ្នាំ១៩៩៣ ទៅ ១៧%នៅក្នុងឆ្នាំ១៩៩៨ និង ២៦.២%នៅក្នុងឆ្នាំ២០០៦ហើយធ្លាក់មកត្រឹម២២.៤%នៅក្នុងឆ្នាំ២០០៨។ ឧស្សាហកម្មចម្បងនៅក្នុងប្រទេសកម្ពុជាគឺ ជ័ ម្ហូបអាហារ ភេសជ្ជៈ ថ្នាំជក់ សម្លៀកបំពាក់ ឈើ ក្រដាស និងការបោះពុម្ពឧស្សាហកម្មកៅស៊ូអគ្គិសនី ឧស្ម័ន ទឹកស្អាត និងសំណង់។ ឧស្សាហកម្មសំខាន់នៅក្នុងប្រទេសកម្ពុជាគឺ វាយនភ័ណ្ឌដែលចូលរួមចំណែក ៤៦%នៃទិន្នផលឧស្សាហកម្ម (២.៣ពាន់លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០០៨) ដែលបន្ទាប់មកគឺសំណង់ (២៧%) ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់(១០%) ឈើ ក្រដាស នុងការបោះពុម្ព(៣%) អគ្គិសនី ឧស្ម័ន និងទឹកស្អាត(២%) និងជ័(២%)។ ផ្នែកនេះនឹងជួយពន្យល់នូវការវិភាគយ៉ាងពិស្តារទាក់ទងទៅនឹងតែឧស្សាហកម្មសំខាន់ៗ។ (ជួនណារ៉ុន, សេដ្ឋកិច្ចនៃប្រទេសកម្ពុជា, ២០១៥)

## ២.៣ ស្ថានភាពវិស័យឧស្សាហកម្មក្រោយពេលមានគោលនយោបាយ

### ២.៣.១ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មរបស់រាជរដ្ឋាភិបាល

នៅឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម (២០១៥ -២០២៥ ) ដោយបានដាក់ចេញវិធានការលម្អិតប្រមាណជា ១០០ចំណុចសម្រាប់ដោះស្រាយវិស័យអាទិភាពជាច្រើនដូចជា ការការអភិវឌ្ឍន៍ជំនាញ បច្ចេកវិទ្យា ហិរញ្ញវត្ថុ និងការសម្របសម្រួលពាណិជ្ជកម្ម និងការវិនិយោគជាដើម។ រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជាពីឧស្សាហកម្មអតិពលកម្មឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥ តាមរយៈការតភ្ជាប់ទៅនឹងខ្សែចង្វាក់ច្រវ៉ាក់តម្លៃសកល សមាហរណកម្មទៅក្នុងបណ្តាញផលិតកម្មតំបន់ និងការអភិវឌ្ឍន៍កន្សោមផលិតកម្មប្រទាក់ក្រឡា ទន្ទឹមនឹងការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាពឧស្សាហកម្មក្នុងស្រុក ហើយឈានទៅរកអភិវឌ្ឍន៍ឧស្សាហកម្មទំនើបដែលផ្អែកជាសំខាន់លើមូលដ្ឋានបច្ចេកវិទ្យា និងចំណេះដឹង។ ការសម្រេចជោគជ័យនូវចក្ខុវិស័យមួយនេះនឹងរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ កំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្ន ការបង្កើតការងារ ការបង្កើនតម្លៃបន្ថែមនៅក្នុងវិស័យសេដ្ឋកិច្ច និងការកើនប្រាក់ចំណូលដល់ប្រជាជនកម្ពុជា។ (រាជរដ្ឋាភិបាលកម្ពុជា, ២០១៥)

### ២.៣.២ ភាពចាំបាច់នៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម

ទស្សនវិស័យវែងឆ្ងាយរបស់កម្ពុជាឆ្ពោះទៅឆ្នាំ២០៣០ និង " **យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣** " បានចង្អុលបង្ហាញពីការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជាដែលកំពុងឈានទៅសម្រេចឋានៈប្រទេសមានកម្រិតចំណូលមធ្យម និងបានចាត់ទុកវិស័យឧស្សាហកម្មជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ ក្នុងគោលដៅនេះរាជរដ្ឋាភិបាលបានរៀបចំនឹងដាក់ចេញនូវ " **គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម** " ដើម្បី

ជាមគ្គុទ្ទេសក៏ជំរុញការអភិវឌ្ឍន៍វិស័យឧស្សាហកម្មនៅកម្ពុជាដែលនឹងរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្ន។ ម៉្យាងទៀតគោលនយោបាយនេះនឹងក្លាយជា " **យុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មី** " ដែលផ្តោតជាសំខាន់លើការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាពស្របតាមនិន្នាការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុក និងការវិវត្តនៃនិម្មាបនកម្មសេដ្ឋកិច្ចពិភពលោក និងតំបន់ក៏ដូចជាការប្រើប្រាស់សក្តានុពលធនធានសរុបជាតិឲ្យអស់លទ្ធភាព។

ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោក និងតំបន់រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយបានគូសបញ្ជាក់ច្បាស់ពីកាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា។ ជាក់ស្តែង ក្នុងក្របខណ្ឌសមាហរណកម្ម និងសេរីភាវូបនីយកម្មសេដ្ឋកិច្ចតំបន់ពិសេសការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) និងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) កម្ពុជានឹងសម្រេចនូវការតភ្ជាប់ទាំងផ្នែករូបវន្ត និងស្ថាប័នរួមទាំងសមាហរណកម្មទូលំទូលាយលើគ្រប់វិស័យដែលនឹងរួមចំណែកដល់ការបើកច្រកទីផ្សារថ្មីៗ ការទាក់ទាញទុនវិនិយោគ និងការផ្ទេរបច្ចេកវិទ្យាមកកម្ពុជា។ ក្នុងន័យនេះ វិស័យពាណិជ្ជកម្ម និងឧស្សាហកម្មកម្ពុជានឹងទទួលប្រយោជន៍ពីសកលភាវូបនីយកម្មជារួម ពិសេសការវិនិយោគពីប្រទេសចិន កូរ៉េ និងជប៉ុនក៏ដូចជាពីសហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិកដែលកំពុងស្វះស្វែងរកឱកាសពាណិជ្ជកម្ម និងវិនិយោគនៅក្នុងទីផ្សារលូតលាស់ថ្មីដូចជាកម្ពុជា។ ជារួម ល្បឿននៃការផ្លាស់ប្តូររចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជានឹងត្រូវកំណត់ដោយកត្តាសត្យានុម័តសំខាន់ៗបីគឺ ៖ " **ការប្រែប្រួលរចនាសម្ព័ន្ធថ្លៃក្នុងតំបន់** " រួមទាំងកម្រៃប្រាក់ឈ្នួលផងដែរ " **និន្នាការតភ្ជាប់ឧស្សាហកម្មតំបន់** " ដែលកម្ពុជាស្ថិតលើទីតាំងភូមិសាស្ត្រអំណោយផលរវាងតំបន់ឧស្សាហកម្មសក្តានុពលទីក្រុងបាងកក និងហូជីមិញក៏ដូចជានៅជិតសេដ្ឋកិច្ចអាស៊ីធំៗរួមមានចិន ជប៉ុន និងកូរ៉េ និង " **និន្នាការរក្សាស្ថិរភាពនៃខ្សែចង្វាក់ផ្គត់ផ្គង់** " ចំពោះមុខហានិភ័យដែលបណ្តាលមកពីកត្តាភូមិសាស្ត្រនយោបាយ គ្រោះមហន្តរាយធម្មជាតិ ជម្លោះការងារ និងភាពរំខានផ្សេងៗ។

ស្ថានភាពអំណោយផលដោយសារការបើកចំហសេដ្ឋកិច្ច និងរចនាសម្ព័ន្ធសេដ្ឋកិច្ចដែលកំពុងផ្លាស់ប្តូររួមទាំងកត្តាផលលាភប្រជាសាស្ត្រ និងសក្តានុពលសំខាន់ៗផ្សេងទៀតបានផ្តល់នូវលក្ខខណ្ឌចាំបាច់គ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍន៍ និងការធ្វើទំនើបកម្មវិស័យឧស្សាហកម្មកម្ពុជា។ ក្នុងន័យនេះការដាក់ឲ្យអនុវត្តនូវ "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម" របស់រាជរដ្ឋាភិបាលនឹងក្លាយជាបន្ទាស់ប្តូរនៃវិធានដ៏សំខាន់ក្នុងន័យជំរុញសន្ទុះ និងរក្សាចីរភាពនៃកំណើនសេដ្ឋកិច្ច ការបង្កើតការងារ និងការលើកស្ទួយជីវភាពប្រជាជនដោយប្រើប្រាស់ឲ្យអស់លទ្ធភាពនូវសក្តានុពលជាតិសំខាន់ៗដូចជា ប្រភពកម្លាំងពលកម្មវ័យក្មេងមានការបណ្តុះបណ្តាលបានល្អ និងប្រកបដោយចំណេះដឹងខ្ពង់ខ្ពស់ សក្តានុពលដែលកើតចេញពីសមិទ្ធិផលនៃការវិនិយោគយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គម។ ពិសេសវិស័យដឹកជញ្ជូន និងថាមពលកាលានុវត្តភាពពាក់ព័ន្ធនឹងនិន្នាការនគររូបនីយកម្ម និងការរីកលូតលាស់នៃស្រទាប់ប្រជាជនថ្នាក់កណ្តាលដែលមានកម្រិតប្រាក់ចំណូលខ្ពស់ក៏ដូចជាភាពជឿនលឿន និងទំនើបកម្មក្នុងវិស័យកសិកម្ម និងវិស័យសេវាគាំទ្រផ្សេង

ទៀតព្រមទាំង "**ឧត្តមភាពនៃការអភិវឌ្ឍន៍ឈានក្រោយគេ**"។ ជាមួយគ្នានេះ សម្ពាធនៃការកើនឡើងប្រាក់ឈ្នួលបានតម្រូវឲ្យឧស្សាហកម្មកម្មន្តសាលបច្ចុប្បន្នដូចជា វិស័យកាត់ដេរជាដើមខិតខំប្រឹងប្រែងបង្កើនផលិតភាពរបស់ខ្លួនដើម្បីរក្សាភាពប្រកួតប្រជែងនៅក្នុងខ្សែចង្វាក់តម្លៃសកលដែលកត្តានេះនឹងជំរុញឲ្យកម្ពុជាចាំបាច់ត្រូវធ្វើពិពិធកម្មវិស័យឧស្សាហកម្មឲ្យបានឆាប់រហ័សដើម្បីកាត់បន្ថយសម្ពាធនៃការកើនឡើងប្រាក់ឈ្នួលឲ្យប្រព្រឹត្តទៅជាជំហានៗប្រកបដោយសុខដុមភាព និងធានាបាននូវការបង្កើតការងារប្រកបដោយគុណភាព និងមាននិរន្តភាព។

ការអភិវឌ្ឍន៍វិស័យឧស្សាហកម្មគឺជាឧបករណ៍គោលនយោបាយប្រកបដោយប្រសិទ្ធភាពសម្រាប់ការតភ្ជាប់រវាងវិស័យសេដ្ឋកិច្ចសំខាន់ៗដែលជា "ឃ្នាស់" ជំរុញកំណើន និងការងារបន្ថែមក្នុងវិស័យកសិកម្ម ទេសចរណ៍ និងសេវាកម្ម។ ឧស្សាហកម្មនឹងរួមចំណែករំដោះអតិរេកពលកម្មពីវិស័យកសិកម្មដែលធ្វើឲ្យផលិតភាពសរុបកើនឡើង និងមានចំណូលខ្ពស់ជាងមុន។ ចំណូលដែលទទួលបានពីវិស័យឧស្សាហកម្មនឹងត្រូវយកទៅចំណាយលើម្ហូបអាហារ និងសម្ភារៈផ្សេងៗដែលទាញឲ្យមានកំណើនផ្នែកផលិតកម្មឧស្សាហកម្ម និងសេវាកម្មបន្ថែមទៀត។

ដោយឡែកសម្រាប់គោលដៅរយៈពេលវែង ការអភិវឌ្ឍន៍វិស័យឧស្សាហកម្មដែលតម្រូវឲ្យមានការកែទម្រង់ស៊ីជម្រៅផ្នែករចនាសម្ព័ន្ធ និងស្ថាប័នគួបផ្សំនឹងការវិនិយោគលើធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធក៏ដូចជាការជំរុញការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា និងនវានុវត្តន៍ផងដែរនោះនឹងបង្កើតបានជាមូលដ្ឋានគ្រឹះសម្រាប់ពង្រឹងសក្តានុពលកំណើនថ្មីៗ និងលើកកម្ពស់ភាពប្រកួតប្រជែងដែលជាបុរេលក្ខខណ្ឌចាំបាច់សម្រាប់ការអភិវឌ្ឍន៍ក្នុងដំណាក់កាលបន្ទាប់ដោយបញ្ចៀសនូវ "**អន្ទាក់ប្រទេសមានចំណូលមធ្យម**"។ ជាមួយគ្នានេះកត្តាប្រជាសាស្ត្រ និងភូមិសាស្ត្រនយោបាយបានបង្កើតនូវកាលានុវត្តដ៏កម្រប៉ំផុតសម្រាប់ការបោះជំហានលើខ្ពស់រាបថ្មីមួយទៀតនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ពិសេសការកសាងមូលដ្ឋានឧស្សាហកម្មរឹងមាំដែលនឹងប្រែក្លាយកម្ពុជាទៅប្រទេសមានកម្រិតចំណូលមធ្យមក្នុងរយៈពេលដ៏ខ្លីខាងមុខ។ (រាជរដ្ឋាភិបាលកម្ពុជា, គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥, ២០១៥)

### ២.៣.២ បញ្ហាប្រឈម នៃការអភិវឌ្ឍន៍ឧស្សាហកម្មនៅកម្ពុជា

ការអភិវឌ្ឍន៍វិស័យឧស្សាហកម្មនៅកម្ពុជា ប្រឈមនឹងបញ្ហាចំនួនប្រាំ គឺ៖ **ទី១)** កង្វះភាពជាអ្នកដឹកនាំ, ការសម្របសម្រួល និងការសម្រេចចិត្តប្រកបដោយប្រសិទ្ធិភាពគ្រប់កម្រិត ពិសេសការគាំទ្រសំខាន់ៗពាក់ព័ន្ធនឹងបញ្ហាផ្គត់ផ្គង់អគ្គិសនី, ហេដ្ឋារចនាសម្ព័ន្ធ និងឡូជិស្ទីក ធនធានមនុស្ស និងជំនាញ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្សេងទៀត **ទី២)** ការអភិវឌ្ឍមូលដ្ឋានចំណេះដឹងផ្នែកបច្ចេកទេស និងជំនាញដែលជាអាទិភាពសំខាន់ដើម្បីប្រែក្លាយកម្លាំងពលកម្មឲ្យមានជំនាញ និងមានសមត្ថភាពឈោងចាប់យកបច្ចេកទេស និងបច្ចេកវិទ្យាខ្ពស់ **ទី៣)** ការរៀបចំហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មនៅមិនទាន់គ្រប់គ្រាន់ ពិសេសកង្វះការសម្របសម្រួលក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដូចជា ការផ្គត់ផ្គង់អគ្គិសនី, ទឹកស្អាត, បណ្តាញផ្លូវគមនាគមន៍, លូបញ្ចេញ

កាកសំណល់ និងការផ្តល់សេវាសារធារណៈឲ្យបានគ្រប់គ្រាន់ ទី៤) ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុនៅមានកម្រិតដែលជាឧបសគ្គដល់ការផ្តល់ហិរញ្ញប្បទានគម្រោងឧស្សាហកម្មទាំងយន្តការហិរញ្ញប្បទានសាធារណៈ និងឯកជន និង**ទី៥)** បញ្ហាទីផ្សារការងារ និងទំនាក់ទំនងវិជ្ជាជីវៈដែលជាគន្លឹះធានាស្ថិរភាពទីផ្សារការងារ និងការផ្គត់ផ្គង់កម្លាំងពលកម្មក៏ដូចជាការលើកកម្ពស់ផលិតភាព និងជីវភាពរបស់ពលករ (រាជរដ្ឋាភិបាលកម្ពុជា, គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥, ២០១៥)។

## ២.៣.៣ យុទ្ធសាស្ត្រគន្លឹះនៃការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម

ដើម្បីសម្រេចនូវចក្ខុវិស័យខាងលើនេះ យុទ្ធសាស្ត្រគន្លឹះរបស់រាជរដ្ឋាភិបាលផ្តោតជាសំខាន់លើការរៀបចំ និងអនុវត្តនូវក្របខណ្ឌគោលនយោបាយមួយច្បាស់លាស់ដែលមានការសម្របសម្រួលប្រទាក់ក្រឡាគ្នា និងបំពេញគ្នាទៅវិញទៅមកដោយចាប់ផ្តើមពីការកែទម្រង់ និងការកែសម្រួលយន្តការស្ថាប័នដើម្បីធានានូវប្រសិទ្ធភាពនៃការអនុវត្ត "**គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម**"។ ក្របខណ្ឌគោលនយោបាយនេះរួមមានសសរស្តម្ភបួន៖ **ទី១.** ការទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និងការកៀរគរវិនិយោគឯកជនក្នុងស្រុកសម្រាប់អភិវឌ្ឍន៍វិស័យឧស្សាហកម្ម ការអភិវឌ្ឍន៍ និងពង្រីកទីផ្សារនាំចេញ និងការជម្រុញការអភិវឌ្ឍន៍ និងផ្ទេរបច្ចេកវិទ្យា **ទី២.** ការអភិវឌ្ឍន៍ និងទំនើបកម្មសហគ្រាសធុនតូចនិងមធ្យមដើម្បីពង្រីក និងពង្រឹងមូលដ្ឋានឧស្សាហកម្មកម្មន្តសាល ការធ្វើទំនើបកម្មនិងចុះបញ្ជីសហគ្រាសជាផ្លូវការ ការជំរុញការអភិវឌ្ឍន៍និងផ្ទេរបច្ចេកវិទ្យានិងការពង្រឹងការតភ្ជាប់ឧស្សាហកម្មរវាងសហគ្រាសក្នុងស្រុកជាមួយនឹងសហគ្រាសបរទេស ពិសេសនៅក្នុងវិស័យកសិឧស្សាហកម្ម **ទី៣.** ការកែលម្អបរិស្ថាននិយតកម្មដើម្បីពង្រឹងភាពប្រកួតប្រជែងតាមរយៈការលើកកម្ពស់បរិយាកាសវិនិយោគ និងកិច្ចសម្រួលពាណិជ្ជកម្ម ការផ្តល់ព័ត៌មានអំពីទីផ្សារ និងការកាត់បន្ថយចំណាយចម្លងអាជីវកម្ម និង**ទី៤.** ការសម្របសម្រួលគោលនយោបាយគាំទ្ររួមមានការអភិវឌ្ឍន៍ធនធានមនុស្ស ការបណ្តុះបណ្តាលជំនាញ និងការកែលម្អទំនាក់ទំនងឧស្សាហកម្ម ការអនុវត្តផែនការរៀបចំដែនដីនគរូបនីយកម្ម និងផែនការប្រើប្រាស់ដីស្របតាម "**គោលនយោបាយដីធ្លី**" និង "**គោលនយោបាយជាតិស្តីពីការរៀបចំដែនដី**" ព្រមទាំងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរួមមានការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនឡូជីស្ទិក និងការតភ្ជាប់ឌីជីថល ការផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាត ព្រមទាំងសេវាគាំទ្រផ្សេងទៀតដូចជាសេវាសាធារណៈ សេវាសង្គមកិច្ច និងសេវាហិរញ្ញវត្ថុ។

ក្របខណ្ឌយុទ្ធសាស្ត្រខាងលើ មានមុខព្រួញសំខាន់ពីរដែលបំពេញគ្នាទៅវិញទៅមកក្នុងនោះ សសរស្តម្ភទីមួយមានគោលបំណងកៀរគរទុនវិនិយោគដើម្បីបង្កើតឧស្សាហកម្មថ្មីៗ ទ្រង់ទ្រាយធំដែលមានចរិតឧស្សាហកម្មនាំមុខ និងបម្រើឲ្យគោលដៅជ្រៀតចូលទីផ្សារតំបន់ និងអន្តរជាតិក៏ដូចជាការតភ្ជាប់ជាមួយខ្សែចង្វាក់តម្លៃសកល។ សសរស្តម្ភទីពីរ សំដៅពង្រឹងនិងកសាងមូលដ្ឋានឧស្សាហកម្មក្នុងស្រុកមានស្រាប់ដោយផ្តោតលើសហគ្រាសធុនតូចនិងមធ្យមដើម្បីអភិវឌ្ឍន៍ឧស្សាហកម្មគាំទ្រ និងចង្កោមឧស្សាហកម្មក្នុងខ្សែចង្វាក់ផលិតកម្មនិងខ្សែចង្វាក់តម្លៃសំខាន់ៗដែលអាចផ្សារភ្ជាប់នឹងចូលរួមសកម្មភាពផលិតកម្មជាមួយនឹងឧស្សាហកម្មប្រភេទទីមួ

យ។ ដោយឡែក សសរស្តម្ភពីរផ្សេងទៀតមានតួនាទីគាំទ្រ និងរួមចំណែកដល់ការសម្រេចគោលដៅលើការដ្ឋានពីរខាងដើមពោលគឺការបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់ទាក់ទាញការវិនិយោគក្នុងវិស័យឧស្សាហកម្មក៏ដូចជាការសម្រួលសកម្មភាពអាជីវកម្ម និងឧស្សាហកម្មនៅកម្ពុជាដែលពាក់ព័ន្ធនឹងក្របខណ្ឌច្បាប់ និងនិយតកម្មធនធានមនុស្សនិងជំនាញហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមក៏ដូចជាការផ្គត់ផ្គង់ធាតុចូលសម្រាប់ឧស្សាហកម្មដូចជាវត្ថុធាតុដើមអគ្គិសនី ទឹកស្អាតជាដើម(រាជរដ្ឋាភិបាលកម្ពុជា, គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥, ២០១៥)។

យោងតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ យើងអាចទាញបានទំនាក់ទំនងកំណើនសេដ្ឋកិច្ចជាមួយវិស័យឧស្សាហកម្មខាងក្រោមនេះ÷

$$\text{GDP} = \beta_0 + \beta_1 \times Industry \quad (1)$$

GDP = តំណាងឲ្យកំណើនសេដ្ឋកិច្ច(គិតជា%)

Industry = ជាអថេរមួយតំណាងឲ្យវិស័យឧស្សាហកម្មទាំងមូល(គិតជា%)

### ២.៣.៤ ការអនុគ្រោះចំពោះសហគ្រាសដែលមានអនុលោមភាពសារពើពន្ធខ្ពស់

តាមរយៈប្រកាសលេខ០៥៣៦ សហវប្រកចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ស្តីពីចំណាត់ថ្នាក់នៃអនុលោមភាពសារពើពន្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយន្តការលើកទឹកចិត្តនិងអនុគ្រោះពន្ធចំពោះសហគ្រាសដែលមានអនុលោមភាពសារពើពន្ធខ្ពស់ដែលក្នុងនោះរួមមាន ការអនុគ្រោះពន្ធអប្បបរមា១% នៃផលរបរប្រចាំឆ្នាំ, ការបង្វិលសងអាករលើតម្លៃបន្ថែមដោយពុំចាំបាច់ធ្វើសវនកម្មផ្ទៀងផ្ទាត់ជាមុន, និងការមិនធ្វើសវនកម្មក្នុងរយៈពេលសុពលភាពនៃការលើកទឹកចិត្តដែលអ្នកជាប់ពន្ធមានអនុលោមភាពសារពើខ្ពស់ទទួលបាន (វិទ្យា, ២០១៨)។

## ២.៤ អត្ថប្រយោជន៍របស់ឧស្សាហកម្មក្នុងការរួមចំណែកដល់សេដ្ឋកិច្ចកម្ពុជា

ការអភិវឌ្ឍន៍នៃវិទ្យាសាស្រ្ត និងបច្ចេកវិទ្យាបានធ្វើឱ្យមានការរីកចម្រើន និងការរីករាលដាលនៃឧស្សាហកម្មធុនធ្ងន់។ វឌ្ឍនភាពរបស់មនុស្សនាពេលបច្ចុប្បន្ននេះ ត្រូវបានវាស់ដោយសក្តានុពលឧស្សាហកម្ម និងវិបុលភាព។ ដោយបង្ហាញពីអត្ថប្រយោជន៍សម្រាប់ចំនួនប្រជាជនដ៏ច្រើន វិស័យឧស្សាហកម្មបានបដិវត្តន៍របៀបនៃការងារ និងស្តង់ដាររស់នៅរបស់ពិភពលោកឥឡូវនេះ។ ការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជនរាប់ពាន់លាននាក់ វិស័យឧស្សាហកម្មបានត្រួសត្រាយផ្លូវថ្មីសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។

វាជាការពិតដែលមិនអាចប្រកែកបានដែលថាបើគ្មានវិស័យឧស្សាហកម្មទេនោះក៏គ្មានសេដ្ឋកិច្ចណាអាចរីកចម្រើនបានដែរ។ អង្គភាពផលិតកម្ម និងឧស្សាហកម្មផ្តល់អត្ថប្រយោជន៍ជាច្រើនដល់អរិយធម៌តាមរបៀបផ្សេងៗគ្នា។ គុណសម្បត្តិមួយចំនួននៃឧស្សាហូបនីយកម្មត្រូវបានរាយខាងក្រោម។

### ២.៤.១ បង្កើតការងារដល់ប្រជាពលរដ្ឋ និងលើកកម្ពស់គុណភាពរស់នៅ

ការកើនឡើងនៃឧស្សាហូបនីយកម្មអាចនាំឱ្យអត្រាអ្នកអត់ការងារធ្វើ និងភាពក្រីក្រទាបនៅក្នុងតំបន់ដែលបានផ្តល់ឱ្យ។ ការអភិវឌ្ឍន៍ឧស្សាហកម្មនាំទៅរកការងារកាន់តែច្រើនទាំងក្នុងអាជីវកម្មខ្នាតធំ និងខ្នាតតូចដែលអនុញ្ញាតឱ្យមានឱកាសកាន់តែច្រើនសម្រាប់អ្នកដែលអាចនឹងគ្មានការងារធ្វើ។ វាក៏នាំមកនូវការងារពីប្រជាជននៅជិតតំបន់ឧស្សាហកម្ម ដូចជាជាយក្រុង និងជាយកដែន។

វិស័យឧស្សាហកម្មបានរួមចំណែកយ៉ាងសំខាន់ដល់ការបង្កើតការងារ ការបង្កើនប្រាក់ចំណូល និងការលើកកម្ពស់ផលិតភាពតាមរយៈការវិនិយោគ និងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ រួមទាំងការបង្កើតការងារក្នុងវិស័យគាំទ្រដទៃទៀតនៅក្នុងគ្រប់ខ្សែចង្វាក់តម្លៃចាប់តាំងពីការផលិត និងការផ្គត់ផ្គង់វត្ថុធាតុដើម សេវាកម្មដឹកជញ្ជូន និងឡូជីស្ទិក វិស័យហិរញ្ញវត្ថុ និងបណ្តុះបណ្តាលជំនាញជាដើម។ តាមជំរឿនឆ្នាំ២០០៨ ចំនួនការងារក្នុងវិស័យឧស្សាហកម្មបានកើនដល់ជិត ៦០មឺនកន្លែង ឬស្មើនឹង ៨,៦% នៃចំនួនការងារសរុប ប៉ុន្តែតាមការអង្កេតនៃសេដ្ឋកិច្ចឆ្នាំ២០១២ ចំនួនការងារក្នុងវិស័យនេះកើនទៅដល់ ១,៤លានកន្លែង ឬស្មើនឹង ១៨,៦%នៃចំនួនការងារសរុប រហូតមកដល់ឆ្នាំ២០២១ វិស័យឧស្សាហកម្មបានបង្កើតការងារចំនួនជិតមួយលាននាក់នៃរោងចក្រធុនធំ។

**ការចែកចាយការងារតាមវិស័យសេដ្ឋកិច្ចពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៩**




Source: World Bank

ស្ថិតិបង្ហាញពីការបែងចែកការងារនៅក្នុងប្រទេសកម្ពុជាតាមវិស័យសេដ្ឋកិច្ចពីឆ្នាំ 2009 ដល់ឆ្នាំ 2019 ។ ក្នុងឆ្នាំ 2019 បុគ្គលិកនៅកម្ពុជាចំនួន 34.53 ភាគរយសកម្មក្នុងវិស័យកសិកម្ម 27.91 ភាគរយក្នុងឧស្សាហកម្ម និង 37.56 ភាគរយនៅក្នុងវិស័យសេវាកម្ម។

### ២.៤.២ បង្កើនការនាំចេញ និងពង្រឹងពាណិជ្ជកម្មអន្តរជាតិ

ជារៀងរាល់ឆ្នាំ វិស័យឧស្សាហកម្មបាននាំចេញនូវផលិតផលជាច្រើនទៅក្រៅប្រទេស ក្នុងនោះមានប្រទេសចិនដែលជាដៃគូសហការណ៍ពាណិជ្ជកម្មយ៉ាងជិតស្និតដោយបានអនុញ្ញាត្តិឲ្យកម្ពុជានាំចេញទំនិញមួយចំនួនទៅចិនដោយអត្រាតម្លៃពន្ធសូន្យភាគរយតាមរយៈ CCFTA ។ យោងតាមតួលេខក្នុងឆ្នាំ២០២០ ដែលបានពីក្រសួងពាណិជ្ជកម្ម ការនាំចេញសរុបរបស់កម្ពុជាទៅប្រទេសចិនបានកើនឡើងជាង ៨% ដោយសម្រេចបាន ១០៨៦ ពាន់លានដុល្លារ។

Cambodia: Export (%GDP) ឆ្នាំ2009-2019

| Year | Export (%GDP) | Export ($Billion) |
|---|---|---|
| 2009 | 49.22 | 5,12 |
| 2010 | 54.08 | 6,08 |
| 2011 | 54.08 | 6,9 |
| 2012 | 57.89 | 8,1 |
| 2013 | 62.39 | 9,50 |
| 2014 | 62.60 | 10,46 |
| 2015 | 61.72 | 11,14 |
| 2016 | 61.28 | 12,27 |
| 2017 | 6.68 | 13,46 |
| 2018 | 61.60 | 15,14 |
| 2019 | 61.09 | 16,55 |

Source: World Bank

### ២.៤.៣ ជួយសម្រួលដល់សេដ្ឋកិច្ចជាតិ

វិស័យឧស្សាហកម្មបានរួមចំណែកដល់ការអភិវឌ្ឍន៍ ការទ្រទ្រង់ និងលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិ។ ជាក់ស្តែង នៅក្នុងឆ្នាំ២០២១ មានរោងចក្រថ្មីកើនឡើងចំនួន១៦៣ រោងចក្រទៀត និងបង្កើនការនាំចេញជាច្រើនទៅក្រៅប្រទេសដែលទាំងនេះសុទ្ធតែជាសម្មិផលដែលទទួលបានពីវិស័យឧស្សាសហកម្ម។ជាពិសេសអាចជួយឲ្យសេដ្ឋកិច្ចជាតិរីកចម្រើននឹងមានលទ្ធភាពអាចប្រកួតប្រជែងជាមួយប្រទេសមហាអំណាចលើពិភពលោក។

## ២.៤.៤ កាត់បន្ថយភាពក្រីក្រ និងការធ្វើចំណាកស្រុក

ភាពក្រីក្រជាឧបសគ្គដែលនាំឲ្យមានគម្លាតរវាងអ្នកមាន និងអ្នកក្រនៅក្នុងប្រទេសនិមួយៗ។ ជាក់ស្តែងប្រទេសកម្ពុជាមានវិស័យឧស្សាហកម្មនាំមុខគេដែលសេដ្ឋកិច្ចកម្ពុជារក្សាបាននូវកំណើនជាមធ្យមចំនួន ៧.៧% ក្នុងមួយឆ្នាំ ហើយអត្រានៃភាពក្រីក្របានប្រែប្រួលគួរឲ្យកត់សម្គាល់។ បើគិតចាប់ពីឆ្នាំ២០០៩ ដល់២០២០ អត្រានៃភាពក្រីក្របានធ្លាក់ចុះចំនួន ១.៦% ក្នុងមួយឆ្នាំដោយសារមានការកើនឡើងនៃប្រាក់ចំណូលពលកម្មដែលដើរតួជាកត្តាជំរុញមួយផ្នែកធំ ជាពិសេសបានកាត់បន្ថយនូវចំនួនពលករចំណាកស្រុកផងដែរ។

**GDP per capita growth of Cambodia (2010-2019)**

| Year | GDP per capita growth(%) | GDP per capital growth ($) |
|---|---|---|
| 2010 | 4.3 | 785.5 |
| 2011 | 5.4 | 882.3 |
| 2012 | 5.6 | 950.9 |
| 2013 | 5.6 | 1,013.4 |
| 2014 | 5.4 | 1,093.5 |
| 2015 | 5.3 | 1,162.9 |
| 2016 | 3.3 | 1,269.6 |
| 2017 | 5.4 | 1,385.3 |
| 2018 | 5.9 | 1,512.1 |
| 2019 | 5.5 | 1,643.1 |

Source: World Bank

## ២.៤.៥ ទាក់ទាញវិនិយោគិនបរទេស

បើយោងតាម រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្ហាញឲ្យឃើញថា បច្ចុប្បន្នកម្ពុជាក្នុងចំណោមប្រទេសជាសមាជិកអាស៊ានទាំង១០ បានក្លាយជាប្រទេសដែលមានសក្តានុពលខ្ពស់ក្នុងការទាក់ទាញវិនិយោគទុនបរទេស ហើយនឹងក្លាយជាគោលដៅវិនិយោគរបស់ក្រុមហ៊ុននានា ជាពិសេសចិន ជប៉ុន និងកូរ៉េ។ កត្តានេះគឺជាទឡ្ហីករណ៍បង្ហាញឲ្យឃើញនូវជំនឿទុកចិត្តពីសំណាក់អ្នកវិនិយោគបរទេសទៅលើគោលនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជាដែលធានាបាននូវបរិយាកាសវិនិយោគពាណិជ្ជកម្ម ស្ថិរភាពនយោបាយ និងកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ ខណៈពេលនោះ ការវិនិយោគផ្ទាល់ពីក្រៅប្រទេសក្នុងវិស័យឧស្សាហកម្មនៃផ្នែកកាត់ដេរសម្លៀកបំពាក់បានបង្កើតការងារដល់ប្រជាពលរដ្ឋប្រមាណ៣សែន៥ម៉ឺននាក់។ មិនតែប៉ុណ្ណោះ វិនិយោគិនបរទេសនាំមកជាមួយពួកគាត់នូវបច្ចេកវិទ្យានៃការផលិត និងរបៀបរស់នៅសេវាគ្រប់គ្រង និងការអនុវត្តធុរកិច្ចចម្រុះចំណែកឯផលប៉ះពាល់វិជ្ជមានមកពីខាងក្រៅពាក់ព័ន្ធនឹងការវិនិយោគផ្ទាល់ពីក្រៅប្រទេសទាំងអស់នេះបានផ្តល់មកនូវផលប្រយោជន៍ដល់ប្រទេសកម្ពុជា។

**Foreign Direct Investment in Cambodia (2009-2019)**

| Year | FDI (%) | FDI ($Billion) |
|---|---|---|
| 2009 | 8.93 | 0,93 |
| 2010 | 12.49 | 1,40 |
| 2011 | 11.99 | 1,54 |
| 2012 | 14.15 | 1,99 |
| 2013 | 13.58 | 2,07 |
| 2014 | 11.10 | 1,85 |
| 2015 | 10.10 | 1,82 |
| 2016 | 12.37 | 2,48 |
| 2017 | 12.57 | 2,79 |
| 2018 | 13.07 | 3,21 |
| 2019 | 13.52 | 3,66 |
| 2020 | 14.01 | 3,62 |
| Total | 144.88 | 27,36 |

Source: World Bank

ជាសន្និដ្ឋាន សកម្មភាពសេដ្ឋកិច្ចក្នុងវិស័យឧស្សាហកម្មបានឆ្លុះបញ្ចាំងពីកំណើនសេដ្ឋកិច្ចយ៉ាងពិតប្រាកដ។ វិស័យមានសារៈសំខាន់សម្រាប់កំណើនយូរអង្វែងប្រកបដោយនិរន្តរភាព និងការកាត់បន្ថយភាពក្រីក្រ។ នៅក្នុងប្រទេសដែលបានសិក្សា ការរីកចម្រើននៃវិស័យផលិតកម្មបានបង្កើតឱកាសការងារនៅខាងក្រៅវិស័យកសិកម្ម និងដូចជាការផលិតនៅក្នុងស្រុក។

# ជំពូកទី៣.

# ការវិភាគលើទិន្នន័យ

# ជំពូកទី៣.

# ការវិភាគលើទិន្នន័យ

## ៣.១ ការកំណត់អថេរ និងគំរូវិភាគ

គោលដៅនៃការស្រាវជ្រាវនេះ គឺដើម្បីធ្វើវិភាគពីឥទ្ធិពលនៃឧស្សាហកម្ម ទៅលើកំណើនសេដ្ឋកិច្ចនៃប្រទេសកម្ពុជា។ ដោយការវិភាគនេះគឺធ្វើការបញ្ចូលទិន្នន័យនៃវិស័យឧស្សាហកម្ម និងកំណើនផលិតផលជាតិចូលទៅ Excel ដើម្បីទទួលនូវតារាង ANOVA នឹងធ្វើការបកស្រាយលទ្ធផលតាមតារាងនេះដែរ។

ការស្រាវជ្រាវនេះមានអថេរពន្យល់៤ យោងតាមសមីការវាស់កំណើនសេដ្ឋកិច្ច៖

GDP=C+I+G+NI

អថេរពន្យល់ទាំង៤មានConsumption, Government Expend, Investment, Net Income ជាអថេរពន្យល់ និង GDP Growth Rate ជាអថេរអាស្រ័យដើម្បីស្វែងយល់។ ប៉ុន្តែដោយសារតែប្រធានបទបកស្រាយអំពីវិស័យឧស្សាហកម្មនាំដែលនាំមានកំណើននៅក្នុងសេដ្ឋកិច្ចកម្ពុជា ដូចនេះក្នុងចំណោមអថេរពន្យល់ទាំង៤ យើងសូមទាញយកអថេរមួយមកសិក្សា គឺ FDI ដែលជាផ្នែកមួយជំនួសអោយ Investment។ FDI គឺជាការវិនិយោគផ្ទាល់ពីបរទេសដែល មានភាគច្រើនជាការវិនិយោគផ្ទាល់ក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា ក៏មានវិនិយោគនៅក្នុងស្រុកដែរ។

## ៣.២ ទំនាក់ទនងរវាងវិស័យឧស្សាហកម្ម និងផលិតផលក្នុងស្រុកសរុប

### ផលិតផលជាតិសរុប

កំណើនផលិតផលក្នុងស្រុកសរុប នៅតែមានភាពរឹងមាំនៅក្នុងប្រទេសកម្ពុជា ដែលជំរុញដោយវិស័យអចលនទ្រព្យ សំណង់ វិស័យកាត់ដេរ និងវិស័យទេសចរណ៍។ ក្រុមសេដ្ឋវិទូដែលមានមូលដ្ឋាននៅចក្រភពអង់គ្លេសដែលល្បីខាងការវិភាគ និងព្យាករណ៍សេដ្ឋកិច្ចរបស់ប្រទេសជាង២០០ បានទទួលស្គាល់ប្រទេសកម្ពុជាថាជាប្រទេសមានសេដ្ឋកិច្ចលូតលាស់លឿនបំផុត និងបានព្យាករណ៍ថាកំណើនផលិតផលក្នុងស្រុកសរុបរបស់កម្ពុជានឹងនៅតែរឹងមាំក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ ហើយនឹងឈានដល់កម្រិតល្អលើកំណើន៦% ក្នុងមួយឆ្នាំ។ នៅចុងឆ្នាំ២០១៦ កំណើន GDP នៅកម្ពុជាបានឈានដល់ ៦.៩% និងបានកើនឡើងបន្តិច ៧% ក្នុងឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០១៨ កម្ពុជាបានកើនឡើងជាលទ្ធផលដែលទទួលបានកំណើនសេដ្ឋកិច្ចល្អប្រសើរដល់ ៧.៥%។ អត្រាកំណើនបច្ចុប្បន្ន និងអនាគតនៃកំណើនផលិតផលក្នុងស្រុកសរុបធ្វើឲ្យកម្ពុជាជាជម្រើសដ៏សំខាន់មួយសម្រាប់វិនិយោគិនបរទេសដែលកំពុងស្វែងរកកន្លែងវិនិយោគដែលមានសេដ្ឋកិច្ចរីកចម្រើនឆាប់រហ័ស និងមានសញ្ញាតិចតួចនៃការធ្លាក់ចុះនៅក្នុងទសវត្សរ៍បន្តបន្ទាប់ (Bank, 2010-2019)។

## វិស័យឧស្សាហកម្ម

បន្ទាប់ពីដំណើរការសេដ្ឋកិច្ចរឹងមាំអស់រយៈពេលពីរទសវត្សរ៍ ប្រទេសកម្ពុជាបានផ្លាស់ប្តូរទៅជាក្រុមប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥ ហើយបានកំណត់ទិសដៅនៃការឈានទៅក្លាយជាក្រុមប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ការនាំចេញរបស់កម្ពុជាត្រូវបានគ្របដណ្តប់ដោយសម្លៀកបំពាក់ ស្បែកជើង និងសម្ភារៈធ្វើដំណើរ។ វិស័យឧស្សាហកម្មដែលមានវិស័យកាត់ដេរជាសសរស្តម្ភមួយនៃសេដ្ឋកិច្ចកម្ពុជាដោយបាននាំចេញសម្លៀកបំពាក់រហូតដល់១១%នៃផលិតផលជាតិសរុបក្នុងឆ្នាំ២០១៩ ដែលនេះបញ្ជាក់ឲ្យឃើញថាវិស័យកាត់ដេរគឺជាចំណែកមួយយ៉ាងសំខាន់នៅក្នុងវិស័យឧស្សាហកម្មដែលជំរុញដល់កំណើនសេដ្ឋកិច្ចកម្ពុជា។

តារាងដែលបង្ហាញពីទំនាក់ទំនងរវាងវិស័យឧស្សាហកម្ម និងផលិតផលជាតិសរុប

| ឆ្នាំ | ផលិតផលជាតិសរុប % | វិស័យឧស្សាហកម្ម % |
|---|---|---|
| 2010 | 6 | 12.5 |
| 2011 | 7.1 | 12.0 |
| 2012 | 7.3 | 14.1 |
| 2013 | 7.4 | 13.6 |
| 2014 | 7.1 | 11.1 |
| 2015 | 7 | 10.1 |
| 2016 | 6.9 | 12.4 |
| 2017 | 7 | 12.6 |
| 2018 | 7.5 | 13.1 |
| 2019 | 7.1 | 13.5 |

ប្រភព ( data.worldbank.org ) , ( www.statista.com )

## ៣.៣ ការវិភាគទិន្នន័យ




តាមរយៈក្រាហ្វទិន្នន័យខាងលើយើងអាចសង្កេតឃើញថា ក្នុងរយៈពេលពីរទសវត្សមុនការរាតត្បាតនៃជំងឺកូវីដ-១៩ ប្រទេសកម្ពុជាបានឆ្លងកាត់ការផ្លាស់ប្តូរដ៏សំខាន់មួយ ដោយឈានដល់ឋានៈមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ 2015 និងបង្ហាញពីក្តីប្រាថ្នានៃការសម្រេចបាននូវឋានៈចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030។ ជំរុញដោយការនាំចេញសម្លៀកបំពាក់ និងទេសចរណ៍ សេដ្ឋកិច្ចរបស់កម្ពុជាមាននិរន្តរភាព។ អត្រាកំណើនប្រចាំឆ្នាំជាមធ្យម 7.7 ភាគរយនៅចន្លោះឆ្នាំ 1998 និងឆ្នាំ 2019 ដែលធ្វើឱ្យវាក្លាយជាប្រទេសមួយដែលមានសេដ្ឋកិច្ចរីកចម្រើនលឿនបំផុតនៅលើពិភពលោក។

ក្នុងលក្ខខណ្ឌនេះពួកយើងនឹងធ្វើការសិក្សាវិភាគពីទំនាក់ទំនងរវាងផលិតផលក្នុងស្រុកសរុប និងឧស្សាហកម្មនៅក្នុងកំឡុងពេល១០ឆ្នាំចុងក្រោយ ព្រោះតែមួយទសវត្សចុងក្រោយនេះវិស័យឧស្សាហកម្មមានការកើនឡើងជាលំដាប់ដែលជាហេតុជម្រុញកំណើនសេដ្ឋកិច្ច មានភាពប្រសើរជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ទោះបីជាមិនមានសន្ទុះខ្លាំង ប៉ុន្តែនៅតែស្ថិតនៅក្នុងលក្ខខណ្ឌល្អប្រសើរបើប្រៀបធៀបទៅនឹងប្រទេសកំពុងអភិវឌ្ឍន៍ ដទៃទៀតនៅក្នុងអាស៊ី។ ចំពោះការវិភាគទំនាក់ទំនងរវាងផលិតផលក្នុងស្រុក និងវិស័យឧស្សាហកម្ម យើងរកដោយការបញ្ចូលទិន្នន័យទាំងពីរនេះ ក្នុងកម្មវិធីExcel ដើម្បីរកតួលេខយកមក ជំនួសក្នុងសមីការខាងក្រោមនេះ៖

$$GDP\% = \beta_0 + \beta_1 (Industry\%)$$

$$GDP = 5.95 + 0.086x(Industry)$$

$$R^2 = 0.06, \quad n = 10$$

យោងតាមសមីការវិភាគទិន្នន័យខាងលើ អាចវិភាគឃើញថាមេគុណ $\beta_1$=0.086 របស់វិស័យឧស្សាហកម្មមានសញ្ញាវិជ្ជមាន នោះមានន័យថា កាលណាវិស័យឧស្សាហកម្មមានកំណើននាំឲ្យមានកំណើននៅក្នុងសេដ្ឋកិច្ចដូចគ្នា។ ជាក់ស្តែងនៅចន្លោះឆ្នាំ២០១០-២០១៩ ទំហំសេដ្ឋកិច្ចមានការកើនឡើងជាលំដាប់ដោយសារវិស័យឧស្សាហកម្មមានកំណើនជាមធ្យមចំនួន 12.5%។ នេះបញ្ជាក់ឲ្យឃើញថាដោយសារភាពរឹងមាំនៃវិស័យឧស្សាហកម្មទើបនាំអោយប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចរឹងមាំជាប់រហូតចាប់តាំងពីឆ្នាំ 2011 ជាមួយនឹងផលិតផលក្នុងស្រុកសរុបជាមធ្យមប្រហែល 7 ភាគរយក្នុងមួយឆ្នាំ ហើយកំណើននេះបានបន្តរហូតដល់ឆ្នាំ 2019។ បើយោងតាមកំណើនជាមធ្យមរបស់GDP និងវិស័យឧស្សាហកម្មដែលមានការកើនឡើងយ៉ាងនេះ ដោយមានមេគុណទំនាក់ទំនង R=0.25 រឹតតែបង្ហាញឲ្យកាន់តែច្បាស់ថា វិស័យឧស្សហកម្មមានឥទ្ធិពលទៅលើកំណើនសេដ្ឋកិច្ចយ៉ាងពិតប្រាកដ។

ជាលទ្ធផលការចូលរួមនៃវិស័យឧស្សាហកម្មទៅក្នុងកំណើនសេដ្ឋកិច្ចមានតែ12.5% នៅឆ្នាំ2010 ប៉ុណ្ណោះ ហើយកំណើននេះនៅតែបន្ត ជាលំដាប់រហូតដល់ឆ្នាំ 2019 កើនដល់ 13.5% ដោយកំណើនផលិតផលសរុបក្នុងស្រុកកើនពី 6% រហូតដល់ 7.1% ។ តួលេខទាំងនេះគឺល្អខ្លាំងណាស់បើប្រៀបធៀបទៅនឹងប្រទេសដទៃទៀតនៅក្នុងអាស៊ី។ កំណើនសេដ្ឋកិច្ចនេះត្រូវបានរំពឹងថានឹងមាននិន្នាការកើនឡើងជាមួយនឹងកំណើន 7.0% ដែលត្រូវបានព្យាករណ៍សម្រាប់ឆ្នាំ 2019 និង 6.8% សម្រាប់ឆ្នាំ 2020 នេះបើយោងតាមធនាគារអភិវឌ្ឍន៍អាស៊ី (ទាំងនេះត្រូវបានធ្វើឡើងមុនពេលផលប៉ះពាល់នៃ COVID-19 នៅដើមឆ្នាំ 2020)។

# សេចក្តីសន្និដ្ឋាន
# និងការផ្តល់អនុសាសន៍

# សេចក្ដីសន្និដ្ឋាន និងផ្ដល់អនុសាសន៍

## ១.សេចក្ដីសន្និដ្ឋាន

យោងតាមការបកស្រាយខាងលើមក យើងអាចសន្និដ្ឋានបានថាស្ថានភាពសេដ្ឋកិច្ចនៅប្រទេសកម្ពុជាមានភាពល្អប្រសើរ ដោយមានការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ទូលំទូលាយ និងកម្មវិធីកំណែទម្រង់រចនាសម្ព័ន្ធ។ ដើម្បីជំរុញការអភិវឌ្ឍន៍ឧស្សាហកម្ម រដ្ឋាភិបាលបានផ្តល់ការលើកទឹកចិត្តដ៏សប្បុរសដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស (FDI)។ ការលើកលែងពន្ធត្រូវបានផ្តល់ជូនលើទំនិញកម្រិតមធ្យមនាំចូល និងលើការនាំចេញទំនិញសម្រេច។ ប្រទេសកម្ពុជាបានក្លាយជាសមាជិកនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍) ក្នុងឆ្នាំ 1999 ហើយទីបំផុតអង្គការពាណិជ្ជកម្មពិភពលោក (WTO) ក្នុងឆ្នាំ 2003 ។ លំហូរចូលនៃ FDI បានកើនឡើងពីត្រឹមតែ 124 លានដុល្លារក្នុងឆ្នាំ 1993 ដល់ 520 លានដុល្លារក្នុងឆ្នាំ 2009 និងដល់ជាង 1,500 លានដុល្លារក្នុងឆ្នាំ 2012 ។

សកម្មភាពរបស់រដ្ឋជាច្រើនត្រូវបានបញ្ចប់ ហើយមានតែសហគ្រាសដែលមានលទ្ធភាពសេដ្ឋកិច្ចប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឱ្យបន្ត។ សហគ្រាសសាធារណៈប្រកួតប្រជែងជាមួយវិស័យឯកជនក្នុងវិស័យភាគច្រើន ហើយជាទូទៅមានតែការរស់រានមានជីវិតដោយសារឧបសគ្គភូមិសាស្ត្រលើការប្រកួតប្រជែង។ យោងតាមជំរឿនសេដ្ឋកិច្ចដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ក្នុងឆ្នាំ 2011 គ្រឹះស្ថានឯកជនមានចំនួន 96 ភាគរយនៃចំនួនអង្គការសរុប ខណៈដែលគ្រឹះស្ថានគ្រប់គ្រងរបស់រដ្ឋមានតិចជាង 3 ភាគរយ។ ក្នុងរយៈពេលពីរទស្សវត្សចុងក្រោយនេះ សេដ្ឋកិច្ចកម្ពុជាបានរីកចម្រើនក្នុងអត្រាជាមធ្យម ៧,៧ ភាគរយក្នុងមួយឆ្នាំ) និង ១០,៣ ភាគរយក្នុងកំឡុងឆ្នាំ ២០០៤-២០០៨ ។

បើយោងតាមធនាគារពិភពលោក "សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានរក្សាបាននូវអត្រាកំណើនជាមធ្យម 7% ចន្លោះឆ្នាំ 1998 ដល់ឆ្នាំ 2019ដែលធ្វើឱ្យវាក្លាយជាប្រទេសមួយដែលមានសេដ្ឋកិច្ចរីកចម្រើនលឿនបំផុតនៅលើពិភពលោក" ដែលមានសសរស្តម្ភទាំងបួនដែលគាំទ្រសេដ្ឋកិច្ចកម្ពុជា ឬឧស្សាហកម្មសំខាន់គឺការនាំចេញសម្លៀកបំពាក់ និងស្បែកជើង ទេសចរណ៍ កសិកម្ម និងសំណង់ ដែលជាទូទៅទទួលបានកំណើនវិជ្ជមាន និងជួយសេដ្ឋកិច្ចជាតិ ដោយកាត់បន្ថយភាពក្រីក្រព្រោះមានទីផ្សារការងារច្រើន ដោយសារតែមានវិនិយោគិនបរទេសជាច្រើនធ្វើការវិនិយោគនៅកម្ពុជា និងលើកស្ទួយជីវភាពប្រជាជនកាន់តែប្រសើរ ដោយចំណូលរបស់ប្រជាជនមានការកើនឡើង បូករួមទាំងការបង្កើនការផលិតផលក្នុងស្រុកនាំអោយការ នាំចេញនូវផលិតផលក៏បានច្រើន ដែលជួយសេដ្ឋកិច្ចយ៉ាងខ្លាំង។ លទ្ធផលដ៏រឹងមាំនេះ ភាគច្រើនត្រូវបានជំរុញដោយការពង្រីកជាបន្តបន្ទាប់នៃឧស្សាហកម្មសំខាន់ៗរបស់ព្រះរាជាណាចក្រកម្ពុជា។

## ២. ផ្តល់អនុសាសន៍

ជាការពិតណាស់កំណើននៃវិស័យឧស្សាហកម្ម បានផ្តល់សារៈប្រយោជន៏ជាច្រើនទៅអោយប្រជាជន និងសេដ្ឋកិច្ចជាតិកម្ពុជាទាំងមូល។ ជាមួយនឹងផលប្រយោជន៏នៃវិស័យឧស្សាហកម្មនេះ វិស័យនេះក៏នៅតែជួបបញ្ហា និងភាពរាំងស្ទះជាច្រើនទៀត ដែលវាធ្វើអាក់សកម្មភាពនៃការអភិវឌ្ឍន៏វិស័យនេះ បញ្ហានេះហើយដែលរាជរដ្ឋាភិបាលគួរតែចិត្តទុកដាក់ និងពង្រឹងវិធានការដើម្បីរកដំណោះស្រាយនៃបញ្ហានេះ អោយភាពធូរប្រសើរដើម្បីអោយសេដ្ឋកិច្ចកាន់តែឆាប់មានកំណើននិងមានការអភិវឌ្ឍន៏កាន់តែខ្លាំងសម្រាប់ការវាយលុកចូលទីផ្សារបរទេសជាដើម។

ដូចដែលអ្នកទាំងអស់គ្នាដឹងហើយថា វិស័យឧស្សាហកម្មនៅកម្ពុជាគឺមានវិស័យសំខាន់ៗជាច្រើនជាពិសេសវិស័យសំខាន់ទាំង៤សុទ្ធតែជួបនឹងឧបសគ្គប្រឈមដូចគ្នា។ ជាអនុសាន៏ ខ្ញុំយល់ឃើញថា កំណែទម្រង់សំខាន់ៗគឺចាំបាច់សម្រាប់ប្រទេសកម្ពុជា ដើម្បីរក្សានិរន្តរភាពកំណើនដែលគាំទ្រអ្នកក្រីក្រ ជំរុញការប្រកួតប្រជែង ការគ្រប់គ្រងទ្រព្យសម្បត្តិធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងលើកកម្ពស់លទ្ធភាពទទួលបាន និងគុណភាពនៃសេវាសាធារណៈ។ កម្ពុជានៅតែមានគម្លាតផ្នែកហេដ្ឋារចនាសម្ព័ន្ធធ្ងន់ធ្ងរ ហើយនឹងទទួលបានអត្ថប្រយោជន៍ពីការតភ្ជាប់ និងការវិនិយោគកាន់តែច្រើនលើហេដ្ឋារចនាសម្ព័ន្ធជនបទ និងទីក្រុង។ ការធ្វើពិពិធកម្មសេដ្ឋកិច្ចបន្ថែមទៀតនឹងតម្រូវឱ្យមានការជំរុញភាពជាសហគ្រិន ពង្រីកការប្រើប្រាស់បច្ចេកវិទ្យា និងការកសាងជំនាញថ្មីៗ ដើម្បីដោះស្រាយតម្រូវការទីផ្សារការងារដែលកំពុងរីកចម្រើន។ ស្ថាប័នសាធារណៈដែលមានទំនួលខុសត្រូវ និងទទួលខុសត្រូវក៏នឹងមានការរិះគន់ផងដែរ។គុណភាពនៃធនធានមនុស្សនឹងមានសារៈសំខាន់បំផុត ដើម្បីសម្រេចបាននូវគោលដៅប្រកបដោយមហិច្ឆិតារបស់ប្រទេសកម្ពុជា ក្នុងការឈានទៅដល់ឋានៈមានប្រាក់ចំណូលមធ្យមនៅឆ្នាំ 2030។

# ឯកសារយោង

# ឯកសារយោង

Ackermann, N. (2012, 2 15). *study.com*. Retrieved from economic growth impact theory: https://study.com/learn/lesson/economic-growth-impact-theory.html

Ashworth, D. (2015, 7 31). *Yahoo! Finance*. Retrieved from Yahoo!Finance website: https://finance.yahoo.com/news/economic-growth-why-important-162936556.html?guccounter=1

Bank, T. W. (2010-2019). Retrieved from The World Bank: https://data.worldbank.org/indicator/NY.GDP.MKTP.KD.ZG?end=2020&locations=kh-er

Galor, O. (2005). *From Stagnation to Growth Unified Growth Theory.* Amsterdam: Handbook of Economic Growth.

Gandhi, Y. (2022, 2 6). *analystic steps*. Retrieved from analysticsteps.com: https://www.analyticssteps.com/blogs/what-economic-growth-and-how-measure-it

Onyimadu, C. O. (2015, May 20). *Researchgate*. Retrieved from Researchgate Web Site: https://www.researchgate.net/publication/314456361_An_Overview_of_Endogenous_Growth_Models_Theory_and_Critique

Phanet, H. (2022, 4 26). *The Phnom Penh Post*. Retrieved from Cambodia's FDI surges 11.2% to $41B in 2021: https://www.phnompenhpost.com/business/cambodias-fdi-surges-112-41b-2021#:~:text=Broken%20down%20by%20sector%2C%20finance,with%20%245.3%20billion%20going%20into

realestate. (2019). *ការផលិតសម្លៀកបំពាក់*. Retrieved from realestate:

https://www.realestate.com.kh/km/investment-guide/core-industries/

realestate. (2019). *ការសាងសង់*. Retrieved from realestate.com.kh:

https://www.realestate.com.kh/km/investment-guide/core-industries/

realestate. (2019). *ទេសចរណ៍*. Retrieved from realestate.com.kh:

https://www.realestate.com.kh/km/investment-guide/core-industries/

Stanbic. (2022, June). *Main Sectors of Industry*. Retrieved from Stanbic: https://www.tradeclub.stanbicbank.com/portal/en/market-potential/indonesia/economical-context?clear_s=y

Stanbic. (2022, June). *Main Sectors of Industry*. Retrieved from Stanbic: https://www.tradeclub.stanbicbank.com/portal/en/market-potential/thailand/economical-context?clear_s=y

Team, C. (2021, May 6). *CFI*. Retrieved from CFI Web site: https://corporatefinanceinstitute.com/resources/knowledge/economics/theories-of-growth/

Unwin, A. a. (1986). *An International to Development Economics.* London: Economic Development and Planing.

Yong, L. (2021, 5 21). *Industrial Analystic Platform*. Retrieved from Industrial Analystic Platform website: https://iap.unido.org/articles/why-industrial-development-matters-now-more-ever

ច័ន្ទតារា, វ. (2021). *មានកត្តាជំរុញពីក្រោយអ្វីខ្លះ ធ្វើឱ្យសេដ្ឋកិច្ចសិង្ហបុរីមានកំណើនល្អក្នុងត្រីមាសទី១នេះ?* Retrieved from ខេមបូណូមីស: https://cambonomist.com/news/behind-singapore-gdp-growth-in-q1-2021-/

ជួនណារ៉ុន, ប. ហ. (២០១៥). *សេដ្ឋកិច្ចនៃប្រទេសកម្ពុជា.* ភ្នំពេញ.

ជួនណារ៉ុន, ប. ហ. (២០១៥). *សេដ្ឋកិច្ចនៃប្រទេសកម្ពុជា.* ភ្នំពេញ.

ណារ៉ុន, ប. ហ. (២០១៧). *គោលនយោបាយទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសនៃប្រទេសកម្ពុជានាសម័យទំនើប.* ភ្នំពេញ: ស៊ីប៉ា.

រាជរដ្ឋាភិបាលកម្ពុជា. (២០១៥). *គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥.* ភ្នំពេញ.

រាជរដ្ឋាភិបាលកម្ពុជា. (២០១៥). *គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥.* ភ្នំពេញ.

រាជរដ្ឋាភិបាលកម្ពុជា. (២០១៥). *គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥.* ភ្នំពេញ.

រាជរដ្ឋាភិបាលកម្ពុជា. (២០១៥). *គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥.* ភ្នំពេញ.

វិទ្យា, ល. (២០១៨, កក្កដា ២៦). Retrieved from ខ្មែរប៉ុស្ដិ៍: https://khmerpostasia.com/archives/15053

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

| ឆ្នាំ | %GDP | %Industry |
|---|---|---|
| 2010 | 6 | 12.5 |
| 2011 | 7.1 | 12 |
| 2012 | 7.3 | 14.1 |
| 2013 | 7.4 | 13.6 |
| 2014 | 7.1 | 11.1 |
| 2015 | 7 | 10.1 |
| 2016 | 6.9 | 12.4 |
| 2017 | 7 | 12.6 |
| 2018 | 7.5 | 13.1 |
| 2019 | 7.1 | 13.5 |

SUMMARY OUTPUT

| *Regression Statistics* | |
|---|---|
| Multiple R | 0.254944384 |
| R Square | 0.064996639 |
| Adjusted R Square | -0.051878781 |
| Standard Error | 0.422040449 |
| Observations | 10 |

ANOVA

| | *df* | *SS* | *MS* | *F* | *Significance F* |
|---|---|---|---|---|---|
| Regression | 1 | 0.099054878 | 0.099054878 | 0.556118978 | 0.477165465 |
| Residual | 8 | 1.424945122 | 0.17811814 | | |
| Total | 9 | 1.524 | | | |

| | *Coefficients* | *Standard Error* | *t Stat* | *P-value* | *Lower 95%* | *Upper 95%* | *Lower 95.0%* | *Upper 95.0%* |
|---|---|---|---|---|---|---|---|---|
| Intercept | 5.953871951 | 1.462557337 | 4.070863959 | 0.003579135 | 2.581208684 | 9.326535219 | 2.581208684 | 9.326535219 |
| X Variable 1 | 0.086890244 | 0.116516427 | 0.745733852 | 0.477165465 | -0.181797119 | 0.355577606 | -0.18179712 | 0.355577606 |